មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែមិថុនា ឆ្នាំ២០១៨

# សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា

# ការសង្កេតការណ៍នៅសាលាឧទ្ធរណ៍



## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)

របាយការណ៍ស្តីពី "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា" ជាការបោះពុម្ពផ្សាយរបស់គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")។ ម.ស.ម.ក គឺជាអង្គការមិនមែនរដ្ឋាភិបាល ("អង្គការ") មិនចូលបក្សសម្ពន្ធដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺកម្ពុជាគ្មានអំពើហិង្សាដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសិទ្ធិស្មើគ្នា និងត្រូវបានផ្តល់អំណាច ដើម្បីចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានការចែករំលែកផលប្រយោជន៍ពីការអភិវឌ្ឍប្រទេសកម្ពុជា។ ម.ស.ម.ក មានគោលបំណងចង់បាននីតិរដ្ឋ ជាជាងនិទណ្ឌភាព ស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងសង្គមសេរីពហុបក្សដែលភាពចម្រុះត្រូវបានគេស្វែងរក និងអបអរសាទរជាជាងការមិនអើពើ និងការដាក់ទោស។ ស្លាកសញ្ញារបស់ ម.ស.ម.ក មាន រូបសត្វស្លាបពណ៌ស កំពុងហើរបំបែកចេញពីរង្វង់មូលពណ៌ផ្ទៃមេឃ ដែលមានន័យថា គឺជាការទាមទារសេរីភាពនៅកម្ពុជា។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ ម.ស.ម.ក ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ ព្រមទាំងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទស្សនាគេហទំព័រ www.cchrcambodia.org។

## ចម្ងល់ និងមតិចូលរួម

ប្រសិនបើលោកអ្នកមានសំណួរ ឬចង់បានព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ ឬប្រសិនបើលោកអ្នកចង់ផ្តល់យោបល់តប សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន info@cchrcambodia.org។

របាយការណ៍នេះ និងការបោះពុម្ពផ្សាយផ្សេងៗរបស់ ម.ស.ម.ក អាចស្វែងរកបានតាមរយៈ www.cchrcambodia.org និងក៏អាចស្វែងរកបានផងដែរនៅលើគេហទំព័រសិទ្ធិមនុស្សកម្ពុជាដែលបង្ហោះដោយ ម.ស.ម.ក តាមរយៈ www.sithi.org។

ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖

ផ្ទះលេខ ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០១

ទូរសារ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០២

BY NC SA

# មាតិកា

**តារាងតួលេខ**.......................................................................................................iii
**បញ្ជីអក្សរកាត់**......................................................................................................iv
**ខ្លឹមសារសង្ខេប** ......................................................................................................vi
១. សេចក្តីផ្តើម................................................................................................ ១
១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌.........................................................................១
១.១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមច្បាប់អន្តរជាតិ .........................................១
១.១.២. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមច្បាប់ជាតិ............................................... ២
១.២. គោលបំណង វិសាលភាព និង វិធីសាស្ត្រ .......................................................................៥
២. ទិន្នន័យ និងការវាយតម្លៃ ................................................................................ ៩
២.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព ............................................ ១១
២.១.១. ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល......................................... ១១
២.១.២. ការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ....................................១២
២.១.៣. សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ............................................. ១៤
២.១.៤. សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី.................................១៧
២.១.៥. សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ...............................................២០
២.២. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌កំពុងប្រឈមនឹងការរំលោភបំពាន..........................២១
២.២.១. សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ...........................................................២១
២.២.២. សិទ្ធិមានវត្តមាននៅពេលសវនាការ និងមានមេធាវី................................................... ២៣
២.២.៣. ការគោរពចំពោះការសន្មតទុកជាមុនថាគ្មានទោស .....................................................២៨
២.២.៤. សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព.......................................................៣២
២.២.៥. សិទ្ធិបង្ហាញពីការការពារខ្លួន (សិទ្ធិបង្ហាញភស្តុតាង) ................................................ ៣៦

២.២.៦. សិទ្ធិទទួលបានសេចក្តីសម្រេចមានសម្អាងហេតុ ........................................................ ៣៩

២.២.៧. សវនាការទាក់ទងនឹងអនីតិជន ........................................................................................៤០

**៣. ការវិវឌ្ឍនៃការការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ឆ្នាំ ២០១៤ ដល់ ២០១៧...៤៩**

៣.១.មានការកើនឡើងគួរជាទីកត់សម្គាល់នូវការគោរពចំពោះសិទ្ធិសំខាន់ៗ....................................៥១

៣.២.ការថយចុះនូវការគោរពចំពោះសិទ្ធិជាមូលដ្ឋានសំខាន់ៗ.......................................................៥៣

៣.៣.សិទ្ធិនៅស្ងៀម និងសិទ្ធិទទួលបានសេចក្តីសម្រេចមានសម្អាងហេតុបន្តរងការបំពាន.................៥៦

៣.៤.សេចក្តីសន្និដ្ឋានអំពីនិន្នាការសំខាន់ៗឆ្នាំ ២០១៤-២០១៥ ដល់ ២០១៦-២០១៧...................៥៦

**៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ...................................................................................៥៨**

៤.១. អនុសាសន៍ទូទៅ ...................................................................................................................៦០

៤.២. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានសវនាការជាសាធារណៈ..............................................៦០

៤.៣. អនុសាសន៍ទាក់ទងនឹងសិទ្ធិមានវត្តមាននៅពេលសវនាការ និងមានមេធាវី ..............................៦១

៤.៤. អនុសាសន៍ទាក់ទងនឹងការសន្មតទុកជាមុនថាគ្មានទោស ......................................................៦១

៤.៥. អនុសាសន៍ទាក់ទងនឹងការការពារខ្លួនពីការឆ្លើយដាក់បន្ទុកបទល្មើសលើខ្លួនឯង ........................៦២

៤.៦. អនុសាសន៍ទាក់ទងជាមួយសិទ្ធិបង្ហាញភស្តុតាង ....................................................................៦២

៤.៧. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានសេចក្តីសម្រេចមានសម្អាងហេតុ................................. ៦៣

៤.៨. អនុសាសន៍ដើម្បីការពារអនីតិជនក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌ ................................................. ៦៣

**៥. ឯកសារគន្ថនិទ្ទេស......................................................................................................៦៥**

**៦. ឧបសម្ព័ន្ធ ..................................................................................................................... ៧១**

# តារាងតួលេខ


តួលេខទី១(ក)៖ សវនាការឧទ្ធរណ៍ដែលបានសង្កេត-បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ.............៩

តួលេខទី ១(ខ)៖ ភាគីធ្វើបណ្ដឹងឧទ្ធរណ៍..........................................................................១០

តួលេខទី ២៖ ការហាមឃាត់ចំពោះការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល.................. ១២

តួលេខទី ៣៖ ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ...........១៤

តួលេខទី ៤(ក)៖ សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់៖ ទិដ្ឋភាពទូទៅ........១៦

តួលេខទី ៤(ខ)៖ សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់៖ ទិដ្ឋភាពលម្អិត.......១៦

តួលេខទី ៥៖ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការការពារក្ដី................១៩

តួលេខទី ៦៖ សិទ្ធិទទួលបានការប្រកាសសេចក្ដីសម្រេចជាសាធារណៈ ................................ ២០

តួលេខទី ៧៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ..................................................២២

តួលេខទី ៨៖ សិទ្ធិមានវត្តមាននៅពេលសវនាការ និងមានមេធាវី......................................... ២៦

តួលេខទី ៩៖ ការពន្យល់ប្រាប់សិទ្ធិ ................................................................................២៧

តួលេខទី ១០៖ សិទ្ធិនៅស្ងៀម........................................................................................ ២៩

តួលេខទី ១១៖ ការសន្មតទុកជាមុនថាគ្មានទោស ............................................................ ៣០

តួលេខទី ១២៖ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព......................................... ៣៤

តួលេខទី ១៣៖ ទិដ្ឋភាពទូទៅនៃសាលដីការបស់សាលាឧទ្ធរណ៍ ..........................................៤០

តួលេខទី ១៤(ក)៖ ការឃុំខ្លួនអនីតិជនមុនការជំនុំជម្រះ....................................................៤៦

តួលេខទី ១៤(ខ)៖ ការការពារឯកជនភាពរបស់អនីតិជន ................................................. ៤៧

# បញ្ជីអក្សរកាត់

| | |
|---|---|
| គណៈមេធាវី | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| កម្ពុជា | ព្រះរាជាណាចក្រកម្ពុជា |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| ក្រមនីតិវិធិព្រហ្មទណ្ឌ | ក្រមនីតិវិធិព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា |
| តារាងសង្កេតការណ៍ | តារាងសង្កេតការណ៍ប្រើដោយអ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ដើម្បីកត់ត្រាទិន្នន័យសវនាការនៅពេលសង្កេតការណ៍ |
| ការណែនាំអំពីតារាងសង្កេតការណ៍ | ឯកសារណែនាំលម្អិតដើម្បីជួយដល់អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ឱ្យមានការយល់ច្បាស់លាស់ចំពោះសំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍ |
| ក្រមសីលធម៌ | ឯកសារកំណត់អំពីកាតព្វកិច្ចនានានៃការមិនជ្រៀតជ្រែក គោលបំណងមិនលម្អៀង និងការសម្ងាត់ដែលចងជាកាតព្វកិច្ចដល់អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| សាលាឧទ្ធរណ៍ | សាលាឧទ្ធរណ៍រាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា |
| អ.ស.ក | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| ប្រព័ន្ធគ្រប់គ្រងទិន្នន័យ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដែលអ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក រក្សាទុកទិន្នន័យសវនាការ ដែលបានកត់ត្រានៅលើតារាងសង្កេតការណ៍ |
| ECHR | តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប |
| HRC | គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ |
| ក.អ.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| មិនដឹង | ព័ត៌មានដែលមិនទទួលបាន ឬមិនបានតាមដានបន្ត |
| ក្រ.ម | ក្រសួងមហាផ្ទៃ |
| ក្រ.យ | ក្រសួងយុត្តិធម៌ |
| ក្រ.ស.ក | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| មិនពាក់ព័ន្ធ | ទិន្នន័យមិនពាក់ព័ន្ធ |
| អ.ម.រ | អង្គការមិនមែនរដ្ឋាភិបាល |
| ក.ស.ម.រ.ប | ការិយាល័យទទួលបន្ទុកសិទ្ធិមនុស្ស និងវិទ្យាស្ថានប្រជាធិបតេយ្យ |

| | |
|---|---|
| ការិយាល័យឧត្តមស្នងការ | ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ |
| អ.ស.ស.អ | អង្គការសម្រាប់សន្តិសុខ និងសហប្រតិបត្តិការនៅអឺរ៉ុប |
| ក្រមព្រហ្មទណ្ឌ | ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា |
| គម្រោង | គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក |
| របាយការណ៍ | របាយការណ៍ប្រចាំឆ្នាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា |
| អំឡុងពេលធ្វើរបាយការណ៍ | ចាប់ពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០១៦ ដល់ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៧ |
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា |
| យុទ្ធសាស្ត្រ | យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៃរាជរដ្ឋាភិបាលកម្ពុជា |
| អ្នកសង្កេតការណ៍ | អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក |
| ស.ស.ស.ម | សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស |
| អ.ស.ប | អង្គការសហប្រជាជាតិ |
| យូនីសេហ្វ | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |
| អ៊ុនតាក់ | អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា |
| ច្បាប់អ៊ុនតាក់ | បទប្បញ្ញត្តិស្តីពីស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលឆ្នាំ ១៩៩២ |

# ខ្លឹមសារសង្ខេប

មុខងារចម្បងរបស់តុលាការដើរតួសំខាន់ក្នុងការការពារ និងអនុវត្តសិទ្ធិមនុស្ស ព្រមទាំងកសាងនូវនីតិរដ្ឋ ដែលជាបញ្ហាព្រួយបារម្ភដ៏សំខាន់មួយនៅកម្ពុជា។ ទោះបីជាមានភាពប្រសើរឡើងខ្លះក្នុងការប្រកាន់ខ្ជាប់នីតិវិធីមួយចំនួនដែលកំណត់អំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងតុលាការកម្ពុជាយ៉ាងណាក្តី ក៏បញ្ហាគួរឱ្យព្រួយបារម្ភមួយចំនួនទៀតនៅតែកើតមាន។ ក្នុងនោះបញ្ហាចម្បងមួយដែលប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា គឺទាក់ទងនឹងបញ្ញត្តិមួយចំនួននៃច្បាប់គោលទាំងបីស្តីពីតុលាការដែលជះឥទ្ធិពលមិនល្អលើឯករាជ្យភាពរបស់ប្រព័ន្ធយុត្តិធម៌ និងជាទូទៅដល់ការបែងចែកអំណាចអោយដាច់ពីគ្នា[1] ដែលជាហេតុបង្កឱ្យប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះ ដោយតុលាការមិនលម្អៀង និងឯករាជ្យ។

ការសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក បានប្រមូលទិន្នន័យមកពីការសង្កេតការណ៍សវនាការព្រហ្មទណ្ឌចំនួន ៣៤០ នៅសាលាឧទ្ធរណ៍ ចាប់ពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០១៦ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០១៧ ("អំឡុងពេលធ្វើរបាយការណ៍") ដើម្បីវាយតម្លៃអំពីការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់សាលាឧទ្ធរណ៍ ដូចដែលបានកំណត់នៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ របាយការណ៍នេះបង្ហាញ និងវិភាគទៅលើទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេលធ្វើរបាយការណ៍។

គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក ("គម្រោង") បានរកឃើញថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗមួយចំនួន ត្រូវបានធានានៅចំពោះមុខសាលាឧទ្ធរណ៍ក្នុងអំឡុងពេលពីខែវិច្ឆិកា ឆ្នាំ២០១៦ ដល់ខែតុលា ឆ្នាំ២០១៧ រួមមានដូចជា សិទ្ធិទទួលបានការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល និងការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្តី និងសិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ។ ប៉ុន្តែយ៉ាងណាក៏ដោយ ការសង្កេតការណ៍ក៏បានរកឃើញកង្វះការអនុលោមតាមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋានមួយចំនួនផងដែរ។ ចំណុចគួរឱ្យកត់សម្គាល់បំផុតនោះគឺ ការគោរពចំពោះការសន្មតទុកជាមុនថាគ្មានទោសពុំត្រូវបានគោរពយ៉ាងពេញលេញនោះទេ ហើយពុំមានការយកចិត្តទុកដាក់ឲ្យបានគ្រប់ជ្រុងជ្រោយចំពោះការលើកឡើងថាការសារភាពដែលជារឿយៗតែងយកជាមូលដ្ឋានសម្រាប់ការផ្តន្ទាទោស ត្រូវបានធ្វើឡើងតាមរយៈការបង្ខិតបង្ខំ ឬអំពើ ហិង្សា។ សិទ្ធិមានវត្តមាននៅពេលសវនាការ និងមានមេធាវី ពុំត្រូវបានគោរពឲ្យបានជានិច្ចជាកាល

[1] សេចក្តីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ដោយសាស្ត្រាចារ្យ សូរិយា ប្រាសាទ ស៊ូប៊ែឌី នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៤, https://bit.ly/2HVnO6R, ដែលសំដៅដល់ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

នោះឡើយ ហើយសិទ្ធិបង្ហាញភស្តុតាង ជារឿយៗត្រូវបានអនុវត្តក្នុងលក្ខណៈរឹតត្បិតយ៉ាងខ្លាំង។ បន្ថែមលើសពីនេះទៀត ក្នុងករណីភាគច្រើនលើសលុបពុំមានការផ្តល់សម្អាងហេតុសម្រាប់សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ឡើយ ដោយតុលាការគ្រាន់តែបញ្ជាក់ថា សេចក្តីសម្រេចរបស់សាលាដំបូង ត្រូវបានរក្សាទុកដដែល ឬត្រូវបានច្រានចោលដោយពុំមានពន្យល់ប្រាប់មូលហេតុឲ្យបានច្បាស់លាស់។ ជាចុងក្រោយសិទ្ធិរបស់ជនជាប់ចោទជាអនីតិជនដែលត្រូវបានការពារ ជាពិសេសនៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់កម្ពុជា ជារឿយៗពុំបានយកចិត្តទុកដាក់ឲ្យ គ្រប់គ្រាន់នៅឡើយទេ។ ហេតុនេះ ការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅតែត្រូវការការកែលម្អជាចាំបាច់។

របាយការណ៍នេះ មានរចនាសម្ព័ន្ធដូចតទៅ៖

**១. សេចក្តីផ្តើម៖** ផ្តល់នូវទិដ្ឋភាពសង្ខេបអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលពាក់ព័ន្ធមុននឹងឈានដល់ការកំណត់វិសាលភាព វិធីសាស្ត្រ និងគោលបំណងនៃរបាយការណ៍នេះ។

**២. ទិន្នន័យ និងការវាយតម្លៃ៖** កំណត់ថាតើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ណាខ្លះដែលត្រូវបានគោរព និងសិទ្ធិណាខ្លះដែលមិនទទួលបានការគោរពគ្រប់គ្រាន់នៅសាលាឧទ្ធរណ៍ តាមរយៈការវិភាគលើទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេលការសង្កេតការណ៍របស់ ម.ស.ម.ក។

**៣. ការវិវឌ្ឍនៃការការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅចន្លោះឆ្នាំ ២០១៤ ដល់ ២០១៧៖** ផ្នែកនេះគូសបញ្ជាក់អំពីនិន្នាការសំខាន់ៗទាក់ទងជាមួយការគោរពបទដ្ឋានអន្តរជាតិនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់សាលាឧទ្ធរណ៍។ ផ្នែកនេះ បង្ហាញការប្រៀបធៀបនៃទិន្នន័យប្រមូលបានក្នុងអំឡុងពេលធ្វើរបាយការណ៍ (ថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០១៦ ដល់ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៧ និងចាប់ពីពេលនេះទៅហៅថា "២០១៦ -២០១៧") ជាមួយទិន្នន័យប្រមូលបានតាមរយៈការសង្កេតការណ៍សវនាការប្រចាំថ្ងៃរបស់ ម.ស.ម.ក ដែលធ្វើឡើងនៅក្នុងសាលាឧទ្ធរណ៍ចន្លោះពីថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០១៤ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៥ ("២០១៤-២០១៥")។

**៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖** រួមមានអនុសាសន៍ដាក់ជូនចំពោះអង្គភាព និងស្ថាប័នពាក់ព័ន្ធផ្សេងៗក្នុងវិស័យយុត្តិធម៌ រួមទាំងរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ក្រសួងយុត្តិធម៌ ("ក.យ") អាជ្ញាធរអនុវត្តច្បាប់ អាជ្ញាធរពន្ធនាគារ ក៏ដូចជាអង្គភាពមិនមែនរដ្ឋាភិបាលដែលជាប់ពាក់ព័ន្ធនឹងលទ្ធផលដែលបានរកឃើញនៅក្នុងរបាយការណ៍នេះ។

ម.ស.ម.ក សង្ឃឹមថា ទិន្នន័យ ការវិភាគ និងអនុសាសន៍ដែលមាននៅក្នុងរបាយការណ៍នេះនឹងជួយសម្រួលដល់ការបង្កើនការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ម.ស.ម.ក សង្ឃឹមថារបាយ

ការណ៍នេះនឹងជួយគាំទ្រដល់អ្នកទាំងឡាយដែលធ្វើការដើម្បីការធានាឱ្យប្រព័ន្ធយុត្តិធម៌នៅកម្ពុជាមានយុត្តិធម៌ និងសមភាព សម្រាប់ជនគ្រប់រូប។

# ១. សេចក្តីផ្តើម

## ១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាធាតុផ្សំដ៏សំខាន់នៃនីតិរដ្ឋ និងការគ្រប់គ្រងយុត្តិធម៌ដ៏ត្រឹមត្រូវ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាសិទ្ធិជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកលនៅក្នុងច្បាប់អន្តរជាតិ ដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ("ស.ស.ស.ម") និងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក៏ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ព្រមទាំងតាមរយៈបទប្បញ្ញត្តិជាក់លាក់មួយចំនួននៃច្បាប់ជាតិផងដែរ។

### ១.១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមច្បាប់អន្តរជាតិ

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ជាផ្នែកដ៏សំខាន់នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ហើយសិទ្ធិនេះ ផ្តល់ឱ្យបុគ្គលគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយ ត្រូវទទួលបាននូវការគោរពដោយយុត្តិធម៌ និងស្មើភាពគ្នា នៅខណៈដែលរដ្ឋកំណត់អំពីពិរុទ្ធភាព ឬភាពគ្មានទោសរបស់អ្នកទាំងនោះ។ ការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ឱ្យបានត្រឹមត្រូវ នឹងការពារដល់សិទ្ធិរបស់ជនជាប់ចោទ និងជនរងគ្រោះ ព្រមទាំងធានាការផ្តល់នូវយុត្តិធម៌ដ៏ត្រឹមត្រូវផងដែរ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមផ្សំដោយសិទ្ធិជាក់លាក់ផ្សេងមួយចំនួន ហើយក្តោបនៅក្នុងនីតិវិធីច្បាប់ទាំងមូល ដោយគិតចាប់ពីដំណាក់កាលដំបូងនៃការឃាត់ខ្លួនជនសង្ស័យ រហូតដល់ការប្តឹងតវ៉ាត្រូវបានបញ្ចប់។

> **មាត្រា ១០ នៃ ស.ស.ស.ម**
>
> មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាពេញលេញ សុំឱ្យតុលាការឯករាជ្យ និងមិនលម្អៀង ពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចបានលើសិទ្ធិ កាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌ។

ស.ស.ស.ម[2] និង ក.អ.ស.ព.ន[3] ធានាសិទ្ធិទទួលបានសវនាការយុត្តិធម៌ និងជាសាធារណៈ ដោយសាលាជម្រះក្តីឯករាជ្យ និងឥតលម្អៀង។ ក.អ.ស.ព.ន បង្កើតបន្ថែមទៀតនូវគោលការណ៍នៃសវនាការយុត្តិធម៌ ដោយមិនកម្រិតត្រឹមតែសិទ្ធិ និងគោលការណ៍ ដូច

[2] មាត្រា ១០ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សរបស់អង្គមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៤៨, http://bit.ly/2I8Pl1d ។

[3] មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់អង្គមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦, http://bit.ly/2oMC3j7។

រៀបរាប់នេះទេ៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ[4] សិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោស[5] សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលមិនសមហេតុផល[6] សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់[7] សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី[8] សិទ្ធិមានមេធាវី[9] សិទ្ធិមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង (មិនសារភាពទោសកំហុសដោយសារតែការបង្ខិតបង្ខំ ឬការលួងលោម)[10] និងសិទ្ធិប្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់លើផ្នែកអង្គហេតុ និងអង្គច្បាប់[11]។

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើ ក.អ.ស.ព.ន នៅឆ្នាំ ១៩៩២ ហើយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញបានដាក់បញ្ចូលកាតព្វកិច្ចគោរពសិទ្ធិមនុស្សអន្តរជាតិទៅក្នុងច្បាប់ជាតិ។[12] បន្ថែមលើនេះទៀត បទដ្ឋានគតិយុត្តិស្តីពីសិទ្ធិមនុស្សអន្តរជាតិនានា រួមទាំងបទប្បញ្ញត្តិនៃ ក.អ.ស.ព.ន មានអានុភាពអនុវត្តដោយផ្ទាល់នៅក្នុងតុលាការកម្ពុជា ដូចដែលបានបញ្ជាក់បន្ថែមតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកាលពីឆ្នាំ ២០០៧។[13]

### ១.១.២. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមច្បាប់ជាតិ

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានការពារនៅកម្ពុជា តាមរយៈបទប្បញ្ញត្តិជាក់លាក់ និងទូទៅមួយចំនួន ដែលមានចែងនៅក្នុងលិខិតូបករណ៍មួយចំនួន។ រដ្ឋធម្មនុញ្ញបញ្ញត្តពីក្របខ័ណ្ឌជាមូលដ្ឋានចំពោះការជំនុំជម្រះដោយយុត្តិធម៌។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកំណត់អំពីសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរ និងការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដោយធានាថា៖

- មិនត្រូវឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។
- ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តតាមបញ្ញត្តិច្បាប់។

---

[4] មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។
[5] មាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។
[6] មាត្រា ១៤(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។
[7] មាត្រា ១៤(៣)(ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។
[8] មាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។
[9] មាត្រា ១៤(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។
[10] មាត្រា ១៤(៣)(ឆ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។
[11] មាត្រា ១៤(៥) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។
[12] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ៖ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ" http://bit.ly/2HZZUnn។
[13] សេចក្តីប្រកាសលេខ ០៩២/០០៣/២០០៧ របស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៧។

- ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់។
- ការទទួលសារភាព ដែលបានមកតាមរយៈការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។
- វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។
- ជនជាប់ចោទណាក៏ដោយ ត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។
- ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។

ម្យ៉ាងវិញទៀត មាត្រា ៥១ មាត្រា ១២៨ មាត្រា ១៣០ មាត្រា ១៣២ នៃរដ្ឋធម្មនុញ្ញបានបញ្ញត្តអំពីការបែងចែកអំណាច និងឯករាជ្យភាពរបស់តុលាការដែលជានាដោយព្រះមហាក្សត្រផងដែរ។

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ") ត្រូវបានអនុម័តក្នុងឆ្នាំ ២០០៧[14] ចែងយ៉ាងលម្អិតអំពីនីតិវិធីដែលត្រូវអនុវត្តលើជនសង្ស័យ។ ក្រមនេះបានកំណត់អំពីតួនាទី និងការទទួលខុសត្រូវរបស់ចៅក្រម ព្រះរាជអាជ្ញា និងភាគីវេងការចោទប្រកាន់ ដោយគិតចាប់ពីការផ្តួចផ្តើមនៃការស៊ើបអង្កេតបឋម រហូតដល់ពេលចាប់ខ្លួននៅក្នុងនីតិវិធីព្រហ្មទណ្ឌទាំងមូល រហូតដល់ការបញ្ចប់បណ្តឹងតវ៉ាជាស្ថាពរ។

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមព្រហ្មទណ្ឌ") ដែលត្រូវបានប្រកាសឱ្យប្រើក្នុងឆ្នាំ ២០០៩ និងបានចូលជាធរមានកាលពីខែធ្នូ ឆ្នាំ ២០១០ ចែងអំពីចំណាត់ថ្នាក់នៃបទល្មើស គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍នៃការផ្តន្ទាទោស។[15]

បន្ថែមលើនេះទៀត ច្បាប់ជាមូលដ្ឋានទាំងបីពាក់ព័ន្ធជាមួយប្រព័ន្ធយុត្តិធម៌ រួមមានច្បាប់ស្តីពីការរៀបចំអង្គការតុលាការ[16] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា[17] និងច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[18] ដែលបានអនុម័តក្នុងឆ្នាំ ២០១៤ មានគោលបំណងធានាឯករាជ្យភាពរបស់អំណាចតុលាការ និងដើម្បីការពារសិទ្ធិ និងសេរីភាពរបស់ពលរដ្ឋកម្ពុជា។

---

[14] ក្រមនីតិវិធិព្រហ្មទណ្ឌជំនួសឱ្យផ្នែកមួយចំនួននៃបទប្បញ្ញត្តិទាក់ទិននឹងតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ឆ្នាំ ១៩៩២ ("ច្បាប់អ៊ុនតាក់")។ អាចស្វែងរកបាននៅលើគេហទំព័រ៖ http://bit.ly/2C9dRwR។

[15] ក្រមព្រហ្មទណ្ឌអាចស្វែងរកបាននៅលើគេហទំព័រ៖ http://bit.ly/2BD6cpf។

[16] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការអាចស្វែងរកបានតាមរយៈ៖ http://bit.ly/2I3IV3l ។

[17] ច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា អាចស្វែងរកបានតាមរយៈ៖ http://bit.ly/2Feppzo ។

[18] ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចស្វែងរកបានតាមរយៈ៖ http://bit.ly/2Fd3ZTj ។

ជាចុងក្រោយច្បាប់ស្តីពីយុត្តិធម៌អនីតិជនអនុម័តក្នុងខែតុលា ឆ្នាំ ២០១៦ ហើយបានចូលជាធរមានក្នុងខែមករា ឆ្នាំ ២០១៧[19] បានចែងអំពីបទដ្ឋានគតិយុត្តិ និងនីតិវិធីពាក់ព័ន្ធជាមួយអនីតិជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។[20] ច្បាប់នេះ នឹងត្រូវអនុម័តយ៉ាងតឹងរឹង ដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជន។

កាលពីខែមិថុនា ឆ្នាំ ២០០៣ គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក៏បានអនុម័តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ("យុទ្ធសាស្ត្រ")។[21] យុទ្ធសាស្ត្រនេះ កំណត់អំពីគោលការណ៍ណែនាំចំនួន ៤ ដែលមានប្រភពចេញពីរដ្ឋធម្មនុញ្ញ ដើម្បីជាមគ្គុទ្ទេសក៍ការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌រួមមាន៖ សិទ្ធិរបស់បុគ្គល គោលការណ៍លទ្ធិប្រជាធិបតេយ្យសេរី ការបែងចែកអំណាច និងនីតិរដ្ឋ។ យុទ្ធសាស្ត្រនេះក៏កំណត់អំពីកម្មវត្ថុជាយុទ្ធសាស្ត្រ[22] ចំនួន ៧ ដែលបង្កើតបានជាមូលដ្ឋានគ្រឹះនៃផែនការសកម្មភាពកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។[23] កម្មវត្ថុទីមួយនៃកម្មវត្ថុជាយុទ្ធសាស្ត្រទាំងប្រាំពីរនេះគឺ ដើម្បីកែលម្អការការពារសិទ្ធិជាមូលដ្ឋាន និងសេរីភាព។

បន្ថែមលើនេះទៀត ក្នុងខែឧសភា ឆ្នាំ ២០១៧ លេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់ក្រសួងយុត្តិធម៌ បានផ្តួចផ្តើមគំនិតឱ្យមានយុទ្ធនាការ ១០០ ថ្ងៃ ដើម្បីវាយតម្លៃលទ្ធផលការងារ និងប្រសិទ្ធភាពរបស់តុលាការ។[24] យុទ្ធនាការនេះ មានគោលបំណងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រ និងកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីធ្វើឱ្យប្រព័ន្ធយុត្តិធម៌កាន់តែមានលក្ខណៈគួរជាទីជឿជាក់ច្បាស់ និង

---

[19] ច្បាប់ពីយុត្តិធម៌អនីតិជន៖ http://bit.ly/2BfhuPv ។

[20] សូមមើលផងដែរ កម្រងសំណួរចម្លើយរបស់អង្គការ UNICEF អំពីច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលទើបនឹងអនុម័តថ្មីក្នុងប្រទេសកម្ពុជា ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០១៦ អាចស្វែងរកបានតាមរយៈ៖ http://bit.ly/2r6JvZO។

[21] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលត្រូវបានអនុម័តដោយរដ្ឋាភិបាលកម្ពុជានៅក្នុងកិច្ចប្រជុំពេញអង្គនៅថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០០៣ សូមមើល៖ http://bit.ly/2EvRqSd។

[22] កម្មវត្ថុទាំង ៧ នោះមាន៖ ១) កាកែលម្អការការពារសិទ្ធិជាមូលដ្ឋាន និងសេរីភាព ២) ទំនើបកម្មក្របខ័ណ្ឌការងារផ្នែកច្បាប់ ៣) ការផ្តល់លទ្ធភាពកាន់តែប្រសើរដើម្បីទទួលបានព័ត៌មានផ្នែកច្បាប់ និងយុត្តិធម៌ ៤) ការពង្រឹងគុណភាពដំណើរការផ្នែកច្បាប់ និងសេវាពាក់ព័ន្ធ ៥) ការពង្រឹងសេវាយុត្តិធម៌ ពោលគឺអំណាចរបស់អង្គតុលាការ និងសេវាអយ្យការ ៦) ការដាក់ឱ្យមានយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ៧) ការពង្រឹងស្ថាប័នក្នុងវិស័យច្បាប់ និងយុត្តិធម៌ ដើម្បីបំពេញតាមអណត្តិរបស់ខ្លួន។ សូមមើល ក្រុមប្រឹក្សាភិបាលស្តារនីតិសម្បទា និងអភិវឌ្ឍកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ឯកសារគោលជំហរ លទ្ធផលការងារគោលនយោបាយរបស់រដ្ឋាភិបាល វាក្យខ័ណ្ឌ ១៥-២៤ អាចស្វែងរកបានតាមរយៈ៖ http://bit.ly/2EvRqSd។

[23] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ផែនការសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលត្រូវបានអនុម័តដោយរដ្ឋាភិបាលកម្ពុជានៅក្នុងកិច្ចប្រជុំពេញអង្គនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៥, សូមមើលផងដែររាជរដ្ឋាភិបាលកម្ពុជា , ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិឆ្នាំ ២០១៤-២០១៨ ទំព័រ ៩-១២ វាក្យខ័ណ្ឌ ២.១២ ដល់ ២.២៣ អាចស្វែងរកបានតាមរយៈ៖ http://bit.ly/2pEnsaX។

[24] សេចក្តីជូនដំណឹងស្តីពីយុទ្ធនាការ ១០០ ថ្ងៃដើម្បីវាយតម្លៃលទ្ធផលការងារ និងប្រសិទ្ធិផលរបស់តុលាការ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៧ ចេញដោយលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការកំណែទម្រង់ផ្នែកច្បាប់ និងយុត្តិធម៌នៃក្រសួងយុត្តិធម៌៖ http://bit.ly/2FBc5Wi។

អាចអនុវត្តបាន។ គោលបំណងរបស់យុទ្ធនាការនេះ ក៏ដើម្បីកែលម្អកិត្យានុភាពរបស់តុលាការ និងបង្កើនការទុកចិត្ត និងជំនឿជឿជាក់របស់សាធារណជនមកលើប្រព័ន្ធតុលាការផងដែរ។

## ១.២. គោលបំណង វិសាលភាព និងវិធីសាស្ត្រ

គោលបំណងនៃគម្រោង គឺធ្វើការវិភាគលើទិន្នន័យប្រមូលបានពីការសង្កេតការណ៍ប្រចាំថ្ងៃនៅសាលាឧទ្ធរណ៍ ដើម្បីកំណត់អំពីចំណុចខ្លាំង និងចំណុចខ្សោយដែលមាននៅក្នុងប្រព័ន្ធយុត្តិធម៌។ តាមរយៈការទាញចំណាប់អារម្មណ៍ទៅលើបញ្ហានានានៅក្នុងដំណើរការសវនាការ ដែលតម្រូវឱ្យមានការលើកកម្ពស់ឱ្យប្រសើរឡើងថែមទៀត ដូចជាការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាដើម និងការផ្តល់អនុសាសន៍ជាក់លាក់ទៅកាន់ស្ថាប័នយុត្តិធម៌ពាក់ព័ន្ធមួយចំនួន ម.ស.ម.ក មានបំណងចង់ពង្រឹង និងកែទម្រង់ប្រព័ន្ធយុត្តិធម៌ សម្រាប់ជាប្រយោជន៍ចំពោះប្រជាពលរដ្ឋគ្រប់រូប។

ចាប់ពីខែសីហា ឆ្នាំ ២០០៩ ដល់ ខែមករា ឆ្នាំ ២០១៣ គម្រោងបានសង្កេតការណ៍សវនាការនៅសាលាដំបូងរាជធានីភ្នំពេញ សាលាដំបូងខេត្តកណ្តាល សាលាដំបូងខេត្តបន្ទាយមានជ័យ និងសាលាដំបូងខេត្តរតនគិរី ហើយបានចេញផ្សាយរបាយការណ៍ប្រចាំធមាស ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ចំនួន ៦ លើក។[25] នៅខែមករា ឆ្នាំ ២០១៣ គម្រោងបានបញ្ចប់សកម្មភាពសង្កេតការណ៍របស់ខ្លួននៅតាមសាលាដំបូង ដើម្បីផ្តោតលើការសង្កេតការណ៍នៅសាលាឧទ្ធរណ៍វិញម្តង។ គម្រោងបានសម្រេចធ្វើការសង្កេតការណ៍នៅសាលាឧទ្ធរណ៍ ដើម្បីវាយតម្លៃអំពីបទដ្ឋានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានអនុវត្តនៅតុលាការជាន់ខ្ពស់។ គោលដៅ គឺដើម្បីផ្តល់ការវិភាគអំពីនិន្នាការទាក់ទងនឹងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលកើតឡើងនៅសាលាឧទ្ធរណ៍ និងដើម្បីបង្កើតជាក្របខ័ណ្ឌមួយ ដែលអាចដាក់ចេញនូវអនុសាសន៍ ហើយធ្វើឱ្យប្រសើរឡើងក្នុងការអនុវត្ត។

គម្រោងផ្តោតទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗមួយចំនួន។ ដើម្បីកំណត់ថាតើសិទ្ធិណាខ្លះដែលត្រូវពិចារណា ម.ស.ម.ក ពឹងផ្អែកលើប្រភពពីខាងក្រៅដូចជារបាយការណ៍ និងការសិក្សាស្រាវជ្រាវផ្សេងៗអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា និងអំពីប្រព័ន្ធយុត្តិធម៌កម្ពុជា។ លើសពីនេះទៀត ការសង្កេតការណ៍នៅសាលាឧទ្ធរណ៍នាំឱ្យ ម.ស.ម.ក ផ្តោតលើធាតុផ្សំជាក់លាក់មួយចំនួនផ្សេងទៀតនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មានលក្ខណៈខុសប្លែកគ្នាពីអ្វីដែល ម.ស.ម.ក បានអនុវត្តសកម្មភាពសង្កេតការណ៍របស់ខ្លួននៅឯសាលាដំបូង។

---

25 របាយការណ៍ប្រចាំធមាសលើកទី ៦ ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជាដែលអាចស្វែងរកបានតាមរយៈ៖ http://bit.ly/M7mkET។

សិទ្ធិខាងក្រោមត្រូវបានជ្រើសរើសសម្រាប់គោលបំណងនៃការសង្កេតការណ៍៖

- សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ
- សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់
- សិទ្ធិទទួលបានការពន្យល់ប្រាប់សិទ្ធិដល់ជនជាប់ចោទ
- សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការការពារក្តី
- សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ
- សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស
- សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព
- សិទ្ធិបង្ហាញភស្តុតាង (រួមទាំងសិទ្ធិហៅ និងសាកសួរសាក្សី)
- សិទ្ធិទទួលបាននូវការប្រកាសសេចក្តីសម្រេចជាសាធារណៈ និងមានសម្អាងហេតុច្បាស់លាស់
- ការហាមឃាត់ប្រឆាំងទៅនឹងការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ (ត្រូវបានជំនុំជម្រះចំពោះបទល្មើស ដែលអំពើនោះមិនមែនជាបទល្មើសក្នុងពេលដែលសកម្មភាពនោះត្រូវបានប្រព្រឹត្ត)
- ការហាមឃាត់ចំពោះការផ្តន្ទាទោសពីរដងចំពោះបទល្មើសដដែល និង
- សិទ្ធិជាក់លាក់សម្រាប់អនីតិជន។

អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក បានចូលរួមសង្កេតការណ៍សវនាការព្រហ្មទណ្ឌនៅសាលាឧទ្ធរណ៍ជារៀងរាល់ថ្ងៃធ្វើការ។ ដើម្បីឱ្យការកត់ត្រាទិន្នន័យពាក់ព័ន្ធនឹងការជំនុំជម្រះឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល ម.ស.ម.ក បានបង្កើតតារាងសង្កេតការណ៍សវនាការ ("តារាងសង្កេតការណ៍") សម្រាប់ប្រើប្រាស់នៅសាលាឧទ្ធរណ៍[26]។ តារាងសង្កេតការណ៍នេះ ត្រូវបានបង្កើតឡើងស្របតាមបរិបទរបស់គម្រោង និងមានជាង ៧០ សំណួរ ដែលឆ្លើយតបទៅនឹង ថាតើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ណាខ្លះ ដែលត្រូវបានគោរពតាមដោយតុលាការ។ ជាកិច្ចប្រឹងប្រែងដើម្បីធានានូវនិរន្តរភាពនៃកិច្ចសហការក្នុងន័យស្ថាបនា ម.ស.ម.ក បានបង្ហាញ និងពន្យល់អំពីតារាងសង្កេតការណ៍ និងសកម្មភាពសង្កេតការណ៍របស់ខ្លួនដល់តំណាងរបស់សាលាឧទ្ធរណ៍។ ម.ស.ម.ក ក៏បានបង្កើតឧបសម្ព័ន្ធចំនួន ១ ទំព័រ ភ្ជាប់ជាមួយនឹងតារាងសង្កេតការណ៍សម្រាប់ប្រើប្រាស់ក្នុងសវនាការដែលជាប់ពាក់ព័ន្ធជនជាប់ចោទជាអនីតិជនផងដែរ។ ដោយពិចារណាឃើញថាតារាងសង្កេតការណ៍មានលក្ខណៈសង្ខេបខ្លី ម.ស.ម.ក បានចងក្រងសេចក្តីណែនាំលម្អិតអំពីការប្រើប្រាស់តារាងសង្កេតការណ៍ ("ការណែនាំអំពីតារាងសង្កេតការណ៍") [27] ដើម្បីផ្តល់ការយល់ដឹងលើមូលដ្ឋានច្បាប់ ព្រមទាំងគោលបំណងនៃសំណួរនីមួយៗ និងធានាឱ្យមានការបកស្រាយស៊ីសង្វាក់គ្នាលើសំណួរនីមួយៗ។ អ្នកសង្កេត

---

[26] តារាងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក។ http://bit.ly/2DOdo3U។

[27] សេចក្តីណែនាំសម្រាប់ការប្រើប្រាស់តារាងសង្កេតការណ៍សវនាការឧទ្ធរណ៍របស់ ម.ស.ម.ក។ http://bit.ly/1fbDZYO។

ករណីក៏ត្រូវបានផ្តល់ជូននូវឯកសារស្តីពីក្របខ័ណ្ឌការងារផ្នែកច្បាប់ គូសបញ្ជាក់អំពីច្បាប់ជាតិ និងអន្តរជាតិពាក់ព័ន្ធ ដើម្បីគាំទ្រដល់សំណួរនីមួយៗ នៅក្នុងតារាងសង្កេតការណ៍។ ម.ស.ម.ក ផ្តោតការយកចិត្តទុកដាក់ជាពិសេសលើចំណុចស្តីពីសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍[28] គឺក្តោបទាំងសិទ្ធិបានទទួលការពិនិត្យឡើងវិញទាំងស្រុងលើសំណុំរឿងផងដែរ។ យើងអាចនិយាយម្យ៉ាងទៀតថា ការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ ចាំបាច់ត្រូវរួមមានទិដ្ឋភាពផ្នែកច្បាប់ និងទិដ្ឋភាពផ្នែកសម្ភារនៃសេចក្តីសម្រេចឱ្យមានទោស និងការជំនុំជម្រះរបស់ជននោះ។[29] ដោយហេតុនេះ ការពិនិត្យឡើងវិញចាំបាច់ត្រូវផ្តល់ "ការវាយតម្លៃពេញលេញលើភស្តុតាង និងដំណើរការនៃការជំនុំជម្រះ"[30]។ ជាចុងក្រោយ ម.ស.ម.ក ប្តេជ្ញាចិត្តចំពោះគោលការណ៍អន្តរជាតិដែលត្រូវអនុវត្ត ដើម្បីសង្កេតការណ៍សវនាការ[31] ហើយបានបង្កើតឱ្យមានជាក្រមសីលធម៌ ("ក្រមសីលធម៌") សម្រាប់អ្នកសង្កេតការណ៍សវនាការរបស់ខ្លួន។[32] ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍ គូសបញ្ជាក់ពីកាតព្វកិច្ចមិនជ្រៀតជ្រែក ភាពមិនលម្អៀង និងការរក្សាការសម្ងាត់ ដែលមន្ត្រីសង្កេតការណ៍ត្រូវគោរពតាម។

នៅក្នុងការអនុវត្តសកម្មភាពសង្កេតការណ៍របស់ខ្លួននៅសាលាឧទ្ធរណ៍ ការជំនុំជម្រះជាក់លាក់គឺពុំត្រូវបានផ្តោតជាគោលដៅសំខាន់ៗនោះទេ ផ្ទុយទៅវិញ សវនាការដែលត្រូវសង្កេតការណ៍ត្រូវបានជ្រើសរើសដោយព្រាវ អាស្រ័យលើកាលវិភាគរបស់តុលាការ ដើម្បីធានាថា ដំណើរការនៃការប្រមូលទិន្នន័យនៅតែមិនលម្អៀង និងមានលក្ខណៈតំណាង។ នៅពេលដែលអ្នកសង្កេតការណ៍ចុះទៅធ្វើការសង្កេតសវនាការណាមួយ ព័ត៌មានត្រូវបានកត់ត្រាទុកដោយផ្ទាល់ទៅក្នុងតារាងសង្កេតការណ៍។ ទិន្នន័យដែលប្រមូល គឺកម្រិតនៅត្រឹមតែដំណើរការសវនាការផ្ទាល់ ដោយពុំមានកិច្ចសម្ភាសន៍ ឬកិច្ចពិភាក្សាបន្ថែមទៀតត្រូវបានធ្វើឡើងនោះទេ លើកលែងតែនៅពេលដែលអ្នកសង្កេតការណ៍សវនាការ ខិតខំស្វែងរកព័ត៌មានទាក់ទិនទៅនឹងសាលដីកានៃការជំនុំជម្រះដែលពុំត្រូវបានប្រកាសនៅថ្ងៃសវនាការ តែត្រូវបានលើកទៅប្រកាសនៅកាលបរិច្ឆេទក្រោយៗទៀត។ បន្ទាប់ពី

[28] មាត្រា ១៤(៥) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៣៧៥ នៃក្រមនីតិវិធិព្រហ្មទណ្ឌ។

[29]គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ ៧០១/១៩៩៦ *សំណុំរឿង Gómez ទល់នឹងប្រទេសអេស្ប៉ាញ* ថ្ងៃទី ៦ ខែមេសា ឆ្នាំ ១៩៩៨ នៅក្នុងឯកសាររបស់ អ.ស.ប លេខ *GAOR*, A/55/40 (vol. II), ទំព័រ ១០៩ វាក្យខណ្ឌ ១១.១ http://bit.ly/1bhUzWm។

[30] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ ៦២៣, ៦២៤, ៦២៦, ៦២៧/១៩៩៥, *សំណុំរឿង V. P. Domukovsky et al. ទល់នឹងប្រទេស Georgia*, ចុះថ្ងៃទី ៦ ខែមេសា ឆ្នាំ ១៩៩៨ នៅក្នុងឯកសាររបស់ អ.ស.ប លេខ *GAOR*, A/53/40 (vol. II), ទំព័រ ១១១ វាក្យខណ្ឌ ១៨.១១ http://bit.ly/2mhtaM5។

[31] សូមមើល អង្គការលើកលែងទោសអន្តរជាតិ ឆ្នាំ ១៩៩៨, http://bit.ly/2mn7L4a; គណៈកម្មាធិការមេធាវីដើម្បីសិទ្ធិមនុស្ស តើអ្វីជាការជំនុំជម្រះដោយយុត្តិធម៌៖ គោលការណ៍ណែនាំមូលដ្ឋានសម្រាប់បទដ្ឋានផ្នែកច្បាប់ និងការអនុវត្ត ឆ្នាំ២០០០, http://bit.ly/2CT37SC; អង្គការសម្រាប់សន្តិសុខ និងសហប្រតិបត្តិការនៅអឺរ៉ុប/ ការិយាល័យទទួលបន្ទុកសិទ្ធិមនុស្ស និងវិទ្យាស្ថានប្រជាធិបតេយ្យ៖ ការសង្កេតការណ៍សវនាការ៖ សៀវភៅជំនួយស្មារតីសម្រាប់អ្នកប្រកបវិជ្ជាជីវៈ ឆ្នាំ២០០៨, http://bit.ly/2CVLX77; គណៈកម្មាធិការអ្នកច្បាប់អន្តរជាតិ ការសង្កេតការណ៍សវនាការ ឆ្នាំ ២០០២, http://bit.ly/2EyWzJf.

[32] ក្រមសីលធម៌សង្កេតការណ៍សវនាការរបស់ ម.ស.ម.ក http://bit.ly/1fbE3Yu។

សវនាការនីមួយៗ ទិន្នន័យដែលប្រមូលបានត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ("ប្រព័ន្ធគ្រប់គ្រងទិន្នន័យ")។[33]

ម.ស.ម.ក វិភាគទិន្នន័យសវនាការដែលកត់ត្រាទុកនៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ហើយព្យាយាមកំណត់រកការអនុវត្តវិជ្ជមាន ក៏ដូចជាបញ្ហាគួរឱ្យព្រួយបារម្ភដែលកើតមាននៅសវនាការជំនុំជម្រះនីមួយៗ។ គោលបំណងសំខាន់បំផុតនៃការវិភាគគឺដើម្បីកំណត់ចំណុចខ្លាំង និងចំណុចខ្សោយទាំងឡាយនៅសាលាឧទ្ធរណ៍ និងដើម្បីពិភាក្សាបញ្ហាទាំងអស់នេះជាមួយនឹងតុលាការ ព្រមទាំងដៃគូពាក់ព័ន្ធនឹងវិស័យច្បាប់ផ្សេងទៀតក្នុងន័យបង្កើត និងអនុវត្តវិធីសាស្រ្តមួយចំនួនដើម្បីធ្វើឱ្យប្រសើរឡើងដល់ការការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅតុលាការកម្ពុជា។ នៅខណៈដែលសកម្មភាពសង្កេតការណ៍សវនាការនឹងនៅតែបន្ត ប្រព័ន្ធគ្រប់គ្រងទិន្នន័យនឹងត្រូវប្រើសម្រាប់វិភាគបែបប្រៀបធៀប និងកំណត់អំពីនិន្នាការក្នុងការអនុវត្តរបស់សាលាឧទ្ធរណ៍ វាយតម្លៃអំពីភាពប្រសើរឡើង និងចង្អុលបង្ហាញពីអនុសាសន៍បន្ថែមទៀត។

បន្ទាប់ពីនោះ សេចក្តីព្រាងចុងក្រោយនៃរបាយការណ៍នេះត្រូវបានផ្ញើជូនប្រធានសាលាឧទ្ធរណ៍ ដើម្បីផ្តល់មតិយោបល់ និងអនុសាសន៍ ហើយបន្ទាប់មកក្រុមការងារគម្រោងបានជួបប្រជុំជាមួយសាលាឧទ្ធរណ៍នៅថ្ងៃទី ៥ ខែមេសា ឆ្នាំ២០១៨ ដើម្បីពិភាក្សាអំពីរបើកគំហើញដែលប្រមូលបានពីការសង្កេតការណ៍។ នៅពេលដែលរបាយការណ៍ត្រូវបានបោះពុម្ព បុគ្គលិកគម្រោងស្នើសុំឱ្យមានកិច្ចប្រជុំជាក់លាក់មួយចំនួនជាមួយនឹងតំណាងរបស់សាលាឧទ្ធរណ៍ និងជាមួយអង្គការ អង្គភាព និងស្ថាប័នធ្វើការលើវិស័យយុត្តិធម៌ផ្សេងៗទៀតដែលស្ថាប័នទាំងនោះ អាចដោះស្រាយអនុសាសន៍ដែលបានលើកឡើង។ កិច្ចប្រជុំបែបនេះ ជាមូលដ្ឋានគ្រឹះសម្រាប់ការផ្លាស់ប្តូរគំនិត និងផ្តល់ការយល់ដឹងលម្អិតអំពីបញ្ហាប្រឈមរបស់ស្ថាប័នដែលធ្វើការដើម្បីពង្រឹងប្រព័ន្ធយុត្តិធម៌ និងមានគោលបំណងក្នុងការលើកកម្ពស់ការអនុវត្តអនុសាសន៍ ដែលរបាយការណ៍បានដាក់ចេញ។

[33] ប្រព័ន្ធគ្រប់គ្រងទិន្នន័យសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក http://bit.ly/2BbUOj3។

## ២. ទិន្នន័យ និងការវាយតម្លៃ

ផ្នែកនេះនៃរបាយការណ៍ កំណត់អំពីទិន្នន័យ "ដើម" ដែលកត់ត្រាក្នុងតារាងសង្កេតការណ៍សវនាការ ចំនួន ៣៤០ ដែលបានសង្កេតនៅសាលាឧទ្ធរណ៍ ចាប់ពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៧ ព្រមទាំងវាយតម្លៃទិន្នន័យទាំងនេះ។

### តួលេខទី ១(ក)៖ សវនាការឧទ្ធរណ៍ដែលបានសង្កេត បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ

សំណុំរឿងចំនួន ៣៤០ ត្រូវបានសង្កេតនៅសាលាឧទ្ធរណ៍




តួលេខទី ១(ក) ខាងលើនេះ បង្ហាញអំពីចំនួនសវនាការព្រហ្មទណ្ឌដែលបានសង្កេតដោយអ្នកសង្កេតការណ៍នៅក្នុងអំឡុងពេលធ្វើរបាយការណ៍ និងបែងចែកបទចោទទៅតាមចំណាត់ថ្នាក់នៃបទល្មើសផ្សេងគ្នា។ មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌកំណត់និយមន័យបទឧក្រិដ្ឋថា ជាបទល្មើសទាំងឡាយណាដែលអតិបរិមានៃទោសដាក់ពន្ធនាគារលើសពីរយៈពេលប្រាំឆ្នាំ។ បទមជ្ឈិមត្រូវបានកំណត់និយមន័យនៅក្នុងមាត្រា៤៧ ថាជាបទល្មើសទាំងឡាយណាដែលអតិបរមានៃទោសដាក់ពន្ធនាគារចាប់ពីប្រាំមួយថ្ងៃ និងក្រោម ឬស្មើនឹងប្រាំឆ្នាំ។ យោងតាមមាត្រា ៤៨ បទលហុ គឺជាបទល្មើសដែលផ្តន្ទាទោសអតិបរមាឱ្យជាប់ពន្ធនាគាររយៈពេលប្រាំមួយថ្ងៃ ឬតិចជាងនេះ ឬផ្តន្ទាទោសដោយការផាកពិន័យតែម្យ៉ាងប៉ុណ្ណោះ។[34]

[34] មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌ។

### តួលេខទី ១(ខ)៖ ភាគីធ្វើបណ្ដឹងឧទ្ធរណ៍




* សំដៅលើតំណាងអយ្យការអមសាលាដំបូង និងមហាអយ្យការអមសាលាឧទ្ធរណ៍។

តួលេខទី ១(ខ) បង្ហាញអំពីអ្នកដែលបានដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមរបស់សាលាដំបូង។ សាលក្រមចេញដោយសាលាដំបូង អាចត្រូវបានប្ដឹងដោយព្រះរាជអាជ្ញាអមសាលាដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី (អ្នកទាំងពីរនេះអាចប្ដឹងបានចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី)។[35] តួលេខនេះបង្ហាញបណ្ដឹងឧទ្ធរណ៍ភាគច្រើន (៨១%) ធ្វើឡើងដោយភាគីជនជាប់ចោទ។

ផ្នែកបន្ទាប់ខាងក្រោមនេះ វិភាគអំពីការអនុវត្តជាក់ស្ដែងនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ពាក់ព័ន្ធផ្សេងៗ ដោយសាលាឧទ្ធរណ៍នៅក្នុងអំឡុងពេលនៃរបាយការណ៍។ សម្រាប់គោលបំណងនៃការវិភាគជាដំបូង របាយការណ៍នេះគូសបញ្ជាក់អំពីទិដ្ឋភាពផ្សេងៗនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរពនៅក្នុងសាលាឧទ្ធរណ៍ មុននឹងឈានដល់ការឆ្លុះបញ្ចាំងលើការអនុវត្តនានាដែលមិនបានគោរពតាមនិយាមនៃការជំនុំជម្រះដោយយុត្តិធម៌។

[35] មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ២.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព

ស្របពេលដែលសកម្មភាពសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក កត់សម្គាល់នូវការអនុវត្តដែលជាការគំរាមកំហែង និងជាការរារាំងដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចដែលបានរៀបរាប់ខាងលើនេះ ម.ស.ម.ក ក៏រីករាយ និងគួរឱ្យលើកទឹកចិត្តផងដែរ ដែលសង្កេតឃើញថា ជាតុផ្សំជាក់លាក់មួយចំនួននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរព និងអនុវត្តបានយ៉ាងប្រសើរនៅសាលាឧទ្ធរណ៍។

| **សិទ្ធិទទួលបានការជំនុំជម្រះយុត្តិធម៌ដែលត្រូវបានគោរពនៅសាលាឧទ្ធរណ៍** |
|---|
| • ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល |
| • ការមិនមានអានុភាពប្រតិសកម្មនៃច្បាប់ |
| • សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ |
| • សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការការពារក្តី |
| • សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ |

### ២.១.១. ការការពារពីការវិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល

| **ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ** | |
|---|---|
| ក.អ.ស.ព.ន<br>មាត្រា ១៤(៧) | "គ្មានជនណាម្នាក់ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើងវិញចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ។" |
| ក្រមព្រហ្មទណ្ឌ<br>មាត្រា ២៣ | "ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះអំពើល្មើសដដែល ហើយដែលក្នុងករណីការផ្តន្ទាទោស បុគ្គលនោះបានបង្ហាញថា ខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ១២ | "ដោយអនុវត្តតាមគោលការណ៍*អាជ្ញាអស់ជំនុំ* ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។" |

ការវិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល ឬគោលការណ៍ *អាជ្ញាអស់ជំនុំ* (ពោលគឺថា"បានវិនិច្ឆ័យរួចហើយ") សំដៅលើសិទ្ធិរបស់បុគ្គលដែលមិនត្រូវឱ្យមានការជំនុំជម្រះលើសពីម្ដងចំពោះអំពី ឬបទល្មើសដដែល។ ករណីនេះ កំណត់ថាសេចក្ដីសម្រេចស្ថាពររបស់តុលាការ ទោះបីជាការលើកលែង ឬការផ្ដន្ទាទោសជនជាប់ចោទក្ដី នឹងក្លាយជារបាំងហាមចំពោះការចោទប្រកាន់បន្ថែមទៀតទៅលើអំពើល្មើសដដែលនោះ។ មានអត្ថប្រយោជន៍ជាច្រើន សម្រាប់ទាំងបុគ្គលជាជនជាប់ចោទ និងសង្គមជារួមក្នុងទទួលយកសេចក្ដីសម្រេចចុងក្រោយនេះ រួមទាំងការផ្ដល់ភាពច្បាស់លាស់ផ្នែកច្បាប់ និងបង្ការនូវភាពខ្ជះខ្ជាយធនធានផ្នែកច្បាប់នៅពេលដែលសេចក្ដីសម្រេចត្រូវបានធ្វើរួចរាល់ហើយនោះ។

### តួលេខទី ២ ៖ ការហាមឃាត់ការវិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល[36]




ជាចំណុចដ៏វិជ្ជមានដែលសង្កេតឃើញថា មានតែមួយករណីប៉ុណ្ណោះក្នុងចំណោមជនជាប់ចោទចំនួន ៥៥៨ នាក់ ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៣៤០ សំណុំរឿងដែលបានសង្កេតដោយ ម.ស.ម.ក ធ្លាប់បានជំនុំជម្រះ និងវិនិច្ឆ័យទោសចំពោះបទល្មើសដដែលក្នុងពេលអតីតកាល។

## ២.១.២. ការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

**ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ**

[36] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុប (៥៥៨ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៣៤០ សំណុំរឿង ដែលបានសង្កេតការណ៍។

| | |
|---|---|
| ស.ស.ស.ម<br>មាត្រា ១១(២) | "គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌដោយអំពើណាមួយ ឬការមិនប្រតិបត្តិតាមណាមួយដែលមិនចាត់ជាបទល្មើសព្រហ្មទណ្ឌ ក្រោមច្បាប់ជាតិ ឬអន្តរជាតិនៅខណៈពេលដែលបទល្មើសបានប្រព្រឹត្តឡើង។ គ្មានទោសបញ្ញត្តិណាមួយត្រូវបានគេយកមកដាក់បង្ខំទៅលើជនណាម្នាក់ ឲ្យធ្ងន់ជាងទោសបញ្ញត្តិដែលបានអនុវត្តនៅខណៈពេលដែលបទល្មើសព្រហ្មទណ្ឌនោះបានប្រព្រឹត្តឡើយ។ |
| ក.អ.ស.ព.ន<br>មាត្រា ១៥ | "គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោសឱ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងមុន។ គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ ចំពោះអំពើ ឬការខកខានណាមួយ ដែលជននោះបានប្រព្រឹត្ត ក្នុងខណៈពេលដែលអំពើឬការខកខាននោះ ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ។" |
| ក្រមព្រហ្មទណ្ឌ<br>មាត្រា ៣ | "មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះ មានចែងនៅក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបផ្តន្ទាទោសព្រហ្មទណ្ឌបាន។" |
| ក្រមព្រហ្មទណ្ឌ<br>មាត្រា ១០ | "បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម។ ប៉ុន្តែការផ្តន្ទាទោសជាស្ថាពរ ហើយនោះ ត្រូវអនុវត្តទោះបីជាទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។ បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ។" |

គោលការណ៍ជាមូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌ គឺថាពុំមានជនណាម្នាក់ត្រូវបានរកឃើញពីពិរុទ្ធភាពនៃបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានដែលមិនបានបង្កើតជាបទល្មើសព្រហ្មទណ្ឌ ពេលដែលអំពើ ឬការខកខាននោះ បានកើតឡើងឡើយ។ ស្រដៀងគ្នានេះ ទោសធ្ងន់ជាងមិនអាចអនុវត្តក្រៅតែពីទោសដែលត្រូវអនុវត្តនៅពេលដែលបទល្មើសព្រហ្មទណ្ឌនោះ ត្រូវបានប្រព្រឹត្តឡើយ។

### តួលេខទី ៣៖ ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

| ទិន្នន័យ | មាន | | គ្មាន | |
|---|---|---|---|---|
| | ចំនួន | % | ចំនួន | % |
| តើជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទល្មើសស្ថិតក្នុងច្បាប់ជាធរមាននៅពេលប្រព្រឹត្តបទល្មើសដែរឬទេ? * | ៥៥៨ | ១០០ | 0 | 0 |

* ទិន្នន័យនេះផ្អែកលើជនជាប់ចោទសរុប (៥៥៨ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿង ៣៤០ សំណុំរឿងដែលបានសង្កេតការណ៍។

ពុំមានករណីណាមួយដែលបានសង្កេតបានបង្ហាញថា ច្បាប់ដែលចោទប្រកាន់លើជនជាប់ចោទណាមួយ ពុំមានអានុភាពអនុវត្តនៅពេលដែលបទល្មើសនោះបានកើតឡើងនោះទេ។ ហេតុនេះការរកឃើញរបស់ ម.ស.ម.ក បង្ហាញថា ការការពារប្រឆាំងការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែលត្រូវបានការពារ។

## ២.១.៣. សិទ្ធិយល់ដឹងពីបទចោទប្រកាន់ និងមូលហេតុនៃការចោទប្រកាន់

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន មាត្រា ១៤(៣)(ក) | "ក្នុងការសម្រេចសេចក្ដីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ត្រូវបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ។" |
| ក.អ.ស.ព.ន មាត្រា ១៤(៣)(ច) | "ក្នុងការសម្រេចសេចក្ដីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ត្រូវទទួលបានអ្នកបកប្រែភាសាដោយឥតគិតឈ្នួល បើជនជាប់ចោទមិនយល់ ឬមិនចេះភាសាដែលប្រើប្រាស់ក្នុងសវនាការ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២២ | "ក្រឡាបញ្ជីហៅឈ្មោះជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់មើលអត្តសញ្ញាណជនទាំងនោះ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២៥ | "ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទឱ្យបានដឹងអំពីអំពើដែលគេចោទប្រកាន់លើខ្លួន និងធ្វើការសួរចម្លើយជនជាប់ចោទនេះ។" |

| | |
|---|---|
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៣០ | "ក្នុងករណីចាំបាច់ ប្រធានអាចហៅរកអ្នកបកប្រែ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៣១ | "កាលណាសំណួរត្រូវសួរដល់ជនគ និងថ្លង់ ក្រឡាបញ្ជីត្រូវសរសេរសំណួរ ហើយឱ្យសាមីខ្លួនអាន និងឆ្លើយជាលាយលក្ខណ៍អក្សរ។ ក្នុងករណីសាមីជនមិនចេះអាន ឬមិនចេះអក្សរ ប្រធានត្រូវរកអ្នកបកប្រែក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៣៣០ [...] ប្រធានសវនាការអាចហៅរកអ្នកធ្លាប់ប្រាស្រ័យទាក់ទងជាមួយជនគ និងថ្លង់នោះ មកបកប្រែ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៩៦ | "លើសពីនេះវិធានដែលអនុវត្តចំពោះតុលាការជាន់ដំបូង ត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍។" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៦ | "អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖[...] សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី [...] សិទ្ធិទទួលបានការឱ្យដំណឹងអំពីបទចោទប្រកាន់[...]" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៥១ | "នៅពេលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនយល់បាន អំពីសិទ្ធិដូចខាងក្រោម៖ សិទ្ធិដែលទាក់ទងនឹងដំណាក់កាលនៃការជំនុំជម្រះដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ [...]." |

ជនទាំងឡាយណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវតែទទួលបាននូវការជូនដំណឹងអំពីបទចោទប្រកាន់ ដែលជននោះត្រូវបានចោទប្រកាន់។ ប្រសិនបើពុំមានព័ត៌មានដ៏សំខាន់នេះទេ គេពិតជាមិនអាចរៀបចំការការពារក្តីឱ្យបានត្រឹមត្រូវ ឬផ្តល់ការណែនាំឱ្យបានល្អិតល្អន់ដល់មេធាវីនៅក្នុងសំណុំរឿងដែលជនជាប់ចោទមានមេធាវីការពារតាមផ្លូវច្បាប់។ អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ប្រមូលទិន្នន័យទាក់ទងនឹងព័ត៌មាន ដែលត្រូវបានប្រាប់ដល់ជនជាប់ចោទនៅពេលចាប់ផ្តើមសវនាការ។ ទោះបីជាព័ត៌មាននេះ គួរតែត្រូវបានប្រាប់ដល់ជនជាប់ចោទរួចហើយ នៅក្នុងអំឡុងពេលនៃនីតិវិធីមុនសវនាការ/ការស៊ើបសួរក៏នៅតែមានសារសំខាន់សម្រាប់ចៅក្រមក្នុងការរម្លឹកដល់ជនជាប់ចោទអំពីព័ត៌មាននេះ មុនពេលសវនាការចាប់ផ្តើម ហើយត្រូវប្រាកដថាជនជាប់ចោទយល់ព័ត៌មាននេះ។ នេះជាការងារដ៏មានសារសំខាន់ជាពិសេសដោយសារតែពេលខ្លះបទចោទអាចត្រូវបានផ្លាស់ប្តូរ ឬកែប្រែនៅចន្លោះពេលនៃការចាប់ខ្លួនដំបូង/ការចោទប្រកាន់ ក្នុងអំឡុងពេលសវនាការ។

## តួលេខទី ៤(ក)៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់៖ ទិដ្ឋភាពទូទៅ

**តើចៅក្រមបានប្រាប់ពីបទចោទប្រកាន់ដែលពាក់ព័ន្ធដល់ជនជាប់ចោទគ្រប់រូបដែរឬទេ ?**




ក្នុងអំឡុងពេលធ្វើរបាយការណ៍ ទិន្នន័យដែលបានចងក្រងបានបង្ហាញថា ក្នុងសំណុំរឿងភាគច្រើន (២៩៤ សំណុំរឿង ក្នុងចំណោមសំណុំរឿងទាំង ៣៤០ សំណុំរឿង) ចៅក្រមបានប្រាប់អំពីបទចោទប្រកាន់ដែលពាក់ព័ន្ធទាំងអស់ដល់ជនជាប់ចោទ។ ប៉ុន្តែក្នុងសំណុំរឿងចំនួន ៤៤ សំណុំរឿង ចៅក្រមបានប្រាប់ដល់ជនជាប់ចោទតែផ្នែកខ្លះនៃបទចោទប្រកាន់ប៉ុណ្ណោះ។ មានតែពីរសំណុំរឿងដែលចៅក្រមមិនបានប្រាប់អំពីបទចោទប្រកាន់ដល់ជនជាប់ចោទ។

## តួលេខទី ៤(ខ)៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់៖ ទិដ្ឋភាពលម្អិត

| ទិន្នន័យ | មាន | | គ្មាន | | មិនពាក់ព័ន្ធ[37] | |
|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| តើចៅក្រមបានប្រាប់ពីមាត្រាច្បាប់ដែលពាក់ព័ន្ធដែរឬទេ ? | ៣២៨ | ៩៦ | ១២ | ៤ | ០ | ០ |
| តើចៅក្រមបានប្រាប់ពីកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើស ដែរឬទេ ? | ៣២៥ | ៩៦ | ១៥ | ៤ | ០ | ០ |
| តើចៅក្រមបានប្រាប់ពីកន្លែងប្រព្រឹត្តបទល្មើសដែរឬទេ ? | ៣០៩ | ៩១ | ៣១ | ៩ | ០ | ០ |
| តើចៅក្រមបានរៀបរាប់ពីឈ្មោះអ្នកចូលរួម ដែរឬទេ ? | ៣៣៣ | ៩៨ | ៧ | ២ | ០ | ០ |
| ប្រសិនបើត្រូវការ តើអ្នកបកប្រែត្រូវបានផ្ដល់ឱ្យដែរឬទេ ? | ៤ | ១ | ៣ | ១ | ៣៣៣ | ៩៨ |

[37] "មិនពាក់ព័ន្ធ" សំដៅលើជនជាប់ចោទជាជនជាតិខ្មែរ ឬជនជាប់ចោទគ្មានពិការភាព។

| | | | | | | |
|---|---|---|---|---|---|---|
| ប្រសិនបើត្រូវការជំនួយ ដែរឬទេ? | តើជនពិការត្រូវបានគេផ្ដល់ | ១ | ០.៣ | ១ | ០.៣ | ៣៣៨ | ៩៩.៤ |

តួលេខខាងលើនេះបង្ហាញថា ក្នុងសំណុំរឿងជាច្រើន ចៅក្រមនៅសាលាឧទ្ធរណ៍ថ្លែងឡើងវិញអំពីបទចោទប្រកាន់ អង្គហេតុ កាលបរិច្ឆេទ និងព័ត៌មានទាក់ទងនឹងបទចោទ។ ហេតុនេះ សិទ្ធិយល់ដឹងអំពីប្រភេទនៃការចោទប្រកាន់នៅក្នុងនីតិវិធីបណ្ដឹងឧទ្ធរណ៍ជាញឹកញាប់ត្រូវបានគោរព។

## ២.១.៤. សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្ដី

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន មាត្រា ១៤ (៣)(ខ) | "ក្នុងការសម្រេចសេចក្ដីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ត្រូវមានពេលវេលា និងសម្ភារបរិក្ខារគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤៨ | "[...] ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថា រឿងក្ដីនោះមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេនោះ សំណុំរឿងត្រូវលើកទៅពេលសវនាការក្រោយ [...]" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩៨ | "ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្ដើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួនអាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស [...]។ ជនដែលត្រូវបានជ្រើសរើសនេះអាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងទាក់ទងជាមួយបុគ្គលសាមីខ្លួនបាន ៣០ (សាមសិប) នាទី ក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនានេះ។ ក្រោយការសន្ទនាជននេះ អាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៤៥ | "កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃមុន ការសួរចម្លើយ។ ក្នុងថេរវេលានេះ មេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធី [...]" |
| ក្រមនីតិវិធី | "អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងមេធាវី អាចពិនិត្យមើលសំណុំរឿងរហូតដល់ពេលបើកសវនាការ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវប្រគល់សេចក្ដីសន្និដ្ឋានជា |

| | |
|---|---|
| ព្រហ្មទណ្ឌ មាត្រា២៥៩ | លាយលក្ខណ៍អក្សរដល់ក្រឡាបញ្ជីយ៉ាងយូរបំផុត ១ (មួយ) ថ្ងៃ មុនពេលសវនាការ [...]" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៣១៩ | "មុនពេលសវនាការ មេធាវីអាចពិនិត្យមើលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី [...]" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ២៩ | "ក្នុងករណីណាក៏ដោយការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញា ត្រូវឱ្យដំណឹងភ្លាមដោយផ្ទាល់ និងជាលាយលក្ខណ៍អក្សរទៅអនីតិជន ហើយប្រសិនបើសមស្របត្រូវឱ្យដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងមេធាវីរបស់អនីតិជន ដើម្បីរៀបចំមធ្យោបាយការពារអនីតិជន។" |

បុគ្គលណា ដែលប្រឈមនឹងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ គួរត្រូវបានផ្តល់ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមការពារខ្លួនចំពោះបទចោទប្រកាន់ទាំងនោះ។ រយៈពេលដែលថា "គ្រប់គ្រាន់" អាស្រ័យលើប្រភេទ និងភាពស្មុគស្មាញនៃបទចោទប្រកាន់ ចំនួននៃបទចោទប្រកាន់ និងប្រភេទនៃភស្តុតាងព្រមទាំងកត្តាដទៃទៀត។[38] ជាគោលការណ៍ ជនជាប់ចោទចាំបាច់ត្រូវអាចរៀបចំការពារក្តីរបស់ខ្លួនឱ្យបានសមស្រប ពោលគឺ អាចរៀបចំដើម្បីឆ្លើយតបទៅនឹងភស្តុតាងរបស់តំណាងអយ្យការ ស៊ើបអង្កេត និងបង្ហាញសាក្សីការពារខ្លួន។ មធ្យោបាយចាំបាច់ក្នុងការរៀបចំការពារខ្លួន រាប់បញ្ចូលទាំងការទទួលបាននូវឯកសារ និងភស្តុតាងនានានៃសំណុំរឿង ដើម្បីឱ្យជនជាប់ចោទបានដឹងពីបទចោទប្រកាន់មកលើខ្លួនបានពេញលេញ ហើយជនជាប់ចោទអាចមានលទ្ធភាពផ្តល់ព័ត៌មានពេញលេញដល់មេធាវីរបស់ខ្លួន។[39] បន្ថែមលើនេះទៀត សិទ្ធិមានមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី ក៏រួមបញ្ចូលទាំងការផ្តល់មធ្យោបាយអំណោយផលដែលអនុញ្ញាតឱ្យជនជាប់ចោទអាចប្រាស្រ័យទាក់ទងដោយមិនបើកចំហឱ្យអ្នកផ្សេងបានដឹង ជាមួយមេធាវីការពារក្តីរបស់ខ្លួនផងដែរ។[40] នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ ប្រការនេះក៏មានន័យថា ជនជាប់ចោទគួរតែមានសិទ្ធិក្នុងការទទួលបានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់សាលាដំបូង និងប្រតិចារឹកនៃសវនាការជំនុំជម្រះ ដើម្បីឱ្យគាត់អាចរៀបចំការពារក្តីរបស់ខ្លួន។

---

[38] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅលេខ ១៣: ១៩៨៤, វាក្យខណ្ឌ ៩, http://bit.ly/1vnBOE8។

[39] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅលេខ ១៣: ១៩៨៤, វាក្យខណ្ឌ ៩, http://bit.ly/1vnBOE8។

[40] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅលេខ ១៣: ១៩៨៤, វាក្យខណ្ឌ ៩, http://bit.ly/1vnBOE8។ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ, CCPR សេចក្តីពន្យល់ទូទៅលេខ ៣២, ២០០៧ វាក្យខណ្ឌ ៣៤, http://bit.ly/1zOqr0M។

## តួលេខទី ៥៖ សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការការពារក្តី[41]

តើមានអ្វីមួយដែលបង្ហាញថា មេធាវីការពារជនជាប់ចោទត្រូវបានចាត់តាំងនៅក្នុងថ្ងៃសវនាការ ដែរឬទេ?




តើបញ្ហាពេលវេលា និងមធ្យោបាយមិនគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីត្រូវបានលើកឡើងដោយភាគីជនជាប់ចោទ ដែរឬទេ?




ថ្វីបើការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍ ពុំបានផ្តល់ព័ត៌មានដែលចាំបាច់ទាំងអស់ដល់ ម.ស.ម.ក ដើម្បីវាយតម្លៃបានថាតើជនជាប់ចោទមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីរបស់ខ្លួន ឬពុំមានក៏ដោយ បើយោងតាមព័ត៌មានដែលមាន ម.ស.ម.ក បានកត់សម្គាល់ឃើញជាវិជ្ជមានថា មានការគោរពសិទ្ធិនេះ នៅក្នុងសំណុំរឿងភាគច្រើនលើសលប់។ ម.ស.ម.ក សង្កេតឃើញថាមានតែ ២% ប៉ុណ្ណោះនៃសំណុំរឿងដែលបានសង្កេត បង្ហាញថាមេធាវីការពារជនជាប់ចោទត្រូវបានចាត់តាំងនៅក្នុងថ្ងៃសវនាការលើបណ្តឹងឧទ្ធរណ៍ ហើយសំណុំរឿងភាគច្រើន គឺសុទ្ធតែមានមេធាវីនៅមុនពេលនោះ។ ក្នុងចំណោមសំណុំរឿងទាំង ៣៤០ សំណុំរឿង មានតែមេធាវីការពារជនជាប់ចោទមួយសំណុំរឿងប៉ុណ្ណោះដែលបានលើកឡើងអំពីបញ្ហានៃការរៀបចំការពារក្តី ហើយបានស្នើសុំឱ្យចៅក្រមអានអង្គហេតុក្នុងសំណុំរឿងដើម្បីការពារកូនក្តីរបស់ខ្លួន។

[41] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ជនសរុប (៥៥៨ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៣៤០ សំណុំរឿង ដែលបានសង្កេតការណ៍។ "មិនពាក់ព័ន្ធ" សំដៅលើសំណុំរឿងដែលជនជាប់ជនមិនមានមេធាវីតំណាង។

## ២.១.៥. សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន មាត្រា ១៤(១) | "[...] ប៉ុន្តែការចេញសាលក្រមទាំងអស់អំពីរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ លើកលែងតែផលប្រយោជន៍អនីតិជន តម្រូវផ្សេងពីនេះ ឬរឿងក្តីអំពីទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣១៧ | "នៅក្នុងគ្រប់ករណីទាំងអស់សាលក្រមត្រូវប្រកាសនៅពេលសវនាការជាសាធារណៈ។" |
| ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៧ | "[...] នៅគ្រប់ករណីទាំងអស់ សាលក្រម និងសាលដីកាតុលាការ ត្រូវប្រកាសនៅក្នុងសាលសវនាការដែលបើកជាសាធារណៈ [...]" |

តួលេខទី ៦៖ សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ[42]




នៅគ្រប់សំណុំរឿងទាំងអស់ដែលយើងទទួលបានព័ត៌មាន សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈត្រូវបានគោរព។

[42] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទជនសរុប (៥៥៨ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៣៤០ សំណុំរឿង ដែលបានសង្កេតការណ៍។ "មិនដឹង" សំដៅលើសំណុំរឿងមិនទទួលបានព័ត៌មាន ឬសំណុំរឿងដែលមិនត្រូវបានតាមដានបន្តដោយសារអ្នកសង្កេតការណ៍សវនាការមិនមានវត្តមាននៅថ្ងៃប្រកាសសាលដីកា។

## ២.២. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌កំពុងប្រឈមនឹងការរំលោភបំពាន

នៅមានចំណុចខ្វះខាតក្នុងការធានាអនុវត្តសិទ្ធិមួយចំនួន និង/ឬការអនុវត្តនៅពុំទាន់បានពេញលេញនៅឡើយ ហេតុដូច្នេះបានគំរាមគំហែងដល់សិទ្ធិបុគ្គលក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

| សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌កំពុងប្រឈមនឹងការរំលោភបំពាននៅសាលាឧទ្ធរណ៍ |
| --- |
| • សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ |
| • សិទ្ធិមានវត្តមាននៅក្នុងសវនាការ និងមានមេធាវី |
| • សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស |
| • សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព |
| • សិទ្ធិបង្ហាញពីការការពារខ្លួន (សិទ្ធិបង្ហាញភស្តុតាង) |
| • សិទ្ធិទទួលបានសេចក្តីសម្រេចមានសម្អាងហេតុ |
| • សិទ្ធិរបស់អនីតិជន |

### ២.២.១. សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
| --- | --- |
| ក.អ.ស.ព.ន<br>មាត្រា ១៤(១) | "ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ជនគ្រប់រូប ត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួនដោយសមធម៌ និងជាសាធារណៈ [...]" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣៩២ | "ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅពេលសវនាការជាសាធារណៈ។" |
| ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៧ | "សវនាការត្រូវធ្វើឡើងជាសាធារណៈ" |

មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការសម្រេចថាមានពិរុទ្ធភាព ឬគ្មានទោសនៅក្នុងសវនាការជាសាធារណៈ លើកលែងតែក្នុងករណីពិសេសជាក់លាក់មួយចំនួន ឧទាហរណ៍៖ នៅពេលដែលតុលាការយល់ឃើញថា សវនាការជាសាធារណៈនឹងបង្កឱ្យមាន *"ការប៉ះពាល់ធ្ងន់ធ្ងរ"* ដល់សណ្តាប់ធ្នាប់សង្គម ជនជាប់ជនជាអនីតិជន ឬដល់ទំនៀមទម្លាប់ដ៏ល្អប្រពៃ។[43] សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈពាក់ព័ន្ធនឹងធាតុផ្សំមួយចំនួន៖ សវនាការគួរតែបើកចំហជាទូទៅសម្រាប់សាធារណជន និងត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ព័ត៌មានពីទីកន្លែង និងកាលបរិច្ឆេទនៃសវនាការ គួរតែអាចរកបានជាសាធារណៈ ហើយគួរតែមានសម្ភាររូបវន្តគ្រប់គ្រាន់ដើម្បីធានាការចូលរួមពីសាធារណជន។[44]

## តួលេខទី ៧ ៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ




ការជូនដំណឹងអំពីសវនាការ គឺជាវិធីមួយដើម្បីលើកកម្ពស់សវនាការជាសាធារណៈ តាមរយៈការផ្តល់ដំណឹងជូនដល់សាធារណជន ថាតើនរណាខ្លះដែលត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងបន្ទប់សវនាការ។ ក្នុង

---

[43] មាត្រា ៣១៦ នៃក្រមនីតិវិធិព្រហ្មទណ្ឌចែងថា បើតុលាការយល់ឃើញថាសាធារណភាពបង្កឱ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទម្លាប់ នោះតុលាការតាមសេចក្តីសម្រេចមានសម្អាងហេតុ អាចបង្គាប់ឱ្យការពិភាក្សាដេញដោលទាំងស្រុង ឬមួយផ្នែកប្រព្រឹត្តិទៅជាសម្ងាត់ ប៉ុន្តែតុលាការសម្រេចតាមសាលក្រមមួយដាច់ដោយឡែកពីសាលក្រមអង្គសេចក្តី ឬតាមសេចក្តីសម្រេចពិសេសនៃសាលក្រមលើអង្គសេចក្តី។ មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបញ្ញត្តិថា សារព័ត៌មាន និងសាធារណជនមិនអាចចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការសម្រាប់ផលប្រយោជន៍នៃ *"ទំនៀមទម្លាប់ល្អ សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិក្នុងសង្គមប្រជាធិបតេយ្យ"* ដែលថាការធ្វើជាសាធារណៈនឹងនាំឱ្យខូចខាតដល់ផលប្រយោជន៍យុត្តិធម៌ ឬនៅពេលផលប្រយោជន៍នៃជីវិតរបស់គូភាគីតម្រូវឱ្យធ្វើដូច្នេះ។ មាត្រា ៤៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនចែងថា ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមរឿងក្តីអនីតិជន ត្រូវធ្វើឡើងក្នុងសវនាការជាអសាធារណៈ។

[44] HRC CCPR, *សំណុំរឿង Van Meurs ទល់នឹងប្រទេសហូឡង់ដ៍* សេចក្តីសម្រេចលេខ ២១៥/១៩៨៦ នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/C/39/D/215/1986, ឆ្នាំ១៩៩០ វាក្យខណ្ឌ ៦.២, http://bit.ly/2DaKGNr។

អំឡុងពេលធ្វើរបាយការណ៍ ម.ស.ម.ក បានសង្កេតឃើញថា ពុំមានការបិទផ្សាយដំណឹងជាសាធារណៈអំពីសវនាការនៅខាងក្រៅបន្ទប់សវនាការឡើយ។ យ៉ាងណាក៏ដោយសាធារណជន ពុំធ្លាប់ត្រូវបានរាំងមិនឱ្យចូលរួមក្នុងសវនាការឡើយ។ អនុប្រធានសាលាឧទ្ធរណ៍[45]បានយល់ស្របថា ពិតជាមានកង្វះខាតចំពោះការបិទផ្សាយការជូនដំណឹងដល់សាធារណជនពាក់ព័ន្ធនឹងកាលវិភាគរបស់តុលាការមែន និងបានជូនដំណឹងដល់ ម.ស.ម.ក ថាសាលាឧទ្ធរណ៍នឹងចាត់វិធានការ ដើម្បីធ្វើឲ្យការទទួលបានព័ត៌មានទាក់ទងនឹងសវនាការមានការប្រសើរឡើងសម្រាប់សាធារណជន។

### ២.២.២. សិទ្ធិមានវត្តមាននៅពេលសវនាការ និងមានមេធាវី

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| **ក.អ.ស.ព.ន**<br>មាត្រា ១៤(៣)(ឃ) | "ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ត្រូវជំនុំជម្រះដោយវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃ នៅគ្រប់ករណីបែបនេះ បើជនជាប់ចោទ គ្មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ។" |
| **រដ្ឋធម្មនុញ្ញ**<br>មាត្រា ៣៨ | "ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។" |
| **ក្រមនីតិវិធីព្រហ្មទណ្ឌ**<br>មាត្រា ១៤៣ | "នៅពេលដែលជនត្រូវចោទដែលជាអនីតិជន ចូលបង្ហាញខ្លួនជាលើកដំបូង ជននេះត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ តុលាការត្រូវចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។" |

[45] ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បានជួបជាមួយអនុប្រធានសាលាឧទ្ធរណ៍ ឯកឧត្តម ប្លង់ សំណាង ឯកឧត្តម ញូង ធុល ព្រមទាំងអគ្គលេខាធិការរងរដ្ឋបាល លោកស្រី ស្រេង សូយ៉េត ដើម្បីពិភាក្សាលើរបកគំហើញនៅក្នុងរបាយការណ៍នេះ។

| | |
|---|---|
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣០០ | "ជនជាប់ចោទត្រូវចូលបង្ហាញខ្លួន នៅពេលសវនាការរបស់តុលាការដោយផ្ទាល់។ ជនជាប់ចោទត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស។ ជនជាប់ចោទក៏អាចសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួនបានដែរ នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣០១ | "ជំនួយពីមេធាវីត្រូវតែមានជាចំាបាច់នៅក្នុងករណីដូចតទៅ៖ ១. ករណីបទឧក្រិដ្ឋ ២. កាលណាជនជាប់ចោទជាអនីតិជន។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣៨៩ | "ជនជាប់ចោទដែលជាប់ឃុំ ត្រូវតែផ្ទេរនៅក្នុងរយៈពេលយ៉ាងខ្លីបំផុត តាមបញ្ជារបស់អគ្គព្រះរាជអាជ្ញាឱ្យទៅនៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដែលនៅជិតជាងគេបំផុតនៃទីស្នាក់ការរបស់សាលាឧទ្ធរណ៍។" |
| ច្បាប់ស្តីពីពន្ធនាគារ<br>មាត្រា ៦២ | "ការផ្ទេរជនជាប់ឃុំក្រៅពីទណ្ឌិតពីពន្ធនាគារមួយទៅពន្ធនាគារមួយ ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីបញ្ជូន និងព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីទទួល ឬព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចកំពុងចាត់ការរឿងក្តី។" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៦ | "អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថា បានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖ [...] សិទ្ធិទទួលបានជំនួយពីមេធាវី [...]" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៥០ | "ជំនួយរបស់មេធាវី ត្រូវតែមានជាចំាបាច់នៅក្នុងសវនាការ [...]" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៥១ | "នៅពេលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បាន អំពីសិទ្ធិដូចខាងក្រោម៖<br>• សិទ្ធិដែលទាក់ទងនឹងដំណាក់កាលនៃការជំនុំជម្រះដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ<br>• សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្តី<br>• សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោលមិនសមរម្យ |

- សិទ្ធិប្តឹងជិតចិត្តចៅក្រមជំនុំជម្រះ
- សិទ្ធិធ្វើសំណូមពរចុងក្រោយ និង
- សិទ្ធិប្តឹងឧទ្ធរណ៍។"

ការដែលត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយ អាចជាបទពិសោធន៍គួរឱ្យខ្លាច ហើយនីតិវិធីច្បាប់អាចមានភាពស្មុគស្មាញ និងច្របូកច្របល់។ ហេតុដូច្នោះជាការសំខាន់ណាស់ដែលបុគ្គលគ្រប់រូបមានឱកាសទទួលបានមេធាវី។ បន្ថែមលើនេះទៀត ជនជាប់ចោទដែលពុំមានលទ្ធភាពអាចជួលមេធាវីដោយខ្លួនឯងអាថ្វាធរដែលពាក់ព័ន្ធគួរផ្តល់មេធាវីដោយឥតគិតថ្លៃ ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ។[46] សិទ្ធិមានមេធាវីធានាថា ជនជាប់ចោទមានឱកាសក្នុងការទទួលបានការណែនាំផ្នែកវិជ្ជាជីវៈពីអ្នកជំនាញផ្នែកតស៊ូមតិដែលមានលទ្ធភាពពន្យល់នូវបទចោទប្រកាន់ប្រឆាំងខ្លួន ពន្យល់ពីសិទ្ធិ ណែនាំពីដំណើរការជំនុំជម្រះ និងការពារផលប្រយោជន៍ដល់ខ្លួននៅក្នុងតុលាការ។ នៅក្នុងប្រទេសកម្ពុជា ជាលក្ខខណ្ឌតម្រូវសម្រាប់បុគ្គលម្នាក់ត្រូវទទួលបានមេធាវី ប្រសិនបើបុគ្គលនោះត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬជននោះជាអនីតិជន។ ថ្វីបើពុំមានការតម្រូវដោយច្បាប់ចំពោះការទទួលបានមេធាវី ប្រសិនជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទមជ្ឈិម (លើកលែងតែជាអនីតិជន) ជននោះនៅតែមានជម្រើសមានមេធាវី ប្រសិនបើខ្លួនត្រូវការរក្សាឱ្យមានមេធាវី។ នៅក្នុងករណីបែបនេះ បន្ទុកក្នុងការរក្សាឱ្យមានមេធាវី ពុំមែនជាបន្ទុករបស់តុលាការឡើយ។

បន្ថែមលើនេះទៀត សវនាការចាំបាច់ត្រូវធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ[47] ដើម្បីអនុញ្ញាតឱ្យជនជាប់ចោទអាចបានឮ និងឆ្លើយតបចំពោះសំណុំរឿងដែលបានប្តឹងប្រឆាំងរូបខ្លួន ព្រមទាំងបង្ហាញការការពារខ្លួន។ ទាក់ទងជាមួយអនីតិជន សវនាការត្រូវធ្វើឡើងដោយមានវត្តមាន "ជំនួយផ្នែកច្បាប់ ឬជំនួយសមស្របដទៃទៀត" ព្រមទាំងឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់កុមារ លើកលែងតែរកឃើញថាការធ្វើបែបនេះ ពុំមែនជាឧត្តមប្រយោជន៍របស់កុមារ។[48] សិទ្ធិមានវត្តមានផ្ទាល់ ត្រូវអនុវត្តចំពោះនីតិវិធីបណ្តឹងឧទ្ធរណ៍ ប្រសិនបើសំណុំរឿងនោះពាក់ព័ន្ធសំណួរផ្នែកអង្គហេតុផង និងអង្គច្បាប់ផង[49] ដែលករណីនេះកើតមាននៅក្នុងប្រទេសកម្ពុជា។ ថ្វីបើសវនាការ *កំបាំងមុខ* អាចត្រូវបានអនុញ្ញាតឱ្យមានតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិក្តី សវនាការកំបាំងមុខ អាចត្រូវបានអនុញ្ញាតឱ្យធ្វើឡើងបានតែក្នុងស្ថានភាពពិសេស និងនៅពេលការធ្វើបែបនេះ ផ្តល់ផលប្រយោជន៍ដល់ការអនុវត្តត្រឹមត្រូវផ្នែកយុត្តិធម៌ប៉ុណ្ណោះ។ ចាំបាច់ត្រូវមានការផ្តល់ហេតុផល

---

[46] មាត្រា ១៤(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[47] មាត្រា ១៤(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[48] មាត្រា ៤០(២)(ខ)(iii) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

[49] UN HRC, *សំណុំរឿង Karttunen ទល់នឹងប្រទេសហ្វាំងឡង់* សេចក្តីសម្រេចលេខ ៣៨៧/១៩៨៩, នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/C/46/D/387/1989, ឆ្នាំ១៩៩២ វាក្យខណ្ឌ ៧.៣, http://bit.ly/2Dm8cUr។

សមស្រប ដើម្បីអាចធ្វើសវនាការកំបាំងមុខបាន។[50] បន្ថែមលើនេះទៀត ចាំបាច់ត្រូវមានការបញ្ជាក់ច្បាស់ពីជនជាប់ចោទថា ខ្លួនបោះបង់សិទ្ធិមានវត្តមាននៅពេលសវនាការ។[51]

### តួលេខទី ៨៖ សិទ្ធិមានវត្តមាននៅពេលសវនាការ និងមានមេធាវី [52]




តួលេខខាងលើបង្ហាញឱ្យឃើញថា ជនជាប់ចោទ ១៥៤ នាក់ក្នុងចំណោម ៥៥៨ នាក់ (២៨%) ពុំមានវត្តមានក្នុងពេលសវនាការទេ ហើយ ១១៩ នាក់ (២១%) ពុំមានមេធាវីតំណាងឡើយ។ ក្នុងចំណោមជនជាប់ចោទ ១១៩ នាក់ ដែលពុំមានមេធាវីតំណាង ជនជាប់ចោទ ០៦ នាក់ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ (ក្នុងនោះ០៤សំណុំរឿង ដែលដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងឧទ្ធរណ៍) ហើយជនជាប់ចោទ ១១៣ នាក់ដែលផ្សេងទៀតត្រូវបានចោទប្រកាន់ពីបទមជ្ឈិម។ ក្នុងសំណុំរឿង ៤០% ដែលជនជាប់ចោទមានមេធាវីតំណាងនោះ មេធាវីម្នាក់បានការពារជនជាប់ចោទច្រើនជាងម្នាក់។ មានតែ ៤% នៃសំណុំរឿងទាំងអស់នេះប៉ុណ្ណោះ ដែលមានទំនាស់ផលប្រយោជន៍។ ថ្វីបើនេះជាចំនួនដ៏តិចតួចក្តី ប៉ុន្តែបើគិតទៅលើលក្ខណសម្បត្តិជាមូលដ្ឋាននៃសិទ្ធិមានវត្តមាននៅក្នុងសវនាការ និងមានមេធាវី ទិដ្ឋភាពនេះនៅតែមានលក្ខណៈគួរឱ្យព្រួយបារម្ភ។ អនុប្រធានសាលាឧទ្ធរណ៍[53] បានកត់សម្គាល់ឃើញថា សំណុំរឿងភាគច្រើនជនជាប់ចោទអវត្តមានពេលសវនាការដោយ

---

[50] UN HRC, *សំណុំរឿង Mbenge ទល់នឹង Zaire*, សេចក្តីសម្រេចលេខ ០១៦/១៩៧៧, នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/C/18/D/16/1977 ឆ្នាំ១៩៨៣ វាក្យខណ្ឌ ១៤.១, http://bit.ly/2muzOje។

[51] UN HRC, សេចក្តីពន្យល់ទូទៅលេខ ៣២, ២០០៧, វាក្យខណ្ឌ ៣៦, http://bit.ly/1zOqr0M។

[52] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ជនសរុប (៥៥៨ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៣៤០ សំណុំរឿង ដែលបានសង្កេតការណ៍។

[53] ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បានជួបជាមួយអនុប្រធានសាលាឧទ្ធរណ៍ ឯកឧត្តម ប្លង់ សំណាង ឯកឧត្តម ញូង ធុល ព្រមទាំងអគ្គលេខាធិការរងរដ្ឋបាល លោកស្រី ស្រេង សូយ៉េត ដើម្បីពិភាក្សាលើរបកគំឃើញនៅក្នុងរបាយការណ៍នេះ។

សារបញ្ហាកង្វះខាតនៃការដឹកជញ្ជូនជនជាប់ចោទពីមណ្ឌលកែប្រែមកតុលាការ ដែលនេះជាការទទួលខុសត្រូវរបស់អគ្គនាយកដ្ឋានពន្ធនាគារ។

### តួលេខទី ៩៖ ការពន្យល់ប្រាប់សិទ្ធិ

**តើចៅក្រមបានប្រាប់ និងពន្យល់ជនជាប់ចោទពីសិទ្ធិមានមេធាវី ឬសិទ្ធិការពារខ្លួន ដែរឬទេ?**




*ជនជាប់ចោទអវត្តមាន។

ដោយហេតុថា ៦៤% នៃសំណុំរឿងទាំង ៣៤០ សំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍ ជនជាប់ចោទមានមេធាវីតំណាងរួចហើយ ជាការបង្ហាញថា សិទ្ធិរបស់បុគ្គលក្នុងការទទួលបានមេធាវីភាគច្រើនត្រូវបានការពារ។ មានតែក្នុងសំណុំរឿងមួយចំនួនតូចប៉ុណ្ណោះ ពោលគឺ ៣៨ សំណុំរឿងក្នុងចំណោមសំណុំរឿងទាំង ៣៤០ សំណុំរឿង ឬស្មើនឹង ១១% ដែលចៅក្រមពុំបានប្រាប់ និងពន្យល់ជនជាប់ចោទអំពីសិទ្ធិមានមេធាវី ឬសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ។

ក្នុងករណីជនជាប់ចោទពុំមានវត្តមាននៅក្នុងសវនាការ ជាញឹកញាប់អវត្តមាននេះដោយសារបញ្ហាភ័ស្តុភារ ក៏ដូចជាបញ្ហាផ្នែកការប្រាស្រ័យទាក់ទងរវាងចៅក្រមជាមួយមណ្ឌលកែប្រែ ឬកន្លែងឃុំឃាំង។ ដោយហេតុថា មានសាលាឧទ្ធរណ៍តែមួយប៉ុណ្ណោះសម្រាប់ប្រទេសទាំងមូល ជនជាប់ចោទដែលជាប់ឃុំនៅក្នុងមណ្ឌលកែប្រែតាមខេត្ត ចាំបាច់ត្រូវធ្វើដំណើរមកកាន់សាលាឧទ្ធរណ៍នៅថ្ងៃសវនាការ។ ប៉ុន្តែមានករណីជាច្រើនដែលការដឹកជញ្ជូនជនជាប់ចោទពុំអាចធ្វើឡើងបាន ដោយសារតែតុលាការបញ្ជូនព័ត៌មានទៅខុសមណ្ឌលកែ

ប្រែ ឬដោយសារតែមណ្ឌលកែប្រែពុំបានផ្តល់ព័ត៌មានបច្ចុប្បន្នភាព អំពីការផ្ទេរជនជាប់ឃុំពីមណ្ឌលកែប្រែមួយទៅមណ្ឌលកែប្រែមួយទៀត។ បញ្ហាកស្តុភារទាំងអស់នេះ អាចត្រូវបានឆ្លើយតបយ៉ាងងាយស្រួលដោយមិនត្រឹមតែត្រូវបង្កើតសាលាឧទ្ធរណ៍បន្ថែមទៀតនោះទេ ប៉ុន្តែត្រូវតែកែលម្អការរក្សាកំណត់ត្រា និងការប្រាស្រ័យទាក់ទងរវាងតុលាការជាមួយមណ្ឌលកែប្រែផងដែរ។

## ២.២.៣. ការគោរពចំពោះការសន្និតទុកជាមុនថាគ្មានទោស

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន<br>មាត្រា ១៤(២) | "ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្និតជាមុនថាគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់ស្របតាមច្បាប់។" |
| រដ្ឋធម្មនុញ្ញ<br>មាត្រា ៣៨ | "ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៥ | "គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឱ្យមានការគោរពគោលការណ៍ដូចតទៅ៖ [...] សន្និតថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។" |

ការសន្និតទុកជាមុនថាគ្មានទោស គឺជាសិទ្ធិជាមូលដ្ឋាន និងត្រូវបានទទួលស្គាល់ជាសកលថាជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលសិទ្ធិនេះអនុវត្តនៅពេញនីតិវិធីនៃការស៊ើបអង្កេត និងការជំនុំជម្រះផ្នែកព្រហ្មទណ្ឌ រហូតដល់ការបញ្ចប់បណ្តឹងឧបាស្រ័យចុងក្រោយ។[54] មានន័យថាជនម្នាក់ត្រូវបានសន្និតជាមុនថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់ស្របតាមច្បាប់ និងតាមរយៈសាលក្រមឬសាលដីកាស្ថាពរ។ គោលការណ៍ដែលថា បន្ទុកនៃភស្តុតាងស្ថិតនៅលើស្ថាប័នអយ្យការ មិនមែនជាបន្ទុករបស់ជនជាប់ចោទទេ គឺមានប្រភពចេញមកពីការសន្និតទុកជាមុនថាគ្មានទោស។ បើទោះបីជាជនជាប់ចោទមិននិយាយអ្វីទាំងអស់ ហើយមិនបង្ហាញភស្តុតាងអ្វីទាល់តែសោះក៏ដោយ ក៏ជនចាប់ចោទត្រូវបានឱ្យរួចផុតពីបទចោទប្រសិនបើអយ្យការមិនអាចបង្ហាញភស្តុតាងដាក់បន្ទុក ឬអាចនិយាយម្យ៉ាងទៀតថា ជនជាប់ចោទពុំមានកាតព្វកិច្ចត្រូវបង្ហាញភស្តុតាងដើម្បីបង្ហាញថាខ្លួនជាជនគ្មានទោសនោះឡើយ។

កាន់តែជាក់លាក់ទៀត ការសន្និតទុកជាមុនថាគ្មានទោសតម្រូវឱ្យ៖

[54] ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ("OHCHR"), សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (ផ្នែកទី ១), ជំពូក ៦ ទំព័រ ២១៩, http://bit.ly/1jp0Xxn។

i. តុលាការ ឬសាលាក្ដីមិនត្រូវធ្វើការសម្រេចជាមុនចំពោះសំណុំរឿងដែលនាំមកចំពោះមុខខ្លួនឡើយ។

ii. ពិរុទ្ធភាពហួសពីវិមតិសង្ស័យ ចាំបាច់ត្រូវបង្ហាញភស្ដុតាងដោយអយ្យការ។

iii. ការប្រព្រឹត្តចំពោះជនជាប់ចោទ មិនត្រូវធ្វើឡើងក្នុងលក្ខណៈដែលបង្ហាញថា ជនជាប់ចោទមានពិរុទ្ធភាពនោះឡើយ។

iv. ប្រព័ន្ធផ្សព្វផ្សាយគួរចៀសវាងការផ្សព្វផ្សាយព័ត៌មានទាំងឡាយណាដែលបំផ្លាញដល់ការសន្មតទុកជាមុនថាគ្មានទោសឡើយ។

v. អាជ្ញាធរសាធារណៈក៏គួរចៀសវាងការធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈណាដែលអាចបំផ្លាញដល់ការសន្មតជាមុននេះដែរ។[55]

## តួលេខទី ១០៖ សិទ្ធិនៅស្ងៀម

**តើចៅក្រមបានប្រាប់ និងពន្យល់ជនជាប់ចោទពីសិទ្ធិនៅស្ងៀម ដែរឬទេ ?**




ទាក់ទងជាមួយសិទ្ធិនៅស្ងៀម ទិន្នន័យដែលបានចងក្រងបង្ហាញថា ក្នុងសំណុំរឿងភាគច្រើនលើសលប់ (៦៥%) ចៅក្រមសាលាឧទ្ធរណ៍មិនបានប្រាប់ និងមិនបានពន្យល់ជនជាប់ចោទពីសិទ្ធនៅស្ងៀមទេ។ ការអនុវត្តដែលពាក់ព័ន្ធនឹងការសន្មតទុកជាមុនថាគ្មានទោស ចាំបាច់ត្រូវដោះស្រាយជាបន្ទាន់ ដោយហេតុថា សិទ្ធិនេះជាសិទ្ធិស្នូលមួយនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ នៅក្នុងកិច្ចប្រជុំជាមួយ ម.ស.ម.ក

[55] UN HRC, សេចក្ដីពន្យល់ទូទៅលេខ ៣២, ២០០៧, វាក្យខណ្ឌ ៣០, http://bit.ly/1zOqr0M។ ECtHR, *សំណុំរឿង Barberá, Messegué and Jabardo ទល់នឹងប្រទេសអេស្ប៉ាញ, ឆ្នាំ ១៩៩៨* វាក្យខណ្ឌ ៧៧, http://bit.ly/2D6kTpS។

អនុប្រធានសាលាឧទ្ធរណ៍បានលើកឡើងថានឹងផ្តើមធ្វើកិច្ចប្រជុំជាមួយចៅក្រមទាំងអស់ និងរម្លឹកចៅក្រមទាំងនោះអំពីសារសំខាន់នៃការធានានូវការគោរពចំពោះការសន្មតទុកជាមុនថាគ្មានទោសឲ្យបានពេញលេញ។[56]

## តួលេខទី ១១៖ ការសន្មតទុកជាមុនថាគ្មានទោស[57]




* ជនជាប់ចោទអវត្តមាន ឬពុំត្រូវបានឃុំខ្លួន។

នៅពេលដែលជនជាប់ចោទចូលរួមក្នុងសវនាការក្នុងឯកសណ្ឋានជាអ្នកទោស[58] ការសន្មតទុកជាមុនថាគ្មានទោសត្រូវបានប៉ះពាល់ជាខ្លាំង។ ករណីនេះ ជាពិសេសនៅពេលដែលពុំមានការបង្ហាញឱ្យឃើញពីភាពខុសគ្នារវាងអ្នកត្រូវបានឃុំខ្លួនរង់ចាំសវនាការ និងទណ្ឌិត។ នៅពេលដែលអ្នកត្រូវបានឃុំខ្លួនរង់ចាំសវនាការបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានជាអ្នកទោសនោះ ការបង្ហាញខ្លួននេះគឺដូចគ្នាទៅនឹងទណ្ឌិតដែលត្រូវបានកាត់ទោសជាស្ថាពរហើយ។ ដោយសារតែពុំមានការបញ្ជាក់ពីភាពខុសគ្នារវាងអ្នកជាប់ឃុំទាំងពីរប្រភេទ ការអនុវត្តបែបនេះធ្វើឱ្យមានការសន្មតយ៉ាងជាក់ស្តែងថា ជនជាប់ចោទគឺពិតជាជនល្មើសដែលត្រូវបាន

---

[56] ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បានជួបជាមួយអនុប្រធានសាលាឧទ្ធរណ៍ ឯកឧត្តម ប្លង់ សំណាង ឯកឧត្តម ញូង ធុល ព្រមទាំងអគ្គលេខាធិការរងរដ្ឋបាល លោកស្រី ស្រេង សូយ៉េត ដើម្បីពិភាក្សាលើរបកគំហើញនៅក្នុងរបាយការណ៍នេះ។

[57] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុប (៥៥៨ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៣៤០ សំណុំរឿង ដែលបានសង្កេតការណ៍។

[58] ចំណុចនេះសំដៅលើឯកសណ្ឋានពណ៌ខៀវរបស់ទណ្ឌិត ដែលក្រសួងមហាផ្ទៃបានចេញសេចក្តីប្រកាសថាឯកសណ្ឋានពណ៌ខៀវនេះគឺសម្រាប់ទណ្ឌិតដែលសាលក្រម ឬសាលដីកាបានចូលជាស្ថាពររួចហើយ។ សូមមើលព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក ឯកសណ្ឋានជនជាប់ឃុំ និង សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ចេញខែមិថុនា ឆ្នាំ ២០១៧ http://bit.ly/2BWjul3។

ផ្ដន្ទាទោសរួចហើយ ហេតុដូច្នេះ អាចជះឥទ្ធិពលដល់សេចក្ដីសម្រេចរបស់ចៅក្រម។ សូម្បីតែនៅពេលជនជាប់ចោទកំពុងតែជាប់ឃុំ ការណ៍ដែលថាជនជាប់ចោទបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានជាអ្នកទោស ក៏ធ្វើឱ្យមានការប៉ះពាល់ដល់គោលការណ៍យុត្តិធម៌ដូចគ្នាដែរ។ បញ្ហាដែលជនជាប់ចោទបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានជាអ្នកទោសនេះ ជាការទទួលខុសត្រូវរបស់អគ្គនាយកដ្ឋានពន្ធនាគារ។

ការប្រតិបត្តិល្អជាលក្ខណៈអន្តរជាតិនៅក្នុងយុត្តិធម៌ព្រហ្មទណ្ឌចង្អុលបង្ហាញឱ្យឃើញថា ជនរងការចោទប្រកាន់រឿងព្រហ្មទណ្ឌគួរតែអាចស្លៀកសម្លៀកបំពាក់របស់ខ្លួនពេលបង្ហាញខ្លួននៅក្នុងតុលាការ។ វិធានបទដ្ឋានអប្បបរមាអង្គការសហប្រជាជាតិសម្រាប់ការប្រព្រឹត្តចំពោះជនជាប់ឃុំ "វិធាននេស៊ុន មេនឌីឡា (Nelson Mandela)"[59] អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិក្នុងឆ្នាំ ២០១៥ ដែលបង្ហាញពីការប្រតិបត្តិល្អ ត្រូវបានទទួលស្គាល់ជាអន្តរជាតិសម្រាប់ការប្រព្រឹត្តចំពោះជនជាប់ឃុំចែងថា "ជនជប់ឃុំដែលពុំទាន់បានជំនុំជម្រះត្រូវបានអនុញ្ញាតឱ្យស្លៀកសម្លៀកបំពាក់របស់ខ្លួន ប្រសិនបើសម្លៀកបំពាក់នោះស្អាត និងសមស្រប។ ប្រសិនបើគាត់ស្លៀកពាក់ឯកសណ្ឋានពន្ធនាគារ ឯកសណ្ឋាននោះត្រូវខុសប្លែកពីឯកសណ្ឋានដែលត្រូវបានផ្ដល់ឱ្យទណ្ឌិត"។ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ជនរងការចោទប្រកាន់ត្រូវបានអនុញ្ញាតឱ្យស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួន នៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការព្រហ្មទណ្ឌ រហូតមានសេចក្ដីសម្រេចជាស្ថាពរ។ ហេតុនេះ ជនដែលរងការចោទប្រកាន់ត្រូវបានអនុញ្ញាតឱ្យបង្ហាញខ្លួនក្នុងតុលាការដោយស្លៀកសម្លៀកបំពាក់របស់ខ្លួន។ យ៉ាងហោចណាស់ ឯកសណ្ឋានពន្ធនាគារដែលពួកគេស្លៀកពាក់ចាំបាច់ត្រូវខុសប្លែកពីឯកសណ្ឋានរបស់ទណ្ឌិត។ ជាលទ្ធផលនៃការតស៊ូមតិរបស់ ម.ស.ម.ក មានការវិវត្តជាសន្សឹមៗ ដោយក្នុងនោះ ជនជាប់ចោទកាន់តែច្រើនឡើងបានបង្ហាញខ្លួនក្នុងឯកសណ្ឋានខុសប្លែកពីឯកសណ្ឋានរបស់ទណ្ឌិត។ បន្ថែមលើនេះទៀត មានករណីជាច្រើនដែលជនជាប់ចោទបានបង្ហាញខ្លួនចំពោះមុខតុលាការនៅក្នុងសម្លៀកបំពាក់របស់ខ្លួនផ្ទាល់។[60]

ទោះបីយ៉ាងក៏ដោយនៅមានករណីមួយចំនួនដែលជនជាប់ចោទនៅតែបង្ហាញខ្លួនក្នុងឯកសណ្ឋានដូចគ្នាជាមួយឯកសណ្ឋានជាទណ្ឌិត ជាហេតុប៉ះពាល់ដល់ការសន្មតទុកជាមុនថាគ្មានទោសរបស់ពួកគេ។ ថ្វីបើកិច្ចខិតខំដែលគួរឲ្យស្វាគមន៍យ៉ាងណាក្ដី ជាការចាំបាច់ណាស់ដែលការអនុវត្តក្នុងការអនុញ្ញាតឱ្យជនជាប់ចោទ

---

[59] អង្គមហាសន្និបាតអង្គការសហប្រជាជាតិ, វិធានបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិស្ដីពីការប្រព្រឹត្តិចំពោះជនជាប់ឃុំ សេចក្ដីសម្រេចលេខ ៧០/១៧៥ ឧបសម្ព័ន្ធ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៥, http://bit.ly/2tBwwLQ.

[60] នៅថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០១៨ ជនជាប់ចោទពីបទជួញដូរគ្រឿងញៀនត្រូវបានសាលាដំបូងខេត្តតាកែវកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលប្រាំឆ្នាំ ត្រូវបានបញ្ជូនទៅសាលាឧទ្ធរណ៍ ដើម្បីចូលរួមសវនាការឧទ្ធរណ៍លើសំណុំរឿងរបស់ខ្លួនក្នុងសម្លៀកបំពាក់ស៊ីវិល។ លោក កឹម សុខា អតីតប្រធានគណបក្សសង្គ្រោះជាតិ ក៏បានបង្ហាញខ្លួនក្នុងសវនាការដោយស្លៀកសម្លៀកបំពាក់របស់គាត់ដែរ កាលពីថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០១៨។

ស្លៀកសម្លៀកបំពាក់របស់ខ្លួន នៅពេលបង្ហាញខ្លួនក្នុងតុលាការត្រូវបានយកទៅអនុវត្តជាទូទៅ។ ដើម្បីធានាបាននូវភាពស៊ីសង្វាក់គ្នា អាជ្ញាធរគួរចេញគោលការណ៍ណែនាំឱ្យបានច្បាស់លាស់ដោយគូសបញ្ជាក់ថា ជនជាប់ឃុំដែលត្រូវបានឃុំខ្លួនរង់ចាំសវនាការ ឬអ្នកដែលស្ថិតក្នុងដំណាក់កាលជំនុំជម្រះ ប៉ុន្តែនៅពុំទាន់មានសេចក្តីសម្រេចស្ថាពរនៅឡើយ ចាំបាច់ត្រូវអនុញ្ញាតឱ្យបង្ហាញខ្លួនក្នុងតុលាការដោយស្លៀកសម្លៀកបំពាក់ស៊ីវិល។

តួលេខខាងលើបង្ហាញថា ជនជាប់ចោទចំនួន ៥០ នាក់ នៅតែបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានទណ្ឌិតនៅក្នុងពេលសវនាការ។ ការអនុវត្តបែបនេះ ធ្វើឱ្យប៉ះពាល់ដល់គោលការណ៍សន្មតទុកជាមុនថាគ្មានទោស។ ទោះជាយ៉ាងណាក្តី ពុំមានជនជាប់ចោទណាម្នាក់ត្រូវបានដាក់ខ្នោះនៅពេលសវនាការទេ។ ទោះបីជាយ៉ាងនេះក៏ដោយ ម.ស.ម.ក បានស្វាគមន៍ការលើកឡើងរបស់អនុប្រធានសាលាឧទ្ធរណ៍[61] ថាសាលាឧទ្ធរណ៍នឹងជួបពិភាក្សាជាមួយក្រសួងមហាផ្ទៃចំពោះបញ្ហានេះ និងជាមួយមណ្ឌលកែប្រែក្នុងគោលបំណងដើម្បីកំណត់នូវលទ្ធភាពដែលអាចអនុញ្ញាតឲ្យជនជាប់ចោទស្លៀកសម្លៀកបំពាក់ធម្មតានៅពេលសវនាការ។

### ២.២.៤. សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព (ការការពារខ្លួនប្រឆាំងនឹងការឆ្លើយការដាក់បន្ទុកលើខ្លួនឯង)

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ៥ | "គ្មានជនណាម្នាក់ ត្រូវទទួលទារុណកម្ម ឬការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបបានឡើយ។" |
| ក.អ.ស.ព.ន មាត្រា ១៤(៣)(ឆ) | "ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ មិនត្រូវបានបង្ខិតបង្ខំឱ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ។" |
| រដ្ឋធម្មនុញ្ញ មាត្រា ៣៨ | "ច្បាប់ហាមឃាត់រំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ [...]" |

[61] ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បានជួបជាមួយអនុប្រធានសាលាឧទ្ធរណ៍ ឯកឧត្តម ប្លង់ សំណាង ឯកឧត្តម ញូង ធុល ព្រមទាំងអគ្គលេខាធិការរងរដ្ឋបាល លោកស្រី ស្រេង សូយ៉េត ដើម្បីពិភាក្សាលើរបកគំឃើញនៅក្នុងរបាយការណ៍នេះ។

| | |
|---|---|
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៤៥ | "[...] ជនត្រូវចោទអាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែ ប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយគ្មានវត្តមានរបស់មេធាវី។ និទ្ទេសស្តីអំពីអវត្តមាននេះ ត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទ [...]" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២១ | "[...] ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ [...]" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៥ | "គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឱ្យមានការគោរពគោលការណ៍ដូចតទៅ៖ [...] មិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថបបន្ថោក តាមគ្រប់រូបភាពទៅលើរូបកាយ និងផ្លូវចិត្តរបស់អនីតិជនឡើយ [...]" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៦ | "អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើស ត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖ [...] សិទ្ធិមិនទទួលការបង្ខិតបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង [...]" |

មាត្រា ១៤(៣)(ធ) នៃ ក.អ.ស.ព.ន ជានានូវសិទ្ធិ "មិនត្រូវបានបង្ខិតបង្ខំឱ្យផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯង ឬឱ្យសារភាពពីពិរុទ្ធភាព"។[62] សិទ្ធិនេះមានពីរផ្នែក៖ ទីមួយ ជនសង្ស័យ ឬជនត្រូវចោទមិនត្រូវបានបង្ខិតបង្ខំ ឬជំរុញឱ្យផ្តល់ភស្តុតាងប្រឆាំងខ្លួនឯងឡើយ។ នៅពេលជនសង្ស័យ ឬជនត្រូវចោទសារភាព ការសារភាពនោះ ចាំបាច់ត្រូវធ្វើឡើងដោយពុំមានការបង្ខិតបង្ខំផ្លូវកាយ ឬផ្លូវចិត្តដោយផ្ទាល់ ឬដោយប្រយោលណាមួយឡើយ។[63] និយាយម្យ៉ាងទៀតបានន័យថា ជនសង្ស័យ/ជនត្រូវចោទទទួលបានសិទ្ធិដែលមិនអាចដកហូតបាន

---

[62] *សូមមើលផងដែរ* មាត្រា ៤០(២០(ខ)(iv) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

[63] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២, ឆ្នាំ២០០៧ វាក្យខណ្ឌ ៤១ http://bit.ly/1zOqr0M ។ សូមមើលផងដែរ៖ HRC CCPR សំណុំរឿង Deolall ទល់នឹង Guyana, សេចក្តីសម្រេចលេខ ៩១២/២០០០ នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/C/៨២/D/៩១២/២០០០, ឆ្នាំ២០០៤, វាក្យខណ្ឌ ៥.១ http://bit.ly/2FwT3jV។ HRC CCPR សំណុំរឿង Singarasa ទល់នឹងប្រទេសស្រីលង្កា សេចក្តីសម្រេចលេខ ១០៣៣/២០០១ នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/C/៨១/D/១០៣៣/២០០ ឆ្នាំ២០០៤ វាក្យខណ្ឌ ៧.៤ http://bit.ly/2EzddIS HRC CCPR, សំណុំរឿង Khuseynova and Butaeva ទល់នឹងប្រទេសតាជីគីស្ថាន, សេចក្តីសម្រេចលេខ ១២៦៣/២០០៤ និង ១២៦៤/២០០៤ នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/ C/៩៤/D/១២៦៣–១២៦៤/២០០៤ ឆ្នាំ២០០៨ វាក្យខណ្ឌ ៨៣ http://bit.ly/2mlnroL។

ក្នុងការមិនផ្តល់ភស្តុតាងដែលអាចត្រូវបានយកទៅប្រើប្រាស់ប្រឆាំងរូបខ្លួន។[64] ប្រសិនបើជនម្នាក់បដិសេធមិនផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯង ឬសារភាពទោសកំហុសទេនោះ ស្ថានភាពដែលចៅក្រមចេញសេចក្តីសន្និដ្ឋានជាអវិជ្ជមានពីការនៅស្ងៀមនេះ ត្រូវបានហាមឃាត់។[65] ក្នុងករណីរបស់អនីតិជន ច្បាប់នេះមានលក្ខណៈកាន់តែទូទៅថែមទៀត៖ អនីតិជនមិនត្រូវបានបង្ខិតបង្ខំ "ឱ្យផ្តល់សក្ខីកម្ម"ឡើយ។[66] សិទ្ធិនេះក៏ត្រូវបានធានាតាមមាត្រាទាំងអស់នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ជាពិសេស គឺមាត្រា ១៥[67] ពីព្រោះសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាពនេះគ្របដណ្តប់លើការហាមឃាត់ជាដាច់ខាតប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

## តួលេខទី ១២៖ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព [68]

**តើមានអ្វីមួយដែលបង្ហាញថា ជនជាប់ចោទត្រូវបានសួរចម្លើយដោយគ្មានវត្តមានមេធាវី ដែរឬទេ?**




[64] មាត្រា ១៤(៣)(ធ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ; *សូមមើលផងដែរ* មាត្រ ៤០(២)(ខ)(iv) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

[65] ECHR សំណុំរឿង Condron ទល់នឹងប្រទេសចក្រភពអង់គ្លេស ឆ្នាំ២០០០ វាក្យខណ្ឌ ៥៦ http://bit.ly/2mwfyO9។ ECHR សំណុំរឿង Beckles ទល់នឹងប្រទេសចក្រភពអង់គ្លេស ឆ្នាំ២០០២ វាក្យខណ្ឌ ៥៨ http://bit.ly/2mlfgsv។

[66] មាត្រា ៤០(២)(ខ)(iv) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

[67] មាត្រា ១៥ នៃ អនុសញ្ញាស្តីពីការប្រឆាំងទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ចែងថា៖ *"រដ្ឋភាគី ត្រូវធានាថា ឯកសារពោយការណ៍ទាំងឡាយ ដែលបង្កើតឡើងបានមកពីអំពើទារុណកម្ម មិនត្រូវយកមកសំអាងជាធាតុនៃភស្តុតាងក្នុងនីតិវិធីណាមួយឡើយ លើកលែងតែឯកសារពោយការណ៍នោះ ត្រូវបានធ្វើសម្រាប់ជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទនៅអំពើទារុណកម្ម។"* http://bit.ly/2z2NhXT។

[68] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ជនសរុប ៥៥៨នាក់ ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៣៤០ សំណុំរឿងដែលបានសង្កេតការណ៍។

តើមានអ្វីមួយដែលបង្ហាញថា ជនជាប់ចោទត្រូវបានគំរាមកំហែងឱ្យសារភាព ដែរឬទេ?




តើមានអ្វីមួយដែលបង្ហាញថា ជនជាប់ចោទទទួលរងអំពើហិង្សា ឬទារុណកម្មបង្ខំឱ្យសារភាព ដែរឬទេ?




* ទាំងជនជាប់ចោទ និងមេធាវីពុំមានវត្តមាននៅក្នុងសវនាការ ហេតុនេះ ពុំមាននរណាលើកបញ្ហានេះឡើង។

ក្នុងអំឡុងពេលធ្វើរបាយការណ៍ មានការកត់សម្គាល់ថា មានតែជនជាប់ចោទចំនួន ៤ នាក់ ក្នុងចំណោម ៥៥៨ នាក់ប៉ុណ្ណោះដែលបានលើកឡើងថា ពួកគេត្រូវបានសួរចម្លើយដោយគ្មានវត្តមានមេធាវី។ ជនជាប់ចោទចំនួន២០ នាក់បានលើកឡើងថា ពួកគេបានរងការគំរាមកំហែងឱ្យសារភាព ដែលជាសមមាត្រចំនួននេះមានកម្រិតតិចតួច។ លើសពីនេះ ជនជាប់ចោទចំនួន៤០ រូប ដែលពួកគេមួយចំនួនក៏ជាអ្នកដែលបានលើកឡើងថា ទទួលរងការគំរាមកំហែងចំពោះពួកគេនោះ បានបញ្ជាក់ថា ពួកគេទទួលរងការប្រើអំពើហិង្សា ឬទារុណកម្ម ដើម្បីឱ្យពួកគេសារភាពចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់ ក្នុងអំឡុងពេលសាកសួរដោយនគរបាលយុត្តិធម៌។

ថ្វីបើចំនួនសំណុំរឿងដែលមានសញ្ញាណបញ្ជាក់អំពីការបង្ខិតបង្ខំ ឬការធ្វើទារុណកម្មលើផ្លូវចិត្ត ឬផ្លូវកាយក្តីក្នុងអំឡុងពេលសួរចម្លើយមានចំនួនតិចតួចក្តី ប៉ុន្តែនេះជាបញ្ហាគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំង។ ទោះជានៅក្នុងសំណុំរឿងភាគច្រើនដែលជនជាប់ចោទ ឬមេធាវីការពារជនជាប់ចោទបានលើកឡើងអំពីបញ្ហាទាក់ទងនឹងការសារភាពក៏ដោយ ក៏ចៅក្រមនៅតែតម្កល់សាលក្រមដែលសម្រេចឱ្យជនជាប់ចោទមានពិរុទ្ធភាពនៅដដែល។ សាលាឧទ្ធរណ៍ចាំបាច់ត្រូវស៊ើបអង្កេតលើអំណះអំណាងទាំងអស់នេះឱ្យសព្វជ្រុងជ្រោយ។ ប្រសិនបើការលើកឡើងអំពីការបង្ខិតបង្ខំណាមួយ ត្រូវបានបង្ហាញជាភស្តុតាងថាជាការពិតក្រោយការស៊ើបអង្កេត ចៅក្រមមានកាតព្វកិច្ចតាមផ្លូវច្បាប់ ក្នុងការចេញសេចក្តីសម្រេចឱ្យរាល់ភស្តុតាងក្រោមការសារភាពដែលបានធ្វើឡើងនោះជាភស្តុតាងមិនអាចទទួលយកបានក្នុងតុលាការ និងមានមូលដ្ឋានសមហេតុផលដើម្បីជឿជាក់ថា ការសារភាពនោះត្រូវបានធ្វើឡើងដោយការបង្ខិតបង្ខំ។ ម្យ៉ាងទៀត ថ្វីបើបញ្ហានេះគួរត្រូវបានដោះស្រាយក្នុងដំណាក់កាលស៊ើបសួរក្តីក៏ចៅក្រមសាលាឧទ្ធរណ៍ចាំបាច់ត្រូវរក្សាការប្រុងប្រយ័ត្ន និងធានាថា រាល់អំណះអំណាងស្តីពីការ

បង្ខិតបង្ខំដែលពុំត្រូវបានដោះស្រាយក្នុងអំឡុងពេលមុនសវនាការនោះ ត្រូវបានស៊ើបអង្កេតសព្វគ្រប់ជ្រុងជ្រោយមុនពេលសវនាការត្រូវបានអនុញ្ញាតឱ្យបន្តទៅមុខទៀត។

### ២.២.៥. សិទ្ធិបង្ហាញពីការការពារខ្លួន (សិទ្ធិបង្ហាញភស្តុតាង)

| ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ | |
|---|---|
| ក.អ.ស.ព.ន<br>មាត្រា ១៤(៣)(ង) | "ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ត្រូវមានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយ ទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ១៥៣ | "ចៅក្រមស៊ើបសួរ អាចស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលចម្លើយនោះអាចមានប្រយោជន៍នៅក្នុងការសម្តែងឱ្យឃើញការពិត [...] ចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីផងដែរ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ១៥៤ | "មុននឹងឆ្លើយទៅនឹងសំណួរ សាក្សីម្នាក់ៗ ត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានិយាយតែការពិត។ ទម្រង់នៃសម្បថ ត្រូវធ្វើដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃក្រមនេះ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ២៩៨ | "ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីអាចនាំចូលរួមក្នុងសវនាការនូវសាក្សីទាំងឡាយណាដែលព្រះរាជអាជ្ញាមិនបានកោះហៅដោយខ្លួនជាអ្នកចេញសោហ៊ុយ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ៣២១ | "លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ អាចជូនបានដោយសេរី។ តុលាការថ្លឹងថ្លែងដោយឥតស្សរចិត្ត អំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យបានដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន។ តុលាការសម្អាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ។ ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ។ |

| | |
|---|---|
| | ការឆ្លើយឆ្លងរវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួន និងអាចយកមកធ្វើជាភស្តុតាងបានឡើយ។" |
| **ក្រមនីតិវិធីព្រហ្មទណ្ឌ** មាត្រា ៣២៤ | "នៅពេលបើកកិច្ចពិភាក្សាដេញដោល ភាគីអាចសុំឱ្យតុលាការស្តាប់ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលដែលមានវត្តមាននៅក្នុងបន្ទប់ ប៉ុន្តែ មិនបានកោះហៅឱ្យបានត្រឹមត្រូវទេ។ ការស្តាប់ចម្លើយសាក្សីនេះ ត្រូវមានការយល់ព្រមពីប្រធានសវនាការ។ ក្រឡាបញ្ជីស្រង់អត្តសញ្ញាណ និងអញ្ជើញសាក្សីនេះឱ្យថយទៅនៅបន្ទប់រង់ចាំ។" |
| **ក្រមនីតិវិធីព្រហ្មទណ្ឌ** មាត្រា ៣២៦ | "ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ប្រធានសវនាការអាចស្តាប់នូវចម្លើយមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ដែលបានចូលរួមក្នុងការស៊ើបអង្កេតក្នុងឋានៈជាសាក្សី។ ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរសួរ។ គ្រប់ការលើកសំណួរទាំងអស់ ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងៗទៀត ត្រូវសួរតាមរយៈសវនាការ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេចចិត្តដោយឥស្សរចិត្តថា តើសំណួរនេះត្រូវតែសួរ ឬទេ។" |
| **ក្រមនីតិវិធីព្រហ្មទណ្ឌ** មាត្រា ៣២៨ | "មុននឹងឆ្លើយរួចហើយ សាក្សីនីមួយៗ ត្រូវស្បថថា ខ្លួននិយាយតែការពិតស្របតាមសាសនា ឬជំនឿរបស់ខ្លួន។" |
| **ក្រមនីតិវិធីព្រហ្មទណ្ឌ** មាត្រា ៣៩៤ | "ក្រោយពេលសួរចម្លើយជនជាប់ចោទរួច ប្រធានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថា មានប្រយោជន៍។ សាក្សី និងអ្នកជំនាញ នឹងត្រូវបានគេស្តាប់ចម្លើយ លុះត្រាតែតុលាការបង្គាប់ឱ្យស្តាប់ចម្លើយជនទាំងនេះ។" |
| **ច្បាប់ស្តីពីយុត្តិធម៌អនីតិជន** មាត្រា ៦ | "អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖ [.........] សិទ្ធិបង្ហាញភស្តុតាង។ សិទ្ធិស្នើសុំឱ្យកោះហៅសាក្សី និងសួរសាក្សី [...]." |

រាល់សេចក្តីសម្រេចទាំងអស់របស់តុលាការ ត្រូវតែផ្អែកទាំងស្រុងលើភស្តុតាងដែលបានបង្ហាញនៅក្នុងដំណាក់កាលនៃការជំនុំជម្រះ។ ហេតុដូច្នេះ នេះជាការសំខាន់ដែលភាគីនីមួយៗមានឱកាសដើម្បីបង្ហាញ

ភស្តុតាង និងហៅសាក្សីនានាដែលគាំទ្រដល់សំណុំរឿងរបស់ខ្លួន។[69] នេះជារឿងសំខាន់ដូចគ្នាដែលភាគីនីមួយៗត្រូវបានផ្តល់ឱកាសដើម្បីសួរដេញដោលសាក្សី និងបដិសេធភស្តុតាងដែលខ្លួនមិនទទួលយក។ ថ្វីបើវិធាននៃភស្តុតាងតាមរយៈសក្ខីកម្មជាលាយលក្ខណ៍អក្សរ (មានន័យថាភស្តុតាងដែលមិនបានផ្តល់ក្នុងអំឡុងពេលសវនាការ) មិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្តីក៏ការធ្វើបែបនេះត្រូវអនុលោមតាមច្បាប់សិទ្ធិមនុស្សដែរ ហើយជនជាប់ចោទមានសិទ្ធិបដិសេធ និងដេញដោលសួរសាក្សី នៅពេលដែលសាក្សីនោះបានផ្តល់សក្ខីកម្ម ឬនៅដំណាក់កាលបន្ទាប់ទៀតនៃនីតិវិធីមុនសវនាការផ្ទាល់។[70] ជាចុងក្រោយ ដោយអនុលោមតាមច្បាប់សិទ្ធិមនុស្ស នៅពេលជនសង្ស័យឬជនត្រូវចោទផ្តល់ការសារភាព ការសារភាពនោះត្រូវធ្វើឡើងដោយពុំមានការបង្ខិតបង្ខំដោយផ្ទាល់ ឬដោយប្រយោលតាមផ្លូវកាយ ឬតាមផ្លូវចិត្តណាមួយឡើយ។[71] ប្រសិនបើបុគ្គលនោះអះអាងថាមានការរំលោភបំពានលើសិទ្ធិរបស់ខ្លួន បន្ទុកនៃការបង្ហាញភស្តុតាងត្រូវធ្លាក់លើភាគីដែលបានលើកពីការសារភាពនោះមកបង្ហាញថា ការសារភាពនោះពុំត្រូវបានធ្វើឡើងដោយការបង្ខិតបង្ខំ ហើយបញ្ហានេះពុំមែនជាបន្ទុករបស់ជនជាប់ចោទក្នុងការបង្ហាញថា ការសារភាពនោះត្រូវបានធ្វើឡើងដោយការបង្ខិតបបង្ខំនោះឡើយ។[72] ភស្តុតាងទទួលបានដែលជាការរំលោភបំពានលើសិទ្ធិនេះ ជាភស្តុតាងមិនអាចទទួលយកបាននៅក្នុងសវនាការ។[73]

ជារឿងគួរកត់សម្គាល់មួយ ដែលបានមកពីការប្រមូលទិន្នន័យលើសំណុំរឿងទាំង ៣៤០ ម.ស.ម.ក បានចុះសង្កេតការណ៍នោះ ពុំមានការលើកឡើងថា ភាគីណាមួយមិនត្រូវបានផ្តល់ឱកាសដើម្បីហៅសាក្សីនោះ

---

[69] មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[70] សូមមើលឧទាហរណ៍ ECtHR *សំណុំរឿង Mirilashvili ទល់នឹងប្រទេសរុស្ស៊ី* ឆ្នាំ២០០៨ វាក្យខណ្ឌ ១៦៣ http://bit.ly/2Fsxn8u។ ECtHR *សំណុំរឿង Asch ប្រទេសអូទ្រីស* ឆ្នាំ១៩៩១ វាក្យខណ្ឌ ២៧ http://bit.ly/2ARSDB5។ ECtHR សំណុំរឿង Isgrò ទល់នឹងប្រទេសអ៊ីតាលី ឆ្នាំ១៩៩១ វាក្យខ័ណ្ឌ ៣៤ http://bit.ly/2Fv1FYo។ ECtHR *សំណុំរឿង Kostovski ទល់នឹងប្រទេសហូឡង់ដ៍* ឆ្នាំ ១៩៨៩ វាក្យខណ្ឌ ៤១ http://bit.ly/2D3ndhf។

[71] UN HRC សេចក្តីពន្យល់ទូទៅលេខ ៣២ ២០០៧ វាក្យខណ្ឌ ៤១ http://bit.ly/1zOqr0M។ សូមមើលផងដែរ៖ UN HRC *សំណុំរឿង Deolall ទល់នឹង Guyana* សេចក្តីសម្រេចលេខ ៩១២/២០០០ នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/C/៨២/D/៩១២/២០០០ ឆ្នាំ២០០៤ វាក្យខណ្ឌ ៥.១ http://bit.ly/2FwT3jV។ UN HRC *សំណុំរឿង Singarasa ទល់នឹងប្រទេសស្រីលង្កា*, សេចក្តីសម្រេចលេខ ១០៣៣/២០០១ នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/C/៨១/D/១០៣៣/២០០ ឆ្នាំ២០០៤ វាក្យខណ្ឌ ៧.៤ http://bit.ly/2EzddIS។ UN HRC *សំណុំរឿង Khuseynova and Butaeva ទល់នឹងប្រទេសតាជីគីស្ថាន* សេចក្តីសម្រេចលេខ ១២៦៣/២០០៤ និង ១២៦៤/២០០៤ នៅក្នុងឯកសាររបស់ អ.ស.ប CCPR/ C/៩៤/D/១២៦៣–១២៦៤/២០០៤ ឆ្នាំ២០០៨ វាក្យខណ្ឌ ៨.៣ http://bit.ly/2mInroL។

[72] UN HRC សេចក្តីពន្យល់ទូទៅលេខ ៣២ ២០០៧ វាក្យខណ្ឌ ៤១ http://bit.ly/1zOqr0M។ សូមមើលផងដែរ៖ UN HRC CCPR *សំណុំរឿង Singarasa ទល់នឹងប្រទេសស្រីលង្កា* សេចក្តីសម្រេចលេខ ១០៣៣/២០០១ នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/C/៨១/D/១០៣៣/២០០ 2004 វាក្យខណ្ឌ ៧.៤ http://bit.ly/2EzddIS។ HRC CCPR *សំណុំរឿង Khuseynova and Butaeva ទល់នឹងប្រទេសតាជីគីស្ថាន* សេចក្តីសម្រេចលេខ ១២៦៣/២០០៤ និង ១២៦៤/២០០៤ នៅក្នុងឯកសាររបស់ អ.ស.ប លេខ CCPR/C/94/D/១២៦៣–១២៦៤/២០០៤ ឆ្នាំ២០០៨ វាក្យខណ្ឌ ៨.៣ http://bit.ly/2mInroL។

[73] UN HRC សេចក្តីពន្យល់ទូទៅលេខ ៣២ ឆ្នាំ២០០៧ វាក្យខណ្ឌ ៦.៤១ http://bit.ly/1zOqr0M។ UN HRC សេចក្តីពន្យល់ទូទៅលេខ ២៩ ឆ្នាំ២០០១ វាក្យខណ្ឌ ៧.១៥ http://bit.ly/2D55AO0។

ឡើយ។ ទោះបីជាយ៉ាងនេះក៏ដោយ សិទ្ធិបង្ហាញភស្តុតាងនៅតែជាបញ្ហាប្រឈមដោយសារហេតុផលចម្បងពីរយ៉ាង។ អ្នកសង្កេតការណ៍បានកត់សម្គាល់ឃើញថា ក្នុងចំណោមសំណុំរឿងមួយចំនួនតូចប៉ុណ្ណោះដែលសាក្សីមានវត្តមាននៅពេលសវនាការ (១២ ករណី ក្នុងចំណោមសំណុំរឿងសរុប ៣៤០ ករណី) សាក្សីបានស្ថិតនៅក្នុងបន្ទប់សវនាការនៅមុនពេលសាកសួរ ក្នុងសំណុំរឿងចំនួន ៨ ក្នុងចំណោមសំណុំរឿងទាំង ១២ ដែលអាចធ្វើឱ្យសក្ខីកម្មរបស់សាក្សីទាំងនោះ រងឥទ្ធិពលតាមរយៈការស្តាប់ឮសវនាការពីជនដទៃទៀត។ ការអនុវត្តប្រសើរជាងនេះ គួរតែឱ្យសាក្សីចេញពីបន្ទប់សវនាការ និងមិនត្រូវត្រឡប់ទៅបន្ទប់សវនាការវិញ រហូតទាល់តែសាក្សីនោះត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្ម។

លើសពីនេះទៀត សាលាឧទ្ធរណ៍ត្រូវតែធានាថា ភស្តុតាងដែលត្រូវយកមកថ្លឹងថ្លែងមានគុណតម្លៃគ្រប់គ្រាន់ (ភាពគួរជឿជាក់ និងភាពពិតប្រាកដ) និងធានាថា ភាគីទាំងអស់មានឱកាសក្នុងការជំទាស់នឹងភស្តុតាងនោះ។ ទិន្នន័យដែលបានប្រមូលនៅអំឡុងពេលសង្កេតការណ៍សវនាការបង្ហាញថា គុណភាពនៃភស្តុតាងដែលបានបង្ហាញ គឺជាប្រការគួរឱ្យព្រួយបារម្ភជាខ្លាំង។ ភស្តុតាងជាច្រើនដែលបានបង្ហាញនៅក្នុងសវនាការដែលបានសង្កេតការណ៍ គឺជាការសារភាព ឬភស្តុតាងជាឯកសារ។ គុណភាព និងចំនួននៃភស្តុតាងដែលបានបង្ហាញ និងពិចារណាក្នុងពេលសវនាការជំនុំជម្រះ គឺមានភាពចាំបាច់ដើម្បីធានាថា បុគ្គលគ្រប់រូបត្រូវបានតុលាការរកឃើញពីពិរុទ្ធភាពហួសពីវិមតិសង្ស័យ។ បន្ថែមពីលើភស្តុតាងជាឯកសារ ចៅក្រម និងព្រះរាជអាជ្ញាគួរតែមានភាពសកម្មក្នុងការស្វែងរក និងពិនិត្យភស្តុតាងប្រភេទដទៃទៀតដែលពាក់ព័ន្ធដូចជា សាក្សីផ្ទាល់ ភស្តុតាងវេជ្ជសាស្ត្រ និងភស្តុតាងកោសល្យវិច័យជាដើម។ ការសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក បង្ហាញឱ្យឃើញថាពុំមាននិន្នាការពិនិត្យលើភស្តុតាងប្រភេទនេះ នៅក្នុងសាលាឧទ្ធរណ៍ឡើយ។

### ២.២.៦. សិទ្ធិទទួលបានសេចក្តីសម្រេចមានសម្អាងហេតុ

សិទ្ធិទទួលបានសេចក្តីសម្រេចមានសម្អាងហេតុ នៅជាប់ជាមួយនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងត្រូវបានរួមបញ្ចូលនៅក្នុងសិទ្ធិទទួលបានសេចក្តីប្រកាសសេចក្តីសម្រេចជាសាធារណៈ។ យោងតាមបទដ្ឋានអន្តរជាតិ បុគ្គលដែលត្រូវបានកាត់ឱ្យជាប់ទោសមានសិទ្ធិទទួលបានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរក្នុងរយៈពេលមួយសមរម្យ ហើយសេចក្តីសម្រេចនេះ ត្រូវមានសម្អាងហេតុត្រឹមត្រូវ ក្នុងការបើកផ្លូវប្តឹងជំទាស់ ដើម្បីឱ្យជនជាប់ចោទអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពក្នុងការស្នើឱ្យតុលាការជាន់ខ្ពស់ពិនិត្យពីការចោទប្រកាន់ និងការផ្តន្ទាទោសមកលើខ្លួនដោយផ្អែកលើច្បាប់។[74] ក្នុងបរិបទកម្ពុជា សិទ្ធិទទួលបាន

[74] UN HRC, *V. Francis v. Jamaica*, សេចក្តីសម្រេចលេខ No. 320/1988, in UN doc. CCPR/C/47/D/320/1988, ( vol. II ) 1993, p.៦៦, វាក្យខណ្ឌ ១២.២ http://bit.ly/1gfuZQw.

សេចក្តីសម្រេចមានសម្អាងហេតុមានភាពចាំបាច់ណាស់ដោយហេតុថា ជនជាប់ចោទ និងអយ្យការមានលទ្ធភាពប្តឹងសារទុក្ខលើសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ទៅកាន់តុលាការកំពូលបន្ថែមទៀត។

### តួលេខទី ១៣៖ ទិដ្ឋភាពទូទៅនៃសាលដីការបស់សាលាឧទ្ធរណ៍ [75]




* ក្រុមការងារអ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ពុំមានវត្តមាននៅពេលប្រកាសសាលដីកា។

ក្នុងសំណុំរឿង ៦៧% ជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព។ អ្នកសង្កេតការណ៍របស់ ម.ស.ម.ក ក៏បានកត់សម្គាល់ផងដែរថា ក្នុងសំណុំរឿងមួយចំនួនដែលគួរកត់សម្គាល់ សាលាឧទ្ធរណ៍បានតម្កល់សេចក្តីសម្រេចរបស់សាលាដំបូង។ ចំណុចនេះ ដែលបូករួមជាមួយកង្វះការអានសម្អាងហេតុនៅក្នុងសេចក្តីសម្រេចបង្កើតឱ្យមានមូលហេតុគួរឱ្យព្រួយបារម្ភ ថាតើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទត្រូវបានគោរព ឬយ៉ាងណា។

ក្នុងសំណុំរឿងស្ទើរទាំងអស់ ចៅក្រមមិនបានផ្តល់មូលដ្ឋានហេតុផលចំពោះសេចក្តីសម្រេចរបស់ខ្លួនឡើយ។ ចៅក្រមពុំបានលើកឡើងអំពីវិធានច្បាប់ និងភស្តុតាងដែលជាមូលដ្ឋាននៃសាលដីការបស់ខ្លួនឡើយ។ ផ្ទុយទៅវិញ ចៅក្រមគ្រាន់តែអាន និងប្រកាសសេចក្តីសម្រេចតែប៉ុណ្ណោះ។

## ២.២.៧. សវនាការទាក់ទងនឹងអនីតិជន

**ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ**

[75] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុប (៥៥៨ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៣៤០ សំណុំរឿង ដែលបានសង្កេតការណ៍។

| | |
|---|---|
| ក.អ.ស.ព.ន<br>មាត្រា ១៤(១) | ក.អ.ស.ព.ន មាត្រា ១៤(១)៖ "សារព័ត៌មាន និងសាធារណជន អាចមិនឱ្យចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការ [...] នៅពេលដែលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគី តម្រូវឱ្យធ្វើដូច្នេះ [...] ប៉ុន្តែការចេញសាលក្រមទាំងអស់ អំពីរឿងព្រហ្មទណ្ឌ រដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ លើកលែងតែផលប្រយោជន៍អនីតិជនត្រូវផ្សេងពីនេះ ឬរឿងក្ដីអំពីទំនាក់ទំនងគ្រួសារ ឬអាណាព្យាបាលរបស់កុមារ។" |
| អ.ស.ក<br>មាត្រា ៤០(២)(ខ)(vii) | "រដ្ឋភាគីត្រូវធានា ជាពិសេសថា/...] ត្រូវគោរពយ៉ាងពេញលេញនូវសិទ្ធិនៃជីវិតឯកជនរបស់កុមារ នៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធី។" |
| អ.ស.ក<br>មាត្រា ៤០(៤) | "ចំណាត់ថ្នាក់មួយចំនួនដូចជា ការថែទាំ របៀបណែនាំ និងដីកាតាមដានពិគ្រោះយោបល់ ការសាកល្បងឱ្យនៅក្រៅឃុំ ការថែទាំដោយឪពុក-ម្ដាយធម៌ កម្មវិធីអប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈនិងមធ្យោបាយផ្សេងៗទៀតជំនួសការថែទាំតាមស្ថាប័ន ត្រូវធ្វើឱ្យមាន ដើម្បីធានាថា កុមារទទួលបាននូវចំណាត់ការដែលសមស្រប ចំពោះសុខុមាលភាពរបស់ខ្លួន និងមានសមាមាត្រទៅនឹងស្ថានភាពរបស់កុមារ និងបទល្មើស។" |
| រដ្ឋធម្មនុញ្ញ<br>មាត្រា ៣១ | "ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុង [...] កតិកសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹង [...] សិទ្ធិកុមារ។" |
| រដ្ឋធម្មនុញ្ញ<br>មាត្រា ៤៨ | "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្ដីពីកុមារ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ១០០ | "កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុក ម្ដាយ ដល់អ្នកតំណាងស្របច្បាប់ ឬអ្នកទទួលភារកិច្ចលើអនីតិជន។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ<br>មាត្រា ២១២ | "អនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្ដោះអាសន្នទេ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឱ្យឪពុកម្ដាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្ន រង់ចាំសេចក្ដីសម្រេចរបស់តុលាការ។" |

| | |
|---|---|
| ក្រមព្រហ្មទណ្ឌ<br>មាត្រា ៣៩ | "អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។" |
| ក្រមព្រហ្មទណ្ឌ<br>មាត្រា ៤០ | "វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមានដូចតទៅ ៖ ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ការប្រគល់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៥ | "គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឱ្យមានការគោរពគោលការណ៍ដូចតទៅ៖ ត្រូវយកចិត្តទុកដាក់ និងពិចារណារាល់សកម្មភាពពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេស ជានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា [...] ត្រូវផ្តល់ឱកាសឱ្យអនីតិជនសម្តែងមតិដោយសេរី ហើយទស្សនៈនោះត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងស្របទៅតាមអាយុ ការរីកចម្រើនផ្នែករូបកាយ បញ្ញាស្មារតី និងកម្រិតនៃការយល់ដឹងរបស់អនីតិជនចំពោះសកម្មភាពរបស់ខ្លួន។ ត្រូវអនុវត្តទៅតាមនីតិវិធីកុមារមេត្រី[76]។ ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្តន្ទាទោសអនីតិជនជាវិធានចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន [...]" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៦ | "អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖<br>• សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី<br>• សិទ្ធិមិនទទួលការបង្ខិតបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង<br>• សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន |

[76] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៤ ចំណុច ៧។

| | |
|---|---|
| | • សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល<br>• សិទ្ធិទទួលបានការឱ្យដំណឹងអំពីបទចោទប្រកាន់<br>• សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់<br>• សិទ្ធិទទួលបានជំនួយពីមេធាវីដោយច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី<br>• សិទ្ធិឱ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្ដី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន<br>• សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកមកម្រៃ កាលបើមានការចាំបាច់<br>• សិទ្ធិបង្ហាញភស្ដុតាង<br>• សិទ្ធិស្នើសុំឱ្យកោះហៅសាក្សី និងសួរសាក្សី<br>• សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ<br>• សិទ្ធិស្នើសុំឱ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ<br>• សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស<br>• សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន។” |
| **ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន**<br>មាត្រា ៣៩ | “ការឃុំខ្លួនអនីតិជនបណ្ដោះអាសន្នជាវិធានការចុងក្រោយ [...]” |
| **ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន**<br>មាត្រា ៤៧ | “ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមរឿងក្ដីអនីតិជន ត្រូវធ្វើឡើងក្នុងសវនាការអសាធារណៈ [...]” |
| **ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន**<br>មាត្រា ៤៨ | “[...] ក្នុងកាលៈទេសៈពិសេស មេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំឱ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្ដាប់ចម្លើយ។” |

| | |
|---|---|
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៤៩ | "ក្នុងករណីតុលាការឃើញថា អនីតិជនជាប់ចោទមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចឱ្យអនីតិជនរួចផុតពីបទចោទប្រកាន់ ហើយបង្គាប់ឱ្យដោះលែងអនីតិជនដែលជាប់ឃុំឃាំងជាបន្ទាន់ ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឱ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់ [...]" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៥៤ | "សាលក្រមត្រូវប្រកាសនៅពេលសវនាការ ក្រោយពីធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ។ ជាគោលការណ៍សាលក្រមត្រូវប្រកាសជាអសាធារណៈនៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅក្នុងរឿងក្តី។ សាលក្រមអាចប្រកាសកំបាំងមុខអនីតិជនបាន ក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឱ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជននោះ។" |
| ច្បាប់ស្តីពីយុត្តិធម៌អនីតិជន<br>មាត្រា ៥៧ | "[...] ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំការជំនុំជម្រះ សាលាឧទ្ធរណ៍ ឬតុលាការកំពូលត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឱ្យមានសេរីភាព។ ក្នុងករណីរឿងក្តីត្រូវបានលើកពេលជំនុំជម្រះ សាលាឧទ្ធរណ៍ ឬតុលាការកំពូលត្រូវពិចារណាផងដែរអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឱ្យមានសេរីភាព។" |

យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារដែលបានកំណត់និយមន័យកុមារថា ជាបុគ្គលទាំងឡាយណាដែលមានអាយុក្រោម ១៨ ឆ្នាំ[77] រដ្ឋភាគីត្រូវព្យាយាមលើកកម្ពស់ឱ្យមានការបង្កើតច្បាប់ នីតិវិធី អាជ្ញាធរ និងស្ថាប័នដែលត្រូវអនុវត្តជាពិសេសចំពោះកុមារជាជនជាប់ចោទ ឬកុមារដែលត្រូវបានទទួលស្គាល់ថាបានបំពានច្បាប់ព្រហ្មទណ្ឌ ហើយជាពិសេស៖

i. ការកំណត់អាយុអប្បបរមាដែលនៅក្រោមអាយុនេះកុមារត្រូវបានសន្មតថា ពុំមានសមត្ថភាពអាចបំពានច្បាប់ព្រហ្មទណ្ឌបាន និង

ii. នៅពេលណាដែលសមស្រប និងអាចទៅរួចវិធានការដើម្បីដោះស្រាយជាមួយកុមារមិនត្រូវធ្វើតាមនីតិវិធីតុលាការនោះទេ ដោយសារថាកុមារត្រូវបានការការពារពេញលេញចំពោះសិទ្ធិមនុស្ស និងការ

[77] អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ១៖ "សម្រាប់គោលបំណងនៃអនុសញ្ញានេះ កុមារគឺជាមនុស្សមានអាយុក្រោម ១៨ ឆ្នាំ លើកលែងតែក្រោមច្បាប់ដែលត្រូវអនុវត្តចំពោះកុមារ នីតិភាពត្រូវបានកំណត់ទាបជាងនេះ។"

ការពារផ្នែកច្បាប់[78]។ ម្យ៉ាងទៀតថា ច្បាប់សិទ្ធិមនុស្សអន្តរជាតិលើកកម្ពស់ការប្រើប្រាស់នីតិវិធីក្រៅតុលាការ ក្នុងករណីដែលកុមារត្រូវបានប្តឹងចោទប្រកាន់ ឬទទួលស្គាល់ថាបានបំពានច្បាប់ព្រហ្មទណ្ឌ នៅពេលណាសមស្រប និងជាពិសេសក្នុងករណីនៃបទល្មើសតូចតាច ដូចជាការលួចអីវ៉ាន់នៅតាមហាងលក់ទំនិញ ឬបទល្មើសប៉ះពាល់ទ្រព្យសម្បត្តិដទៃទៀត។[79]

បន្ថែមលើនេះទៀត ចំណាត់ការមួយចំនួន ដូចជា ការថែទាំ របៀបណែនាំ និងដឹកាតាមដាន ការពិគ្រោះយោបល់ ការសាកល្បងឲ្យនៅក្រៅឃុំ ការថែទាំដោយអាណាព្យាបាល កម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមធ្យោបាយផ្សេងៗទៀត ជំនួសការថែទាំតាមស្ថាប័ន ត្រូវធ្វើឲ្យមាន ដើម្បីធានាថាកុមារទទួលបាននូវចំណាត់ការដែលសមស្រប ចំពោះសុខុមាលភាពរបស់ខ្លួន និងសមាមាត្រទៅនឹងស្ថានភាពរបស់កុមារ និងបទល្មើស។ [80]

អនីតិជន ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិទទួលបានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទាំងអស់ដែលត្រូវអនុវត្តចំពោះមនុស្សពេញវ័យ ក៏ដូចជាមានសិទ្ធិទទួលបានការការពារបន្ថែម ដោយត្រូវពិចារណាសព្វជ្រុងជ្រោយទៅលើអាយុ ភាពចាស់ទុំ និងការអភិវឌ្ឍផ្នែកសតិបញ្ញារបស់កុមារ។ ក.អ.ស.ព.ន និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ("អ.ស.ក") ដែលបានចូលជាធរមានក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩២ មានចែងនូវមាត្រាជាក់លាក់ស្តីពីការប្រព្រឹត្តចំពោះអនីតិជនក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។ លិខិតូបករណ៍គតិយុត្តិទាំងអស់នេះ បានទទួលការគាំទ្រពីវិធាន និងគោលការណ៍ណែនាំអន្តរជាតិជាច្រើន។ ដូចមានបញ្ជាក់ខាងលើហើយថា បទប្បញ្ញត្តិផ្នែកច្បាប់ជាច្រើនក្នុងច្បាប់កម្ពុជា មានចែងបន្ថែមទៀតអំពីការប្រព្រឹត្តចំពោះអនីតិជន ដែលខុសប្លែកពីការប្រព្រឹត្តចំពោះមនុស្សពេញវ័យលើវិស័យសំខាន់ៗជាច្រើន។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានអនុម័តក្នុងឆ្នាំ ២០១៦ ដើម្បីធានាសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

---

[78] មាត្រា ៤០ (៣) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

[79] គណៈកម្មាធិការស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ១០ ឆ្នាំ២០០៧ វាក្យខណ្ឌ ២៤ ២៥ http://bit.ly/1fbEoKP។ គណៈកម្មាធិការស្តីពីសិទ្ធិកុមារ គឺជាស្ថាប័នផ្លូវការបង្កើតឡើងដោយ មាត្រា ៤៣ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ដើម្បីពិនិត្យលើវឌ្ឍនភាពដែលរដ្ឋភាគីសម្រេចបានទាក់ទងនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ និងដើម្បីផ្តល់មតិយោបល់ និងអនុសាសន៍លើអនុសញ្ញាស្តីពីសិទ្ធិកុមារ (មាត្រា ៤៥ (ឃ))។

[80] មាត្រា ៤០(៤) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

## តួលេខទី ១៤(ក)៖ ការឃុំខ្លួនអនីតិជនមុនការជំនុំជម្រះ[81]

អាយុជនជាប់ចោទនៅក្នុងពេលឃុំខ្លួនបណ្ដោះអាសន្ន?




* ជនជាប់ចោទជាអនីតិជនពុំត្រូវបានឃុំខ្លួន។

ក្នុងអំឡុងពេលធ្វើរបាយការណ៍ ក្នុងចំណោមជនជាប់ចោទទាំង ៥៥៨ នាក់ ពាក់ព័ន្ធក្នុងសំណុំរឿងដែលយើងបានសង្កេតការណ៍ មានជនជាប់ចោទ ៣៥ នាក់ជាអនីតិជននៅក្នុងពេលប្រព្រឹត្តបទល្មើស ហើយជនជាប់ចោទជាអនីតិជនទាំងអស់នោះត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន លើកលែងតែជនជាប់ចោទពីរនាក់ចេញ។ អនីតិជន ២៩ រូបមានអាយុចន្លោះពី ១៦ ដល់ ១៧ ឆ្នាំ ហើយ ៣ នាក់មានអាយុចន្លោះ ១៤ ដល់ ១៥ ឆ្នាំ។ បន្ថែមលើនេះទៀត មានសំណុំរឿងពីរពាក់ព័ន្ធជាមួយកុមារមានអាយុក្រោម ១៤ ឆ្នាំ នៅពេលបទល្មើសត្រូវបានចោទប្រកាន់ ហើយជនជាប់ចោទម្នាក់ត្រូវបានឲ្យរួចផុតពីបទចោទ និងបានដោះលែងដោយសាលាដំបូង ឯជនជាប់ចោទម្នាក់ទៀតត្រូវបានឃុំខ្លួនបន្ទាប់មានសេចក្ដីសម្រេចរបស់សាលាដំបូង។ សាលាឧទ្ធរណ៍បានរង់ចាំរហូតទាល់តែទទួលបានភស្តុតាងជាផ្លូវការដែលបញ្ជាក់ថាជនជាប់ចោទមានអាយុក្រោម ១៤ ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស ទើបសាលាឧទ្ធរណ៍អាចឲ្យជនជាប់ចោទរួចផុតពីបទចោទ និងដោះលែងបាន។

ឧត្តមប្រយោជន៍របស់កុមារ ចាំបាច់ត្រូវតែជាការពិចារណាចម្បងនៅពេលចេញសេចក្ដីបញ្ជា ឬបង្គាប់ឱ្យមានការផ្ដន្ទាទោសលើអនីតិជនដែលត្រូវបានរកឃើញថា បានបំពានច្បាប់ព្រហ្មទណ្ឌ។ [82] ការឃុំខ្លួនអនីតិជន គឺត្រូវបានចាត់ទុកថា ជាជម្រើសចុងក្រោយបំផុត ហើយគួរត្រូវបានយកមកអនុវត្តតែក្នុងករណីពិសេសតែ

[81] ទិន្នន័យនេះផ្អែកលើចំនួនសរុបនៃជនជាប់ចោទជាកុមារ (៣៥ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ១៩ សំណុំរឿងដែលបានសង្កេតការណ៍។

[82] មាត្រា ៣(១) នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ។ *សូមមើលផងដែរ* គណៈកម្មាធិការស្ដីពីសិទ្ធិកុមារ សេចក្ដីពន្យល់ទូទៅ លេខ ១០៖ សិទ្ធិកុមារនៅក្នុងយុត្តិធម៌អនីតិជន វាក្យខណ្ឌ ១០ និង ៧១ http://bit.ly/1fbEoKP។

ប៉ុណ្ណោះ។[83] ច្បាប់កម្ពុជា ក៏ផ្តល់ឱ្យមានវិធានផ្សេងទៀតក្រៅពីការកាត់ទោសជាប់ពន្ធនាគារផងដែរ។[84] ហេតុនេះ តួលេខខាងលើបង្ហាញពីការព្រួយបារម្ភយ៉ាងខ្លាំង ព្រមទាំងមិនអនុលោមតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដោយហេតុថា ការឃុំខ្លួនអនីតិជនជាបណ្តោះអាសន្ន ហាក់ធ្វើឡើងជាទម្លាប់ជាជាងជាវិធានការចុងក្រោយបំផុត។ សាលាឧទ្ធរណ៍ ពុំបានទាញប្រយោជន៍ពីជម្រើសការកាត់ទោសជាជម្រើសជំនួស ដូចមានចែងក្នុងមាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ និងនៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ក្នុងមាត្រា ២៨ នៃជំពូក ១០ ស្តីពីការបង្វែរ ដូចជាការដាក់អនីតិជនទៅក្នុងទីភ្នាក់ងារសេវាសង្គម ឬទៅកាន់អង្គការឯកជនមាននីតិសម្បទា ឬដាក់ក្នុងមន្ទីរពេទ្យ ឬស្ថាប័នឯកទេសជាដើម។ សាលាឧទ្ធរណ៍ពុំបានអនុវត្តស្របតាមមាត្រា ៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលតម្រូវឱ្យជនទាំងឡាយក្នុងមុខងារសាធារណៈដែលជាប់ទាក់ទងជាមួយអនីតិជន ត្រូវធ្វើសកម្មភាព ដើម្បីឧត្តមប្រយោជន៍របស់អនីតិជន និងជាពិសេស គឺសិទ្ធិទទួលបានការអភិវឌ្ឍរបស់អនីតិជន ហើយដែលចែងថា ការចាប់ខ្លួន ឬការឃុំខ្លួនអនីតិជន គួរត្រូវបានប្រើប្រាស់ជាជម្រើសចុងក្រោយបំផុត។

### តួលេខទី ១៤(ខ)៖ ការការពារឯកជនភាពរបស់អនីតិជន[85]




នៅក្រោមច្បាប់សិទ្ធិមនុស្ស អនីតិជនមានសិទ្ធិទទួលបានការគោរពចំពោះភាពជាឯកជនរបស់ខ្លួននៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធី។[86] សិទ្ធិនេះ រួមមានចាប់តាំងពីការចូលមកពាក់ព័ន្ធជាដំបូងជាមួយមន្ត្រី

[83] មាត្រា ៣៧(ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

[84] មាត្រា៤០ នៃក្រមព្រហ្មទណ្ឌ។

[85] ទិន្នន័យនេះផ្អែកលើចំនួនសរុបនៃជនជាប់ចោទជាកុមារ (៣៥ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ១៩ សំណុំរឿងដែលបានសង្កេតការណ៍។

[86] មាត្រា ៤០(២)(vii) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

អនុវត្តច្បាប់រហូតដល់សេចក្តីសម្រេចជាស្ថាពរ ឬប្រសិនបើត្រូវបានកាត់ឱ្យជាប់ទោស គឺរហូតដល់ការដោះលែងចេញពីការមើលខុសត្រូវ ការឃុំខ្លួន ឬការដកហូតសេរីភាព។[87] មូលដ្ឋានហេតុផលដែលធ្វើឱ្យមានការអនុវត្តបែបនេះ គឺដើម្បីចៀសវាងការបង្កគ្រោះថ្នាក់តាមរយៈការបង្ហាញព័ត៌មានជាសាធារណៈមិនសមស្រប ឬការធ្វេសប្រហែស។ ហេតុនេះ គ្មានព័ត៌មានណាមួយត្រូវបានបង្ហាញជាសាធារណៈទាក់ទងជាមួយអត្តសញ្ញាណរបស់ជនល្មើសជាកុមារឡើយ។[88] ភាពជាឯកជនរបស់ជនរងគ្រោះ ឬជនដែលរងការចោទប្រកាន់ជាអនីតិជនអាចត្រូវបានការពារបន្ថែមទៀតតាមរយៈការដាក់អនីតិជនឱ្យនៅខាងក្រោយរបាំង ឬប្រើប្រាស់មធ្យោបាយជាជម្រើសជំនួសដទៃទៀតក្នុងការផ្តល់សក្ខីកម្ម។ ការប្រើប្រាស់ឧបករណ៍នានា ដូចជាប្រព័ន្ធឆ្លើយឆ្លងតាមវីដេអូ ឬសវនាការបិទទ្វារ គួរត្រូវបានពិចារណាយកមកអនុវត្ត។

ពុំមានវិធានការណាមួយត្រូវបានធ្វើឡើង ដើម្បីគោរពភាពជាឯកជនរបស់អនីតិជននៅក្នុងសំណុំរឿង ៩៧% ដែលពាក់ព័ន្ធជាមួយអនីតិជនដែលយើងបានសង្កេតការណ៍ឡើយ ហើយនេះជាទង្វើបំពានសិទ្ធិមនុស្សអន្តរជាតិ។ គ្រប់សវនាការទាំងអស់សុទ្ធតែបើកចំហសម្រាប់សាធារណជន។ មានតែមួយករណីប៉ុណ្ណោះដែលតុលាការធ្វើសវនាការបិទទ្វារ ប៉ុន្តែសវនាការបិទទ្វារនោះត្រូវបានធ្វើឡើងដោយសារតែ ហេតុផលសីលធម៌សង្គម ព្រោះថាអនីតិជនរូបនោះត្រូវបានចោទប្រកាន់ពីបទរំលោភសេពសន្ថវៈ។ បញ្ហាពាក់ព័ន្ធនឹងសិទ្ធិទទួលបានការការពារឯកជនភាពរបស់អនីតិជននៅពេលសវនាការរឿងក្តីព្រហ្មទណ្ឌ ត្រូវបានលើកយកមកពិភាក្សាយ៉ាងទូលំទូលាយជាមួយអនុប្រធានសាលាឧទ្ធរណ៍[89] ដែលបានលើកឡើងថានឹងពិនិត្យឡើងវិញលើការអនុវត្តនេះ ដោយមិនត្រឹមតែការពារឯកជនភាពរបស់អនីតិជនជាជនជាប់ចោទប៉ុណ្ណោះទេ ថែមទាំងការពារឯកជនភាពរបស់អនីតិជនជាជនរងគ្រោះ និងជាសាក្សីផងដែរ ក្នុងគោលបំណងដើម្បីអនុលោមតាមបទដ្ឋានជាតិ និងអន្តរជាតិ។

[87] អនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ១០ វាក្យខណ្ឌ ៦៤។

[88] អនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ១០ វាក្យខណ្ឌ ៦៤។

[89] ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បានជួបជាមួយអនុប្រធានសាលាឧទ្ធរណ៍ ឯកឧត្តម ប្លង់ សំណាង ឯកឧត្តម ញូង ធុល ព្រមទាំងអគ្គលេខាធិការរងរដ្ឋបាល លោកស្រី ស្រេង សូយ៉េត ដើម្បីពិភាក្សាលើរបកគំឃើញនៅក្នុងរបាយការណ៍នេះ។

## ៣. ការវិវឌ្ឍនៃការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅចន្លោះឆ្នាំ ២០១៤ ដល់ ២០១៧

ផ្នែកនេះគូសបញ្ជាក់អំពីនិន្នាការសំខាន់ៗ ទាក់ទងជាមួយការគោរពតាមបទដ្ឋានអន្តរជាតិនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់សាលាឧទ្ធរណ៍។ ផ្នែកនេះ បង្ហាញការប្រៀបធៀបនៃទិន្នន័យប្រមូលបានក្នុងអំឡុងពេលធ្វើរបាយការណ៍ (ថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០១៦ ដល់ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៧ និងចាប់ពីពេលនេះទៅហៅថា "២០១៦ -២០១៧") ជាមួយទិន្នន័យប្រមូលបានតាមរយៈការសង្កេតការណ៍សវនាការប្រចាំថ្ងៃដែលធ្វើឡើងនៅក្នុងសាលាឧទ្ធរណ៍ចន្លោះពីថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០១៤ ដល់ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៥ ("២០១៤-២០១៥")។[90] គម្រោងសង្កេតការណ៍សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក ត្រូវបានផ្អាកជាបណ្ដោះអាសន្ននៅចន្លោះរវាងថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០១៥ ដល់ ខែតុលា ឆ្នាំ ២០១៦ ដោយសារកង្វះមូលនិធិ ជាលទ្ធផលពុំមានទិន្នន័យសម្រាប់អំឡុងរយៈពេលនេះឡើយ។

របាយការណ៍ ២០១៤-២០១៥ គឺផ្អែកលើសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតការណ៍ ដោយក្នុងនោះមាន ៤៦ សំណុំរឿង ជាបទឧក្រិដ្ឋ, ៧៧ សំណុំរឿង ជាបទល្មើសមជ្ឈិម និង ៥ សំណុំរឿង ជាបទលហុ។ ម.ស.ម.ក បានសន្និដ្ឋានថា សាលាឧទ្ធរណ៍បានគោរពសិទ្ធិដូចខាងក្រោម៖

- ការសន្មតទុកជាមុនថាគ្មានទោស
- សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់
- សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ
- សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្ដី
- ការហាមឃាត់ការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល
- ការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ និង
- សិទ្ធិទទួលបានការប្រកាសសេចក្ដីសម្រេចជាសាធារណៈ។

ផ្ទុយទៅវិញ ម.ស.ម.ក បានរកឃើញថា សិទ្ធិខាងក្រោមនេះកំពុងតែប្រឈមនឹងការរំលោភបំពានក្នុងចន្លោះឆ្នាំ ២០១៤ ដល់ ២០១៥៖

- សិទ្ធិបានទទួលការពន្យល់អំពីសិទ្ធិទទួលបានការជំនុំជម្រះរបស់ខ្លួន រួមទាំងសិទ្ធិមានមេធាវី ឬ សិទ្ធិការពារខ្លួនឯង និងសិទ្ធិនៅស្ងៀម

[90] របាយការណ៍ប្រចាំឆ្នាំ ២០១៤-២០១៥ គ្របដណ្ដប់រយៈពេលចាប់ពីថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០១៤ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៥ គឺនៅមិនទាន់បានបោះពុម្ពផ្សាយនៅឡើយ ប៉ុន្តែយើងអាចផ្ដល់ជូនបានតាមការស្នើសុំ។

- សិទ្ធិទទួលបានសេចក្ដីសម្រេចដែលមានសម្អាងហេតុ
- ចៅក្រមឯករាជ្យ មិនលម្អៀង និងមានវិជ្ជាជីវៈ
- សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព និង
- សិទ្ធិរបស់អនីតិជន។

ការប្រែប្រួលនេះ អាចពន្យល់ត្រឹមតែផ្នែកខ្លះៗ ដោយសារតែ ម.ស.ម.ក បានសង្កេតការណ៍លើសវនាការ ក្នុងឆ្នាំ ២០១៦-២០១៧ ច្រើនជាង ឆ្នាំ២០១៤-២០១៥ ពីរដងក្ដី ប៉ុន្តែការប្រៀបធៀបនេះ នៅតែអនុញ្ញាតឱ្យអាចកំណត់ឃើញនិន្នាការមួយចំនួន ដោយក្នុងនោះ អាជ្ញាធរត្រូវយកចិត្តទុកដាក់ធ្វើសកម្មភាពដើម្បីកែលម្អការគោរពចំពោះសិទ្ធិទទួលបានកាជំនុំជម្រះជាទូទៅ។

ដោយឡែក នៅពេលយើងធ្វើការប្រៀបធៀបនូវការរកឃើញពីចន្លោះឆ្នាំ ២០១៤-២០១៥ ជាមួយរបាយការណ៍ចន្លោះឆ្នាំ ២០១៦-២០១៧ មាននិន្នាការសំខាន់ៗមួយចំនួន ដែលអាចកំណត់ឃើញដូចតទៅ៖

- ការគោរពសិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មានភាពប្រសើរឡើងគួរជាទីកត់សម្គាល់ ដោយបានកើនឡើងដល់ស្ទើរ ១០០% ក្នុងឆ្នាំ ២០១៦-២០១៧ ដោយកើនឡើងពីអត្រា ៨២% ក្នុងឆ្នាំ ២០១៤-២០១៥។
- សិទ្ធិសំខាន់ៗ ទាក់ទងនឹងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានគោរព និងការពារយ៉ាងស៊ីសង្វាក់ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍ទាំងពីរ៖ ការហាមឃាត់ការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល ការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ និងសិទ្ធិទទួលបានការប្រកាសសេចក្ដីសម្រេចជាសាធារណៈ។
- ថ្វីបើការគោរពសិទ្ធិអនីតិជន ជាពិសេសការចាត់វិធានការ ដើម្បីការពារភាពជាឯកជនរបស់អនីតិជនមានភាពប្រសើរឡើងបន្តិចបន្តួចក្ដី ដោយគិតពី ១០០% នៃសំណុំរឿងដែលពុំមានវិធានការណាមួយត្រូវបានធ្វើឡើងសោះ មកនៅត្រឹម ៩៧%។ ការមិនគោរពសិទ្ធិរបស់អនីតិជន គឺជាកង្វល់ធំបំផុតទាក់ទងជាមួយសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។
- ការការពារសិទ្ធិសំខាន់ៗ មួយចំនួនមានការថមថយក្នុងអំឡុងរយៈពេលពីរឆ្នាំ ថ្វីបើភាពខុសគ្នារវាងឆ្នាំ ២០១៤-២០១៥ និងឆ្នាំ ២០១៦-២០១៧ មានកម្រិតតិចតួចក្ដី (ខុសគ្នាប្រមាណ ៥%)។ ជាពិសេស សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្ដី សិទ្ធិមានវត្តមាននៅពេលសវនាការ និងមានមេធាវី និងការការពារខ្លួនប្រឆាំងការឆ្លើយដាក់បន្ទុកបទល្មើសលើខ្លួនឯង មានការថយចុះបន្តិច។
- ការវិភាគមួយលើការគោរពចំពោះការសន្មតទុកជាមុនថាគ្មានទោស បាននាំឱ្យមានទស្សនៈថាល្អផង និងមិនល្អផង៖ ខណៈពេលដែលវត្តមានរបស់ជនជាប់ចោទក្នុងឯកសណ្ឋានពន្ធនាគារមានការកើន

ឡើងពី ៤% ដល់ ៩% ក្តី ប៉ុន្តែជនជាប់ចោទទាំងនោះ ពុំមាននរណាម្នាក់ត្រូវបានដាក់ខ្នោះឡើយ ហើយចៅក្រមក៏ពុំដែលធ្វើសារណាប្រឆាំងទោសកំហុសរបស់ជនជាប់ចោទ នៅក្នុងអំឡុងពេលធ្វើបោយការណ៍ទាំងពីរនេះដែរ។ ប៉ុន្តែក្នុងអំឡុងពេលធ្វើបោយការណ៍ទាំងពីរនេះ ចៅក្រមខកខានក្នុងការប្រាប់ និងពន្យល់អំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការស្ងៀមនៅតែមានអត្រាថេរដែលជាការបង្ហាញអំពីការអនុវត្តនៅតែមានការបំពានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នៅក្នុងសំណុំរឿងភាគច្រើន (ក្នុងអត្រា ៣,៥ សំណុំរឿងក្នុងចំណោម ៥ សំណុំរឿង)។

- សិទ្ធិទទួលបានសេចក្តីសម្រេចមានសម្អាងហេតុ ដែលជាសិទ្ធិជាមូលដ្ឋានបំផុតមួយនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅតែប្រឈមគួរជាទីកត់សម្គាល់នៅសាលាឧទ្ធរណ៍ ដែលតែងខកខានក្នុងការផ្តល់មូលដ្ឋានផ្នែកច្បាប់ និងមូលដ្ឋានផ្នែកអង្គហេតុ ក៏ដូចជាសម្អាងហេតុសម្រាប់សេចក្តីសម្រេចរបស់ខ្លួននោះឡើយ ជាហេតុបង្កើតឱ្យមានហានីភ័យនៃការចេញសេចក្តីសម្រេចតាមចិត្តឯង។

## ៣.១. មានការកើនឡើងគួរជាទីកត់សម្គាល់នូវការគោរពចំពោះសិទ្ធិសំខាន់ៗមួយចំនួន ក្នុងចំណោមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ទន្ទឹមនឹងនេះក៏ចាំបាច់ត្រូវមានកិច្ចខិតខំបន្ថែមទៀត

### ៣.១.១. សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ត្រូវបានការពារកាន់តែប្រសើរឡើង

ការគោរពចំពោះសិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មានភាពប្រសើរឡើងនៅចន្លោះឆ្នាំ ២០១៤ ដល់ ២០១៧។ ចៅក្រមបានបញ្ជាក់អំពីច្បាប់ដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង ៩៦% ក្នុងឆ្នាំ ២០១៦-២០១៧ ដោយការប្រតិបត្តិនេះ មានត្រឹមតែ ៨២% ប៉ុណ្ណោះក្នុងចំណោមសំណុំរឿងដែលបានសង្កេតការណ៍ក្នុងឆ្នាំ ២០១៤-២០១៥។ ជាទូទៅចៅក្រមបញ្ជាក់រាល់បទចោទប្រកាន់ដែលពាក់ព័ន្ធទាំងអស់ ធ្វើឡើងប្រឆាំងនឹងជនជាប់ចោទគ្រប់រូប នៅក្នុងសំណុំរឿង ៨៦% ក្នុងឆ្នាំ ២០១៦-២០១៧ បើធៀបនឹងចំនួន ៨៥% នៃសំណុំរឿងដែលបានសង្កេតការណ៍ក្នុងឆ្នាំ ២០១៤-២០១៥។ ហេតុនេះ មាននិន្នាការជាវិជ្ជមាន និងគួរជាការលើកទឹកចិត្តបន្ថែមទៀត ដោយក្នុងនោះ ម.ស.ម.ក សង្ឃឹមជឿជាក់យ៉ាងខ្លាំងថា និន្នាការនេះនឹងបន្តទៅមុខទៀត ដោយហេតុថា ការប្រតិបត្តិនេះ គឺជាធាតុផ្សំគន្លឹះមួយរបស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

យ៉ាងណាក៏ដោយ ចាំបាច់ត្រូវផ្តល់ការយកចិត្តទុកដាក់ជាពិសេសក្នុងការផ្តល់ព័ត៌មានទាក់ទងជាមួយទីកន្លែងប្រព្រឹត្តបទល្មើស ដោយហេតុថា មានការថយចុះបន្តិចនូវចំនួនសំណុំរឿងដែលបានបញ្ជាក់អំពីទីកន្លែងប្រព្រឹត្តបទល្មើស។




### ៣.១.២. ការការពារឯកជនភាពដល់អនីតិជនគឺមានភាពប្រសើរឡើងតិចតួចប៉ុណ្ណោះ ដែលនេះបង្កឲ្យមានការព្រួយបារម្ភខ្លាំង

មានភាពប្រសើរឡើងតិចតួចទាក់ទងជាមួយឯកជនភាពរបស់អនីតិជន។ ខណៈដែលក្នុងឆ្នាំ ២០១៥ ពុំមានវិធានការណាមួយត្រូវបានធ្វើឡើង ដើម្បីការពារឯកជនភាពរបស់អនីតិជនក្នុងគ្រប់សំណុំរឿងដែលបានសង្កេតការណ៍ ប៉ុន្តែក្នុងឆ្នាំ ២០១៧ វិធានការប្រភេទនេះ ត្រូវបានធ្វើឡើងនៅក្នុងសំណុំរឿងតែចំនួន ៣% ប៉ុណ្ណោះនៃសំណុំរឿងពាក់ព័ន្ធនឹងអនីតិជន។




យ៉ាងណាក៏ដោយ ដូចបានបញ្ជាក់ខាងលើហើយថា នេះនៅតែជានិន្នាការគួរជាទីបារម្ភយ៉ាងខ្លាំង ដោយហេតុថា ការការពារឯកជនភាពរបស់អនីតិជន គឺជាសិទ្ធិដ៏សំខាន់មួយនៅក្នុងចំណោមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សម្រាប់អនីតិជន។ ហេតុនេះ ចាំបាច់ត្រូវមានវិធានការជាបន្ទាន់ ដើម្បីធានាឱ្យបានថា

ការគោរពឯកជនភាពរបស់អនីតិជន ត្រូវបានអនុវត្តជានិយាមទូទៅ ពុំមែនតែក្នុងករណីលើកលែងនោះឡើយ ដូចមានរៀបរាប់លម្អិតនៅក្នុងអនុសាសន៍ខាងក្រោម។ វិធានការដែលអាចកែលម្អការគោរពសិទ្ធិនេះ គឺអាចអនុវត្តបានយ៉ាងងាយស្រួលដោយចំណាយអស់តិច ឧទាហរណ៍តាមរយៈការហាមឃាត់សាធារណជនចូលមកកាន់បន្ទប់សវនាការនៅពេលមានការជំនុំជម្រះទាក់ទងជាមួយជនណាម្នាក់ដែលជាអនីតិជន។ ចាំបាច់ត្រូវមានវិធានការជាក់លាក់ ដើម្បីដោះស្រាយចំពោះការរំលោភបំពាននេះ។

### ៣.១.៣. ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល និងការហាមឃាត់ការអនុវត្តអានុ ភាពប្រតិសកម្មនៃច្បាប់ក៏ដូចជាសិទ្ធិទទួលបានសេចក្ដីសម្រេចជាសាធារណៈត្រូវបានគោរពជាបន្តបន្ទាប់

ការប្រៀបធៀបលើបេកគំហើញរបស់ ម.ស.ម.ក ចន្លោះរវាងឆ្នាំ ២០១៤-២០១៥ និង ២០១៦-២០១៧ ទាក់ទងជាមួយការការពារការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល ការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ និងសិទ្ធិទទួលបានការប្រកាសសេចក្ដីសម្រេចជាសាធារណៈត្រូវបានគោរពយ៉ាងស៊ីសង្វាក់ដោយសាលាឧទ្ធរណ៍។ ដោយឡែកក្នុងសំណុំរឿងទាំងអស់ ដែលបានសង្កេតការណ៍ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍ទាំងពីរនេះ ពុំមានការរំលោភបំពានលើការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌទេ ហើយសេចក្ដីសម្រេចទាំងអស់ត្រូវបានប្រកាសជាសាធារណៈ។ មានតែសំណុំរឿងរបស់ជនជាប់ចោទតែម្នាក់ប៉ុណ្ណោះដែលបានរំលោភបំពានលើការការពារការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល ក្នុងចំណោមជនជាប់ចោទជនទាំង ៥៥៨ នាក់ ក្នុងសំណុំរឿងដែល ម.ស.ម.ក បានអង្កេតការណ៍ក្នុងឆ្នាំ ២១០៦-២០១៧។

## ៣.២. ការថយចុះនូវការគោរពចំពោះសិទ្ធិជាមូលដ្ឋានសំខាន់ៗ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌

លទ្ធផលនៃការសង្កេតការណ៍របស់ ម.ស.ម.ក បង្ហាញថា មានការថយចុះតិចតួច ប៉ុន្តែមានលក្ខណៈគួរជាទីបារម្ភចំពោះការគោរព និងការការពារសិទ្ធិរបស់ជនជាប់ចោទទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្ដី សិទ្ធិមានវត្តមាននៅពេលសវនាការ និងមានមេធាវី ព្រមទាំងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាពនៅក្នុងសាលាឧទ្ធរណ៍។ បន្ថែមលើនេះ មានសំណុំរឿងជាច្រើនដែលចៅក្រមសាលាឧទ្ធរណ៍បានតម្កល់សេចក្ដីសម្រេចរបស់សាលាដំបូង បើទោះបីជាជនជាប់ចោទ ឬមេធាវីការពារជនជាប់ចោទបានលើកឡើងថា ការសារភាពកើតចេញពីបង្ខំ ឬហិង្សាលើរូបរាងកាយក៏ដោយ។ លើសពីនេះ ការប្រើប្រាស់ឯកសណ្ឋានពន្ធនាគារសម្រាប់ជនជាប់ឃុំដែលនៅពុំទាន់ត្រូវបានកាត់ទោសជាស្ថាពរ ដែលជាសិទ្ធិត្រូវបានទទួលពីការសន្មតទុកជាមុនថាគ្មានទោសក៏មានការកើនឡើងបន្តិចផងដែរ។




### ៣.២.១. សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីមានការថយចុះបន្តិច

ការគោរពសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីមានការថយចុះបន្តិចក្នុងសាលាឧទ្ធរណ៍ក្នុងឆ្នាំ ២០១៦-២០១៧ បើធៀបនឹងឆ្នាំ ២០១៤-២០១៥។ ថ្វីបើពុំមានជនជាប់ចោទណាមួយដែលមេធាវីរបស់ខ្លួនត្រូវបានចាត់តាំងនៅនាទីចុងក្រោយនៅថ្ងៃសវនាការឧទ្ធរណ៍ឆ្នាំ ២០១៤-២០១៥ ក្តី ប៉ុន្តែមានការកើនឡើងចំនួនជនជាប់ចោទរហូតដល់ ២% ដែលត្រូវស្ថិតក្នុងស្ថានភាពបែបនេះក្នុងឆ្នាំ ២០១៦-២០១៧ ដែលបង្កើតឱ្យមាននិន្នាការគួរជាទីបារម្ភ។

### ៣.២.២. សិទ្ធិមានវត្តមាននៅពេលសវនាការ និងមានមេធាវីនៅតែទទួលបានការគោរពជាទូទៅថ្វីបើមានការធ្លាក់ចុះបន្តិចចន្លោះឆ្នាំ ២០១៤-២០១៥ មកដល់ឆ្នាំ ២០១៦-២០១៧ ក្តី

មានភាពធ្លាក់ចុះនូវការប្រកាន់ភ្ជាប់របស់សាលាឧទ្ធរណ៍ចំពោះការគោរពសិទ្ធិមានវត្តមាននៅពេលសវនាការ និងមានមេធាវី។ ក្នុងឆ្នាំ ២០១៤-២០១៥ ជនជាប់ចោទមានវត្តមាននៅក្នុងសំណុំរឿងចំនួន ៧៩% ចំណែកក្នុងឆ្នាំ ២០១៦-២០១៧ តួលេខនេះ បានថយចុះមកនៅត្រឹម ៧២% ។ ស្រដៀងគ្នានេះដែរ ថ្វីបើក្នុង

ឆ្នាំ ២០១៤-២០១៥ ជនជាប់ចោទ ៨៤% ក្នុងសំណុំរឿងដែលត្រូវបានសង្កេតការណ៍មានមេធាវី ប៉ុន្តែក្នុងឆ្នាំ ២០១៦-២០១៧ ជនជាប់ចោទមានមេធាវីតំណាងតែ ៧៩% តែប៉ុណ្ណោះ។

ថ្វីបើតួលេខខុសគ្នាបន្តិចបន្តួចក្តី ប៉ុន្តែទិដ្ឋភាពនេះ អាចតំណាងឱ្យនិន្នាការជាអវិជ្ជមាន ដែលចាំបាច់ត្រូវដោះស្រាយជាបន្ទាន់។

### ៣.២.៣. ការចោទប្រកាន់ថា ជនជាប់ចោទត្រូវបានគំរាមកំហែង ទទួលរងអំពើហិង្សា ឬទារុណកម្មឱ្យសារភាពបានកើនឡើងនៅរវាងចន្លោះឆ្នាំ ២០១៤-២០១៥ ដល់ ២០១៦-២០១៧

ការអនុលោមតាមសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព (ការការពារខ្លួនប្រឆាំងការឆ្លើយដាក់បន្ទុកលើខ្លួនឯង) មានការកើនឡើងបន្តិច ប៉ុន្តែក៏បង្កឱ្យមានក្តីព្រួយបារម្ភផងដែរ។ សំណុំរឿងដែលជនជាប់ចោទចោទប្រកាន់ថា មានការគំរាមកំហែងបង្ខិតបង្ខំលើរូបគាត់ឱ្យសារភាពចំពោះបទល្មើសដែលបានចោទប្រកាន់បានកើនឡើងពីអត្រា ៣% ក្នុងចំណោមសំណុំរឿងទាំងអស់ក្នុងឆ្នាំ ២០១៤-២០១៥ មកដល់ ៤% ក្នុងចំណោមសំណុំរឿងដែលបានសង្កេតការណ៍ក្នុងឆ្នាំ ២០១៦-២០១៧។ ការចោទប្រកាន់ថា ជនជាប់ចោទរងអំពើហិង្សា ឬទារុណកម្មឱ្យសារភាពចំពោះបទល្មើសដែលបានចោទប្រកាន់បានកើនឡើងពី ៤% ក្នុងឆ្នាំ ២០១៤-២០១៥ ដល់ ៧% ក្នុងឆ្នាំ ២០១៦-២០១៧។

ការការពារខ្លួនប្រឆាំងនឹងការឆ្លើយដាក់បន្ទុកលើខ្លួនឯង គឺជាសិទ្ធិដ៏សំខាន់មួយនៅក្នុងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយគឺជាស្នូលដ៏សំខាន់មួយ ដើម្បីឱ្យប្រព័ន្ធយុត្តិធម៌អាចបំពេញមុខងារបានត្រឹមត្រូវ។ ជាការសំខាន់ខ្លាំងណាស់ដែលត្រូវបង្វែរនិន្នាការនេះ ឱ្យត្រឡប់មកជាវិជ្ជមានវិញតាមរយៈការប្រើប្រាស់វិធានការដ៏រឹងមាំ ដើម្បីធានាឱ្យបានថា គ្រប់ការសារភាពទាំងអស់ត្រូវបានធ្វើឡើងដោយការព្រមព្រៀងសេរី និងផ្អែកលើព័ត៌មានត្រឹមត្រូវដោយពុំមានការបង្ខិតបង្ខំក្នុងទម្រង់ណាមួយឡើយ។

### ៣.២.៤. ការប្រើប្រាស់ឯកសណ្ឋានពន្ធនាគារដែលប៉ះពាល់យ៉ាងខ្លាំងចំពោះការសន្មតទុកជាមុនថាគ្មានទោស មានការកើនឡើងបន្តិច

ម.ស.ម.ក មានការសោកស្តាយដែលបានសង្កេតឃើញការកើនឡើងចំនួនសំណុំរឿងដែលជនជាប់ចោទបង្ហាញខ្លួនក្នុងសវនាការដោយពាក់ឯកសណ្ឋានពន្ធនាគារ ធ្វើឱ្យការគោរពចំពោះការសន្មតទុកជាមុនថាគ្មានទោសត្រូវប្រឈមនឹងការបំពាន។ ខណៈពេលដែលសមាមាត្រទូទៅនៅមានកម្រិតទាបជាង ១០% នៃសំណុំរឿងដែលបានសង្កេតការណ៍ក្តី ប៉ុន្តែចំនួនសំណុំរឿងបានកើនឡើងពី ៤% មកដល់ ៩% បង្កើតឱ្យមានជាកង្វល់។ ទោះយ៉ាងណាក្តី នៅក្នុងអំឡុងពេលធ្វើរបាយការណ៍ទាំងពីរនេះ ជនជាប់ចោទពុំបានជាប់ខ្នោះឡើយ។

### ៣.៣. សិទ្ធិនៅស្ងៀម និងសិទ្ធិទទួលបានសេចក្តីសម្រេចមានសម្អាងហេតុបន្តរងការបំពាន

ម.ស.ម.ក មានក្តីកង្វល់យ៉ាងខ្លាំងដោយបានសង្កេតឃើញថា ទាំងក្នុងអំឡុងឆ្នាំ ២០១៤-២០១៥ និង ២០១៦-២០១៧ ក្នុងសំណុំរឿងភាគច្រើនលើសលប់ ជនជាប់ចោទពុំត្រូវបានប្រាប់ពីសិទ្ធិនៅស្ងៀមនោះឡើយ (៦៤% នៃសំណុំរឿងក្នុងឆ្នាំ ២០១៤-២០១៥ និង ៦៥% នៃសំណុំរឿងក្នុងឆ្នាំ ២០១៦-២០១៧) ដែលបំពានយ៉ាងខ្លាំងចំពោះការសន្មតទុកជាមុនថាគ្មានទោស។







មកទល់ពេលនេះ យើងក៏ឃើញនិន្នាការប្រហាក់ប្រហែលគ្នានេះដែរនៅក្នុងសាលាឧទ្ធរណ៍ទាក់ទងជាមួយការគោរពសិទ្ធិជនជាប់ចោទក្នុងការទទួលបានសេចក្តីសម្រេចដោយមានសម្អាងហេតុ ដែលជាកង្វល់ធ្វើឱ្យសិទ្ធិនេះ ត្រូវប្រឈមការរំលោភបំពានគួរជាទីកត់សម្គាល់។ ក្នុងឆ្នាំ ២០១៤-២០១៥ ចៅក្រមមិនបានបញ្ជាក់អំពីមាត្រាច្បាប់ពាក់ព័ន្ធនៅពេលប្រកាសសាលដីកាចំនួន ៨០% ហើយមិនបានលើកឡើងអំពីភស្តុតាងក្នុងសំណុំរឿង ៧៣%។ ក្នុងឆ្នាំ ២០១៦-២០១៧ និន្នាការនេះ បន្តកើនឡើងគួរជាទីកត់សម្គាល់ដោយចៅក្រមពុំបានផ្តល់មូលដ្ឋានបញ្ជាក់អំពីសេចក្តីសម្រេចរបស់ខ្លួននៅក្នុងសំណុំរឿងស្ទើរតែទាំងអស់ ដោយផ្ទុយទៅវិញដោយគ្រាន់តែអាន និងប្រកាសសេចក្តីសម្រេចប៉ុណ្ណោះ។

### ៣.៤. សេចក្តីសន្និដ្ឋានអំពីនិន្នាការសំខាន់ៗក្នុងអំឡុងពេលរវាងឆ្នាំ ២០១៤-២០១៥ ដល់ ២០១៦-២០១៧

ដូច្នោះ ការងារជាអាទិភាពសម្រាប់សាលាឧទ្ធរណ៍ គឺត្រូវធានាឱ្យបានថាសិទ្ធិអនីតិជនក្នុងការទទួលបានការការពារឯកជនភាព ត្រូវបានគោរព និងការពារយ៉ាងពេញលេញ ហើយត្រូវធានាថានៅពេលប្រកាសសេចក្តីសម្រេចត្រូវផ្តល់សេចក្តីសម្រេចមានសម្អាងហេតុសម្រាប់សេចក្តីសម្រេចនោះ។ សាលាឧទ្ធរណ៍ត្រូវធានា

ឱ្យបានផងដែរថា ជាតុទាំងអស់នៅក្នុងការសន្មតទុកជាមុនថាគ្មានទោសត្រូវបានគោរពយ៉ាងពេញលេញ ជាពិសេសត្រូវជានាឱ្យថា ចៅក្រមប្រាប់ដល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ខ្លួន។

ម្យ៉ាងទៀតជាការសំខាន់ផងដែរ ដែលសាលាឧទ្ធរណ៍ត្រូវជានាឱ្យបានថា សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី សិទ្ធិមានវត្តមាននៅក្នុងសវនាការ និងមានមេធាវី ក៏ដូចជាការការពារខ្លួនប្រឆាំងការឆ្លើយដាក់បន្ទុកលើខ្លួនឯង ពុំត្រូវធ្វើឱ្យកាន់តែធ្ងន់ធ្ងរបន្ថែមទៀតឡើយ។ ជាចុងក្រោយ ភាគីពាក់ព័ន្ធទាំងអស់ ចាំបាច់ត្រូវបន្តកិច្ចខិតខំធានាយ៉ាងណាឱ្យសិទ្ធិដែលត្រូវបានការពារយ៉ាងស៊ីសង្វាក់ បន្តត្រូវបានការពារតទៅមុខទៀត។

.

## ៤. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

ទិន្នន័យដែលប្រមូលបាននៅក្នុងអំឡុងពេលនៃការអនុវត្តគម្រោង ថ្វីបើបង្ហាញឱ្យឃើញថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាច្រើនត្រូវបានការពារនៅចំពោះមុខសាលាឧទ្ធរណ៍ក្ដី ប៉ុន្តែក៏បានគូសបញ្ជាក់នូវតម្រូវការក្នុងការធ្វើកំណែទម្រង់ទៅលើចំណុចមួយចំនួន ដើម្បីអាចឈានទៅទទួលបាននីតិរដ្ឋកាន់តែរឹងមាំថែមទៀត។ ថ្វីបើជាទូទៅ សាលាឧទ្ធរណ៍ប្រកាន់ខ្ជាប់តាមនីតិវិធីដែលមានដើម្បីធានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចជាសិទ្ធិទទួលបានការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល ឬការហាមឃាត់អានុភាពប្រតិសកម្មនៃច្បាប់ និងសិទ្ធិទទួលបានសេចក្ដីសម្រេចជាសាធារណៈក្ដី ប៉ុន្តែកង្វល់ភាគច្រើនគឺផ្ដោតលើបញ្ហាសំខាន់ឯទៀតជាច្រើន។

ជាពិសេស របកគំហើញសំខាន់ៗមួយចំនួនបានកក់សម្គាល់ដូចខាងក្រោម៖

- ពុំមានសវនាការណាមួយក្នុងចំណោមសវនាការទាំង ៣៤០ សំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍ចាប់ពីខែ វិច្ឆិកា ឆ្នាំ ២០១៦ ដល់ខែ តុលា ឆ្នាំ ២០១៧ ត្រូវបានបិទប្រកាសជាសាធារណៈ តាមរយៈការជូនដំណឹងនៅលើក្ដារព័ត៌មានឡើយ។
- មានជនជាប់ចោទលើសពីម្នាក់ក្នុងចំណោមបួននាក់ ពុំមានវត្តមានក្នុងសវនាការឡើយ (២៨%)។
- មាន ២១% នៃជនជាប់ចោទទាំងអស់ក្នុងសំណុំរឿងពុំមានមេធាវីតំណាងឡើយ។
- ប្រមាណមួយករណីក្នុងចំណោមដប់ករណី ចៅក្រមពុំបានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិការពារខ្លួនដោយខ្លួនឯង និងសិទ្ធិមានមេធាវីតំណាងនោះឡើយ។
- ចៅក្រមពុំបានប្រាប់ និងពន្យល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមឡើយ ក្នុងសំណុំរឿងលើសពីបីសំណុំរឿងក្នុងចំណោមប្រាំសំណុំរឿង (៦៥%)។
- ជនជាប់ចោទ ៥០ នាក់បង្ហាញខ្លួននៅចំពោះមុខសាលាឧទ្ធរណ៍ក្នុងឯកសណ្ឋានពន្ធនាគារ (ឯកសណ្ឋានពណ៌ខៀវ) ដែលជាការរំលោភបំពានដល់ការសន្មតទុកជាមុនថាគ្មានទោស។
- ជនជាប់ចោទ ៤០ នាក់បាននិយាយថាខ្លួនបានផ្ដល់ការសារភាពក្រោយពីមានការប្រើប្រាស់អំពើហិង្សា ឬការធ្វើទារុណកម្មមកលើខ្លួន។
- នៅក្នុងស្ទើរគ្រប់សំណុំរឿងទាំងអស់ ចៅក្រមពុំបានលើកពីមាត្រាច្បាប់ និងភស្តុតាងដែលខ្លួនប្រើប្រាស់ជាមូលដ្ឋានដើម្បីឈានដល់ការសម្រេចចេញសាលដីការបស់ខ្លួនឡើយ។ ចៅក្រមគ្រាន់តែអាន និងប្រកាសសេចក្ដីសម្រេចតែប៉ុណ្ណោះ។ ការធ្វើបែបនេះរារាំងដល់ការវាយតម្លៃទាំងឡាយដើម្បីដឹងថាតើបន្ទុកភស្តុតាងហួសពីវិមតិសង្ស័យត្រូវបានឆ្លើយតប ឬមិនបានឆ្លើយតបនោះឡើយ ហើយបង្កឱ្យមានការសង្ស័យថាសាលដីកាត្រូវបានធ្វើឡើងតាមតែចិត្តរបស់ចៅក្រម។

- សាលដីកាប្រកាសថាជនជាប់ចោទមានពិរុទ្ធភាព មានចំនួនបីនាក់ក្នុងចំណោមប្រាំនាក់ (៦៧%)។
- ក្នុងចំណោមជនជាប់ចោទទាំង ៥៥៨ នាក់ សាលាឧទ្ធរណ៍បញ្ជាឱ្យមានការស៊ើបអង្កេតឡើងវិញតែ ៦ សំណុំរឿងប៉ុណ្ណោះ។
- ក្នុងអំឡុងពេលសង្កេតការណ៍របស់ ម.ស.ម.ក អនីតិជនទាំងអស់ត្រូវបានឃុំខ្លួននៅមុនពេលសវនាការលើកលែងតែពីរនាក់ប៉ុណ្ណោះ។
- ក្នុងចំណោមសវនាការជំនុំជម្រះលើអនីតិជនទាំង ៣៥ នាក់ដែល ម.ស.ម.ក បានសង្កេតការណ៍មានតែអនីតិជនម្នាក់ប៉ុណ្ណោះ ដែលត្រូវបានប្រើវិធានការ ដើម្បីគោរព និងការពារឯកជនភាព។
- ជាទូទៅ ពុំមានវិធានការជាក់លាក់ត្រូវបានធ្វើឡើងដើម្បីការពារសិទ្ធិរបស់អនីតិជនឡើយ ថ្វីបើប្រទេសកម្ពុជាជាភាគីមួយនៃអនុសញ្ញាស្តីពីសិទ្ធិកុមារក្តី។ ជំហានជាក់លាក់ចាំបាច់ត្រូវធ្វើដើម្បីបង្កើតឱ្យមានប្រព័ន្ធយុត្តិធម៌អនីតិជនពិសេសមួយ និងសម្របតាមប្រព័ន្ធដែលមានស្រាប់ដើម្បីការពារឯកជនភាពរបស់អនីតិជន។

ជាទូទៅ បញ្ហាភាគច្រើនដែលត្រូវបានគូសបញ្ជាក់ក្នុងរបាយការណ៍នេះអាចដោះស្រាយបានតាមរយៈវិធានការងាយៗ ចំណាយអស់តិច និងអាចអនុវត្តបានយ៉ាងឆាប់រហ័ស។ ឧទាហរណ៍ ការកែលម្អការសម្របសម្រួលទាក់ទងជាមួយការដឹកជញ្ជូនជនជាប់ចោទពីមណ្ឌលកែប្រែទៅចូលរួមសវនាការ ការសុំឱ្យសាក្សីចាកចេញពីបន្ទប់សវនាការមុនពេលចូលមកផ្តល់សក្ខីកម្មក្នុងសវនាការ និងការតម្រូវឱ្យចៅក្រមត្រូវពន្យល់ប្រាប់ជនជាប់ចោទអំពីសិទ្ធិរបស់គេជាដើម។ បញ្ហាមួយចំនួនទៀតនឹងអាចកែលម្អបានយ៉ាងងាយស្រួលតាមរយៈការបណ្តុះបណ្តាលចៅក្រម និងមេធាវីទាក់ទងជាមួយការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ សំខាន់ដូចគ្នាដែរ សមត្ថភាពរបស់សាលាឧទ្ធរណ៍គួរត្រូវបានពង្រឹងដើម្បីអនុញ្ញាតអាចដោះស្រាយសំណុំរឿងដែលនៅកកស្ទះ ជៀសវាងការពន្យារពេល និងគ្រប់គ្រងសំណុំរឿងថ្មីៗក្នុងលក្ខណៈសមស្រប និងទាន់ពេលវេលា។ ជាចុងក្រោយនេះ ម.ស.ម.ក សូមស្វាគមន៍សេចក្តីប្រកាសធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជាថានឹងមានការបង្កើតសាលាឧទ្ធរណ៍បន្ថែមនៅតាមបណ្តាខេត្តដទៃទៀត ព្រោះថាការស្ថាបនាសាលាឧទ្ធរណ៍បន្ថែមនឹងអាចដោះស្រាយបញ្ហាមួយចំនួនដែលបានលើកឡើងខាងលើ។[91] តាមរយៈការចាត់វិធានការចំពោះមុខដើម្បីដោះស្រាយកង្វល់ទាំងអស់នេះ សាលាឧទ្ធរណ៍អាចបង្កើតយុត្តិសាស្ត្រ ដើរតួជាឧទាហរណ៍ដល់សាលាដំបូង ព្រមទាំងអាចជះឥទ្ធិពលជាវិជ្ជមានលើគុណភាពនៃការផ្តល់យុត្តិធម៌ជាទូទៅក្នុងប្រទេសកម្ពុជា និងអាចចូលរួមចំណែកគួរជាទីកត់សម្គាល់ដើម្បីពង្រឹងនីតិរដ្ឋ។

[91] Khy Sovuthy, *"Government to Establish New Appeal Court by 2018"*, The Cambodia Daily ចេញថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១៦ អាចស្វែងរកបានតាមរយៈ៖http://bit.ly/2DNI05l។

បន្ថែមលើអនុសាសន៍ដែលបានលើកឡើងខាងលើ និងជាកិច្ចឆ្លើយតបចំពោះការខកខានគោរពតាមនិយាមការជំនុំជម្រះដោយយុត្តិធម៌ដូចដែលទិន្នន័យប្រមូលបានអំឡុងពេលធ្វើរបាយការណ៍ ម.ស.ម.ក សូមលើកឡើងនូវអនុសាសន៍បន្ថែមទៀតដូចខាងក្រោម៖

## ៤.១. អនុសាសន៍ទូទៅ

- ក្រសួងយុត្តិធម៌គួររៀបចំការបណ្តុះបណ្តាលជាប្រចាំ ស្តីពីការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បែបអនុវត្តជាក់ស្តែងសម្រាប់ចៅក្រមសាលាឧទ្ធរណ៍ ផ្អែកតាមទស្សនាទានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផ្អែកលើបទដ្ឋានជាតិ និងអន្តរជាតិ។
- សាលាឧទ្ធរណ៍គួរអនុវត្តតាមការប្រតិបត្តិល្អបំផុតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")។
- គួរបង្កើត និងអនុវត្តទម្រង់បទដ្ឋានមួយសម្រាប់ប្រើប្រាស់នៅក្នុងតុលាការ។ ព័ត៌មានដូចខាងក្រោមត្រូវបានបញ្ចូល ដើម្បីធានាឱ្យបានថារបាយការណ៍សង្ខេបដែលអានដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះនោះជារបាយការណ៍ពេញលេញដូចជា៖
  - បទល្មើសដែលជនជាប់ចោទត្រូវបានចោទ និងច្បាប់ពាក់ព័ន្ធ
  - កាលបរិច្ឆេទ ពេលវេលា ទីតាំងនៃបទល្មើស និងភាគីដែលពាក់ព័ន្ធ
  - សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលជនជាប់ចោទមានសិទ្ធិបានទទួល ដូចមានចែងក្នុងទំព័រទី៦ នៃរបាយការណ៍នេះ។ ជាពិសេស សិទ្ធិរបស់ជនជាប់ចោទទទួលបានការសន្មតជាមុនថាគ្មានទោស រហូតដល់សេចក្តីសម្រេចស្ថាពរ និងបន្ទុកភស្តុតាងដែលត្រូវជាបន្ទុករបស់អយ្យការ។

  ចៅក្រមគួរសួរទៅជនជាប់ចោទដោយផ្ទាល់ថាតើយល់អំពីបទចោទប្រកាន់ និងអំពីសិទ្ធិរបស់ខ្លួន ឬទេ។ ការខកខានក្នុងការអានព័ត៌មានខាងលើនៅពេលចាប់ផ្តើមការជំនុំជម្រះ នាំឱ្យមានមូលដ្ឋានប្តឹងតវ៉ានឹងសេចក្តីសម្រេចឱ្យមានពិរុទ្ធភាព។

## ៤.២. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានសវនាការជាសាធារណៈ

- សាលាឧទ្ធរណ៍ និងក្រសួងយុត្តិធម៌ គួរធានាឱ្យបានថាកាលវិភាគប្រចាំថ្ងៃរបស់សវនាការទាំងអស់ត្រូវបានបិទផ្សាយនៅលើក្តារខៀនព័ត៌មានខាងក្រៅបន្ទប់សវនាការយ៉ាងហោចណាស់ឱ្យបាន ២៤ម៉ោងមុនពេលសវនាការ ហើយបន្តធានាលទ្ធភាពរបស់សាធារណជនអាចចូលមកក្នុងបន្ទប់សវនាការបានទាំងអស់ លើកលែងតែក្នុងករណីពិសេសដែលអាចរួមមានករណីអនីតិជន។ ពេលដែលព័ត៌មានទាំងអស់នេះត្រូវបានបិទផ្សាយនៅលើក្តារខៀនព័ត៌មាន ឈ្មោះរបស់អនីតិជនមិនគួរត្រូវបានសរសេរចេញមកឡើយ ហើយគួរតែហៅអនីតិជនដោយប្រើអក្សរដើមនៃឈ្មោះដើម្បីការពារឯកជនភាពរបស់គេ។

## ៤.៣. អនុសាសន៍ទាក់ទងនឹងសិទ្ធិមានវត្តមាននៅពេលសវនាការ និងមានមេធាវី

- សាលាឧទ្ធរណ៍ និងអគ្គនាយកដ្ឋានពន្ធនាគារត្រូវពិគ្រោះយោបល់ និងសម្របសម្រួលជាមួយគ្នាដើម្បីដោះស្រាយបញ្ហាភស្តុភារ និងបញ្ហាការប្រាស្រ័យទាក់ទងឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបានទាក់ទងជាមួយទីតាំងឃុំខ្លួនរបស់ជនជាប់ចោទចោទ ជាពិសេសគឺៈ
  - អគ្គនាយកដ្ឋានពន្ធនាគារចាំបាច់ត្រូវធានាឱ្យបានថាព័ត៌មានស្តីពីការផ្ទេរជនជាប់ឃុំត្រូវបានបញ្ជូនមកឱ្យអយ្យការជាទៀងទាត់។
  - សាលាឧទ្ធរណ៍ចាំបាច់ត្រូវធានាឱ្យបានថា ព័ត៌មានទាក់ទងជាមួយកាលបរិច្ឆេទ និងពេលវេលាសវនាការនៃឧទ្ធរណ៍ត្រូវបានបញ្ជូនទៅដល់មណ្ឌលកែប្រែដាកន្លែងដែលជនជាប់ចោទត្រូវបានឃុំខ្លួនឱ្យបានត្រឹមត្រូវ។
- ចៅក្រមសាលាឧទ្ធរណ៍គួរពន្យារសវនាការ ប្រសិនបើជនជាប់ចោទពុំមានវត្តមានក្នុងសវនាការ បើទោះបីជាជនជាប់ចោទនោះមានមេធាវីតំណាងក៏ដោយ លើកលែងតែជនជាប់ចោទបានបោះបង់សិទ្ធិមានវត្តមាននៅសវនាការរបស់ខ្លួនយ៉ាងជាក់ច្បាស់ និងជាផ្លូវការ។
- ក្នុងករណីជនជាប់ចោទច្រើននាក់ត្រូវបានតំណាងដោយមេធាវីតែម្នាក់ ចៅក្រមសាលាឧទ្ធរណ៍ត្រូវធានាឱ្យបានថាពុំមានទំនាស់ផលប្រយោជន៍ ហើយមេធាវីអាចផ្តល់ការការពារប្រកបដោយប្រសិទ្ធភាពដល់ជនជាប់ចោទទាំងអស់ដែលមេធាវីនោះតំណាងឱ្យ។
- ចៅក្រមសាលាឧទ្ធរណ៍គួរប្រាប់ និងពន្យល់ជនជាប់ចោទពីសិទ្ធិមានមេធាវីតាមការជ្រើសរើសរបស់ខ្លួន ហើយធានាឱ្យបានថាជនជាប់ចោទដែលជ្រើសរើសការការពារខ្លួនដោយខ្លួនឯង ធ្វើឡើងដោយផ្អែកលើព័ត៌មានត្រឹមត្រូវ ហើយសម្រេចចិត្តមិនស្វែងរកមេធាវី។

## ៤.៤. អនុសាសន៍ទាក់ទងនឹងការសន្មតទុកជាមុនថាគ្មានទោស

- ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃត្រូវចេញ និងផ្សព្វផ្សាយនូវគោលការណ៍ណែនាំយ៉ាងច្បាស់លាស់ដោយគូសបញ្ជាក់ថា ជនជាប់ឃុំដែលរង់ចាំសវនាការ ឬជនដែលត្រូវបានជំនុំជម្រះហើយ ប៉ុន្តែសាលក្រម ឬសាលដីកាស្ថាពរមិនទាន់ស្ថាពរ ចាំបាច់ត្រូវបានអនុញ្ញាតឱ្យបង្ហាញខ្លួនក្នុងសវនាការដោយស្លៀកសម្លៀកបំពាក់ស៊ីវិល។
- ចៅក្រមសាលាឧទ្ធរណ៍ត្រូវប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរពន្ធនាគារដែលពាក់ព័ន្ធ ដើម្បីធានាឱ្យបានថាពុំមានជនជាប់ចោទណាម្នាក់បង្ហាញខ្លួនក្នុងឯកសណ្ឋានពន្ធនាគារ ដោយហេតុថាការមានវត្តមាននៅសវនាការក្នុងឯកសណ្ឋានពន្ធនាគារជាការរំលោភបំពានលើគោលការណ៍ការការសន្មតទុកជាមុនថាគ្មានទោស។

- ចៅក្រមសាលាឧទ្ធរណ៍ចាំបាច់ត្រូវប្រាប់ដល់ជនជាប់ចោទ ឱ្យបានជាក់ច្បាស់អំពីសិទ្ធិត្រូវបានសន្មតថាគ្មានទោសរបស់ជនជាប់ចោទរហូតដល់ពេលចេញសាលដីកាស្ថាពរ ត្រូវប្រាប់ឱ្យជនជាប់ចោទបានដឹងថាបន្ទុកភស្តុតាងគឺជាកាតព្វកិច្ចរបស់អយ្យការ និងប្រាប់ឱ្យបានដឹងថាជនជាប់ចោទមានសិទ្ធនៅស្ងៀម ហើយការនៅស្ងៀមនេះនឹងមិនត្រូវបានប្រើប្រាស់ប្រឆាំងរូបគាត់ឡើយ។
- ក្រសួងមហាផ្ទៃគួរគោរពតាមការប្រតិបត្តិល្អជាលក្ខណៈអន្តរជាតិដែលអនុវត្តដោយ អ.វ.ត.ក ដែលអនុញ្ញាតឱ្យជនជាប់ចោទស្លៀកសម្លៀកបំពាក់ស៊ីវិលរបស់ខ្លួន ចូលមកក្នុងតុលាការនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីព្រហ្មទណ្ឌរហូតដល់ចេញសាលក្រម/សាលដីកាថាមានទោសជាស្ថាពរ។

## ៤.៥. អនុសាសន៍ទាក់ទងនឹងការការពារខ្លួនពីការឆ្លើយដាក់បន្ទុកបទល្មើសលើខ្លួនឯង

- ចៅក្រមសាលាឧទ្ធរណ៍ត្រូវរំលឹកជនជាប់ចោទអំពីសិទ្ធិមិនផ្តល់ភស្តុតាង ដែលអាចប្រើប្រាស់ប្រឆាំងរូបគាត់។
- ចៅក្រមសាលាឧទ្ធរណ៍ត្រូវធានាឱ្យបានថា រាល់ការសារភាព ឬសេចក្តីថ្លែងពីភាពមានពិរុទ្ធ ត្រូវបានផ្តល់ឱ្យដោយសេរី ដោយពុំមានការបង្ខិតបង្ខំដោយផ្ទាល់ ឬដោយប្រយោលតាមផ្លូវកាយ ឬផ្លូវចិត្តឡើយ។
- ប្រសិនបើជនជាប់ចោទបាននិយាយថា ការសារភាព ឬសេចក្តីថ្លែងពីភាពមានពិរុទ្ធបានទទួលដោយមានការបង្ខិតបង្ខំ ចៅក្រមសាលាឧទ្ធរណ៍ចាំបាច់ត្រូវរំលឹកឡើងវិញថាបន្ទុកភស្តុតាង ដើម្បីបញ្ជាក់ថាសេចក្តីថ្លែងនោះមិនត្រូវបានធ្វើឡើងក្រោមការបង្ខិតបង្ខំ គឺជាបន្ទុករបស់ភាគីនៃអ្នកផ្តល់សេចក្តីថ្លែង ពោលគឺពុំមែនជាបន្ទុករបស់ជនជាប់ចោទឡើយ។ ចៅក្រមត្រូវចាត់វិធានការទាំងអស់ដើម្បីវាយតម្លៃថាតើមានមូលហេតុណាមួយ ដើម្បីជឿជាក់ថាសេចក្តីថ្លែងពីភាពមានពិរុទ្ធ ត្រូវបានធ្វើឡើងដោយមានការបង្ខិតបង្ខំឬទេ។
- ក្នុងករណីដែលមានមូលដ្ឋានសមហេតុផល ដើម្បីជឿជាក់ថាការសារភាពត្រូវបានធ្វើឡើងដោយមានការបង្ខិតបង្ខំ ឬដាក់សម្ពាធ ចៅក្រមសាលាឧទ្ធរណ៍មិនត្រូវទទួលយកមកជាភស្តុតាងឡើយ។
- នៅពេលទទួលយកការសារភាព ឬសេចក្តីថ្លែងពីភាពមានពិរុទ្ធមកធ្វើជាភស្តុតាងដែលក្នុងនោះជនជាប់ចោទនិយាយថា ជាការសារភាព ឬសេចក្តីថ្លែងដែលពុំបានផ្តល់ឱ្យដោយឆន្ទៈសេរី ចៅក្រមសាលាឧទ្ធរណ៍ចាំបាច់ត្រូវផ្តល់ហេតុផលលម្អិតបញ្ជាក់អំពីមូលហេតុដែលខ្លួនធ្វើដូច្នេះ។

## ៤.៦. អនុសាសន៍ទាក់ទងជាមួយសិទ្ធិបង្ហាញភស្តុតាង

- ចៅក្រមសាលាឧទ្ធរណ៍ត្រូវប្រាប់ដល់ជនជាប់ចោទ អំពីសិទ្ធិបង្ហាញភស្តុតាងនៅក្នុងលក្ខខណ្ឌដូចគ្នាជាមួយភស្តុតាងដែលត្រូវបានបង្ហាញដើម្បីប្រឆាំងរូបគាត់។

- ចៅក្រមសាលាឧទ្ធរណ៍ត្រូវបង្គាប់សាក្សីឱ្យចាកចេញពីបន្ទប់សវនាការ ហើយមិនត្រូវវិលមកកាន់បន្ទប់សវនាការវិញឡើយ រហូតទាល់តែដល់ពេលដែលគេហៅចូលមកធ្វើសក្ខីកម្ម ជាមធ្យោបាយមួយដើម្បីបញ្ជាក់ថាសាក្សីពុំបានរងឥទ្ធិពលពីភស្តុតាង ឬសក្ខីកម្មដទៃទៀតដែលត្រូវបានបង្ហាញក្នុងអំឡុងពេលសវនាការ។
- ចៅក្រមសាលាឧទ្ធរណ៍ចាំបាច់ត្រូវវាយតម្លៃដោយប្រុងប្រយ័ត្ន ថាតើភស្តុតាងដែលត្រូវបានបង្ហាញចំពោះមុខសវនាការអាចបង្កើតមូលដ្ឋានហួសពីវិមតិសង្ស័យដែលបញ្ជាក់ថាជនជាប់ចោទមានពិរុទ្ធភាព។ ប្រសិនបើមានការបកស្រាយភស្តុតាងដែលស៊ីសង្វាក់ជាមួយភាពគ្មានពិរុទ្ធរបស់ជនជាប់ចោទ ត្រូវលើកលែងរួចផុតពីបទចោទ។

## ៤.៧. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានសេចក្តីសម្រេចមានសម្អាងហេតុ

- ចៅក្រមសាលាឧទ្ធរណ៍ត្រូវប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីមូលហេតុដែលឈានដល់ការសម្រេចទោស។ ជាពិសេស ចៅក្រមចាំបាច់ត្រូវបង្ហាញពីមាត្រាច្បាប់ពាក់ព័ន្ធ ព្រមទាំង ភស្តុតាងសំខាន់ៗ ដែលជាមូលដ្ឋាននៃការចេញសេចក្តីសម្រេចរបស់ខ្លួន។

## ៤.៨. អនុសាសន៍ដើម្បីការពារអនីតិជនក្នុងប្រព័ន្ធព្រហ្មទណ្ឌ

- ចៅក្រមសាលាឧទ្ធរណ៍ត្រូវអនុវត្តបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឱ្យបានហ្មត់ចត់ដើម្បីការពារឧត្តមប្រយោជន៍របស់អនីតិជនជាជនជាប់ចោទ ជាពិសេស គឺមាត្រា ៤៧ ដែលតម្រូវឱ្យដំណើរការជំនុំជម្រះ និងសេចក្តីសម្រេច ត្រូវធ្វើឡើងក្នុងសវនាការបិទទ្វារ។
- ចៅក្រម និងព្រះរាជអាជ្ញា ត្រូវឆ្លងកាត់ការបណ្តុះបណ្តាលជាក់លាក់ទាក់ទងជាមួយបញ្ហាពាក់ព័ន្ធយុត្តិធម៌អនីតិជន ហើយការបណ្តុះបណ្តាលនេះគួរត្រូវបានអនុវត្តរួមគ្នាដោយក្រសួងយុត្តិធម៌ជាមួយគណៈមេធាវី។
- សាលាឧទ្ធរណ៍ត្រូវប្រើប្រាស់ប្រព័ន្ធឆ្លើយឆ្លងតាមវីដេអូដែលបច្ចុប្បន្នមានរួចហើយនៅតុលាការ ហើយត្រូវធានាយ៉ាងណាឱ្យមន្ត្រីរបស់ខ្លួនបានទទួលការបណ្តុះបណ្តាលពីការប្រើប្រាស់នេះ។ ក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តកម្មវិធីបង្វែរដោយក្នុងនោះជនល្មើសជាអនីតិជន បានទទួលការគាំទ្រ និងស្តារនីតិសម្បទានៅក្នុងសហគមន៍ ជាជម្រើសជំនួសឱ្យការកាត់ទោសជាផ្លូវការ។ គម្រោងនេះ ចាំបាច់ត្រូវអនុវត្តសម្រាប់ជនចាប់ចោទប្រព្រឹត្តបទល្មើសលើកដំបូងគ្រប់រូប លើកលែងតែបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរបំផុត។
- ជម្រើសក្នុងការកាត់ទោសអនីតិជនចាំបាច់ត្រូវពង្រីកឱ្យទូលំទូលាយថែមទៀត។ ក្រសួងយុត្តិធម៌ក្រោមការគាំទ្រពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តគោលការណ៍ណែនាំក្នុងការ

កាត់ទោសទាក់ទងជាមួយអនីតិជន ដោយក្នុងនោះត្រូវផ្តោតការយកចិត្តទុកដាក់លើការស្តារនីតិសម្បទារបស់អនីតិជន ជាជាងការផ្តន្ទាទោសតែមួយមុខ។ ចាំបាច់ត្រូវចៀសវាងជាដាច់ខាតនូវការឃុំខ្លួនកុមារ ហើយការឃុំខ្លួនកុមារត្រូវបានអនុវត្តតែក្នុងករណីធ្ងន់ធ្ងរបំផុត ឬក្នុងករណីដែលចាំបាច់ត្រូវឃុំខ្លួនកុមារ ដោយសារមូលហេតុដើម្បីការពារផលប្រយោជន៍សាធារណៈ។

- ក្រសួងយុត្តិធម៌ត្រូវពិនិត្យឡើងវិញលើបទដ្ឋានគតិយុត្តិជាធរមាន រួមទាំងច្បាប់ពាក់ព័ន្ធជាមួយការប្រព្រឹត្តទៅរបស់តុលាការ ដើម្បីធានាឱ្យអនុលោមតាមបទដ្ឋានអន្តរជាតិស្តីពីប្រព័ន្ធយុត្តិធម៌អនីតិជន ដោយក្នុងនោះ រួមមានទាំងវិធានបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិសម្រាប់ការអនុវត្តយុត្តិធម៌អនីតិជន ("វិធានក្រុងប៉េងកាំង")[92] គោលការណ៍ណែនាំរបស់មូលនិធិសហប្រជាជាតិដើម្បីកុមារសម្រាប់កំណែទម្រង់ផ្នែកច្បាប់ស្តីពីយុត្តិធម៌អនីតិជន[93] សៀវភៅជំនួយស្មារតីការអនុវត្តរបស់មូលនិធិសហប្រជាជាតិដើម្បីកុមារសម្រាប់អនុសញ្ញាស្តីពីសិទ្ធិកុមារ[94] និងរបាយការណ៍កំណែទម្រង់ច្បាប់ និងការអនុវត្តច្បាប់របស់មូលនិធិសហប្រជាជាតិដើម្បីកុមារ ទាក់ទងនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ។[95]

---

[92] អាចស្វែងរកបានតាមរយៈ៖ http://www.ohchr.org/Documents/ProfessionalInterest/beijingrules.pdf.

[93] អាចស្វែងរកបានតាមរយៈ៖ http://www.unicef.org/policyanalysis/files/Juvenile_justice_16052011_final.pdf.

[94] ជាពិសេសនៅទំព័រ ១០៧ អាចស្វែងរកបានតាមរយៈ៖ http://www.unicef.org/publications/index_43110.html.

[95] ជាពិសេសនៅទំព័រ ១០៧ អាចស្វែងរកបានតាមរយៈ៖ http://www.unicef-irc.org/publications/pdf/law_reform_អនុសញ្ញាស្តីពីសិទ្ធិកុមារ_imp.pdf.

# ៥. ឯកសារយោងនិទ្ទេស

## នីតិជាតិ

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (២០០៧)។ http://bit.ly/2C9dRwR

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣ ដូចដែលបានធ្វើវិសោធនកម្ម)។ http://bit.ly/2HZZUnn

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (២០០៩)។ http://bit.ly/2BD6cpf

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ២០១៦)។ http://bit.ly/2BfhuPv

ច្បាប់ស្តីពីពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជា (២០១១)។ http://bit.ly/2oME26Z

ប្រកាសលេខ ២១៧ ស្តីពីការគ្រប់គ្រងពន្ធនាគារ (ថ្ងៃទី ១៣ ខែមីនា ឆ្នាំ ១៩៩៨)។ http://bit.ly/2FQpSIJ

បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល (១៩៩២)។ http://bit.ly/2rgWYOG

## លិខិតូបករណ៍គោលនយោបាយកម្ពុជា

ក្រុមប្រឹក្សាភិបាលស្តារនីតិសម្បទា និងអភិវឌ្ឍកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា *ឯកសារបញ្ជាក់គោលជំហរលទ្ធផលការងារគោលនយោបាយរបស់រដ្ឋាភិបាល*, http://bit.ly/2EvRqSd

ក្រុមប្រឹក្សាកំណែទម្រង់ផ្នែកច្បាប់ និងយុត្តិធម៌ *យុទ្ធសាស្ត្រកំណែទម្រង់ផ្នែកច្បាប់ និងយុត្តិធម៌* អនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងកិច្ចប្រជុំពេញអង្គកាលពីថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០០៣, http://bit.ly/2pEnsaX

